ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- មេរៀនកម្ពុជា សម្រាប់អនាគតអាហ្វហ្គានីស្ថាន
- ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិកប្រកាសអំពីហិរញ្ញប្បទានថ្មី ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
- កម្មវិធីផ្សាយសំឡេងតាមស្ថានីយ៍វិទ្យុអេហ្វអឹមជាតិ ភ្នំក្រាំងដីមាស ខេត្តកំពង់ឆ្នាំង ដើម្បីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦១ ខែកញ្ញា ឆ្នាំ២០២១

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦១ ខែកញ្ញា ឆ្នាំ២០២១



ក្រុមគ្រូពេទ្យខ្មែរក្រហមដើរពិនិត្យសុខភាពប្រជាជននៅតាមផ្ទះៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


- មេរៀនកម្ពុជា សម្រាប់អនាគតអាហ្វ ..........១


### ផ្នែកឯកសារ


- កងទ័ពវៀតណាម ប៉ូយ ហុងវ៉ៃ ............. ៥


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ទីភ្នាក់ងាររដ្ឋផ្ដល់ជំនួយសហរដ្ឋអាមេរិក ..... ៨
- កិច្ចសហការរវាងសកលវិទ្យាល័យស្ទែនហ្វត និងមជ្ឈមណ្ឌលឯកសារកម្ពុជា ........... ១២
- ឯកអគ្គរដ្ឋទូតអាមេរិក W. Patrick Murphy ..... ចូលរួមកម្មវិធីប្រកាសអំពីហិរញ្ញប្បទានថ្មី .... ១៤
- សារព័ត៌មានហ្វ្រេសញ៉ូ ធ្វើបទសម្ភាសន៍ជាមួយលោក ឆាំង យ៉ុ .................... ១៨
- កិច្ចសម្ភាសន៍រវាងសារព័ត៌មានរស្មីកម្ពុជាជាមួយ លោក ឆាំង យុ ................. ២២
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តត្បូងឃ្មុំទទួលកញ្ចប់អនុស្សាវរីយ៍ ... ២៦
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពង់ស្ពឺ ទទួលកញ្ចប់អនុស្សាវរីយ៍ ... ២៨
- សហគមន៍ជនជាតិភាគតិចចាម នៅក្នុងស្រុកក្រូចឆ្មារ ទទួលបានកញ្ចប់អនុស្សាវរីយ៍.. ៣០
- អនុព័ន្ធយោធាសហរដ្ឋអាមេរិកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ.... ៣២
- មជ្ឈមណ្ឌលឯកសារកម្ពុជាផ្ដល់ម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគ .................... ៣៣
- ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី យ៉ាងទស្សនកិច្ច «បណ្ណាល័យសម្ដេចម៉ែ» ...... ៣៤
- យូ ព្រឿង ៖ អតីតពេទ្យផ្នែកផលិត ..... ៣៧
- រ៉ា យ៉ែម ៖ ខ្មែរក្រហមបង្ខំឲ្យខ្ញុំសឹក ...... ៤១


### ផ្នែកច្បាប់


- សាលក្រមសំណុំរឿង០០២/០២ .........៤៥


### ផ្នែកវេទិកាសាធារណៈ


- កម្មវិធីផ្សាយសំឡេងតាមស្ថានីយ៍វិទ្យុ ...... ៥៧


### ផ្នែកស្រាវជ្រាវរកគ្រួសារ


«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
- ជា គីមស្រេង៖ មេផ្ទះ ........................៦០


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ឡុង អូន, ឡុង ដានី, សុភ័ក្ត្រ ភាណា, ភា រស្មី, មីន សាណាស់, មេក វិន, ដារ៉ារដ្ឋ មេត្តា, ដេង ពង្សរ៉ាស៊ី, ប៉ាង ពីរីន្ទ និង វេនី ខកហ្កៀល
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** អ៊ុន សុដាវី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# មេរៀនកម្ពុជា សម្រាប់អនាគតអាហ្វហ្គានីស្ថាន

ឆាំង យុ



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការក្រោកឈរឡើងវិញរបស់តាលីបង់ និងការដួលរលំនៃសាធារណរដ្ឋអ៊ីស្លាមអាហ្វហ្គានីស្ថាន គឺជាសោកនាដកម្មដ៏រន្ធត់មួយដែលបានកម្រើកមកវិញនូវការចងចាំអំពីសង្គ្រាមពីអតីតកាល និងការជជែកវែកញែកអំពីគោលនយោបាយផ្សេងៗ។ ប៉ុន្តែយើងត្រូវគិតឲ្យបានហ្មត់ចត់ និងប្រើគំនិតឆ្ពោះទៅមុខក្នុងការដោះស្រាយវិបត្តិនេះ។ អនាគតរបស់ប្រទេសអាហ្វ-ហ្គានីស្ថាន គឺមិនទាន់ត្រូវបានកំណត់ជាក់លាក់នៅឡើយទេ។ មានការលើកឡើងជាច្រើនទាក់ទងនឹងការដកខ្លួនរបស់សហរដ្ឋអាមេរិកចេញពីប្រទេសវៀតណាម និងបានយកព្រឹត្តិការណ៍នេះទៅធ្វើជាប្រវត្តិសាស្ត្រប្រៀបធៀបដ៏សំខាន់ក្នុងការវាយតម្លៃពីផលប៉ះពាល់នៃស្ថានការណ៍នៅប្រទេសអាហ្វហ្គានីស្ថាននាពេលបច្ចុប្បន្ន ប៉ុន្តែប្រវត្តិសាស្ត្រប្រៀបធៀបដែលល្អជាងនេះគឺមេរៀនប្រទេសកម្ពុជា។ ប្រវត្តិសាស្ត្រប្រទេសកម្ពុជាមិនត្រឹមតែអាចផ្តល់នូវការយល់ដឹងដ៏សំខាន់ចំពោះផលប៉ះពាល់នៃស្ថានភាពបច្ចុប្បន្ននៅប្រទេសអាហ្វហ្គានីស្ថានតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការរំឭកដ៏សំខាន់ថាក្តីសង្ឃឹមចំពោះគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិកនាពេលអនាគត និងវិធីសាស្ត្ររបស់សហគមន៍អន្តរជាតិចំពោះប្រជាជនអាហ្វហ្គានីស្ថានគឺនៅតែមានៗ

យើងមិនអាចមិនប្រៀបធៀបរូបភាពនៃការជម្លៀសចេញដ៏វឹកវរតាមយន្តហោះរបស់សហរដ្ឋអាមេរិក និងប្រជាជនអាហ្វហ្គានីស្ថាន ជាមួយនឹងរូបភាពនៃការចាកចេញរបស់សហរដ្ឋអាមេរិកពីអាស៊ីអាគ្នេយ៍ឡើយ។ មានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានល្បីៗជាច្រើនបានធ្វើការប្រៀបធៀបនេះ ដោយប្រើប្រាស់រូបភាពនៃការជម្លៀសចេញរបស់សហរដ្ឋអាមេរិកដោយឧទ្ធម្ភាគចក្រនៅទីក្រុងសៃហ្គន ឬ ទីក្រុងព្រៃនគរ (ទីក្រុងហូជីមិញ) ប្រទេសវៀតណាម។ យើងមិនអាចបដិសេធទេថាការចាកចេញរបស់សហរដ្ឋអាមេរិកពីលើដំបូលសណ្ឋាគារនៅទីក្រុងកាប៊ុល គឺស្រដៀងគ្នានឹងរូបភាពនៃការជម្លៀសដ៏វឹកវររបស់ស្ថានទូតអាមេរិកនៅប្រទេសវៀតណាម ប្រមាណជាហាសិបឆ្នាំមុន ប៉ុន្តែភាពប្រហាក់ប្រហែលគ្នានៃព្រឹត្តិការណ៍ទាំងពីរគឺបញ្ចប់នៅត្រឹមទីនោះ ហើយព្រឹត្តិការណ៍នៅប្រទេសកម្ពុជាគឺសាក

សមបំផុតក្នុងការលើកមកប្រៀបធៀបដោយសារហេតុផលមួយចំនួន។

នៅពេលដែលកងទ័ពខ្មែរក្រហមដណ្តើមអំណាចនៅខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងទាហានអាមេរិកបានធ្វើការចាកចេញយ៉ាងប្រញាប់ប្រញាល់ពីប្រទេសកម្ពុជា និងរៀបចំការជម្លៀសជនជាតិអាមេរិក មន្ត្រីរដ្ឋាភិបាលកម្ពុជា និងអ្នកដែលអាចទទួលបានសិទ្ធិជនភៀសខ្លួនបុហ៊ានះផ្សេងៗទៀត។ ការជម្លៀសនេះត្រូវបានចងចាំមិនត្រឹមតែពីភាពច្របូកច្របល់តែប៉ុណ្ណោះទេ ប៉ុន្តែគឺភាពក្តុកក្តួលយ៉ាងខ្លាំងរបស់ប្រជាជនកម្ពុជាដែលមានអារម្មណ៍ថា ខ្លួនត្រូវបានបោះបង់ចោលជាពិសេសមន្ត្រីរដ្ឋការដែលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីអាមេរិក។ អតីតឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅប្រទេសកម្ពុជា ក្នុងអំឡុងរបបសាធារណរដ្ឋខ្មែរលោក ចន គានធ៌ដីន (១៩៧៤-១៩៧៥) បានចែករំលែកសំបុត្រមួយច្បាប់ដែលផ្ញើជូនលោកប្រហែលជាពីរបីម៉ោងមុនពេលដែលសហរដ្ឋអាមេរិកជម្លៀសចេញពីទីក្រុងភ្នំពេញ។

សំបុត្រនេះសរសេរដោយមេដឹកនាំនយោបាយនៃរបបសាធារណរដ្ឋខ្មែរ និងជាសមាជិកម្នាក់នៃគ្រួសាររាជវង្សកម្ពុជាគឺ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ មានខ្លឹមសារដូចខាងក្រោម ៖

**ជូនឯកឧត្តម និងប្រិយមិត្ត,**

**ខ្ញុំសូមអរគុណដោយស្មោះចំពោះការផ្តល់ជូនរបស់លោកដើម្បីនាំខ្ញុំឆ្ពោះទៅរកសេរីភាព។ ខ្ញុំមិនអាចចាកចេញដោយភាពកំសាកបែបនេះបានទេ។ ចំពោះរូបលោក និងប្រទេសដ៏អស្ចារ្យរបស់លោកខ្ញុំស្ទើរតែមិនអាចជឿទាល់តែសោះថាលោកនឹងបោះបង់ចោលប្រជាជនដែលជ្រើសរើសសេរីភាព។ លោកបានបដិសេធមិនការពារប្រជាជនកម្ពុជា ហើយយើងទាំងអស់គ្នាមិនអាចធ្វើអ្វីបានទេ។ លោកចាកចេញទៅ ខ្ញុំសូមប្រសិទ្ធពរជូនលោក និងប្រទេសរបស់លោកឱ្យជួបតែសុភមង្គលនៅក្រោមមេឃ។ ប៉ុន្តែសូមលោកចងចាំឱ្យបានល្អថា ប្រសិនបើខ្ញុំស្លាប់នៅក្នុងប្រទេសដែលខ្ញុំស្រឡាញ់ គឺសូមឱ្យបែបហ្នឹងទៅចុះ។ ខ្ញុំបានប្រព្រឹត្តកំហុសតែមួយគត់គឺជឿជាក់ទៅលើលោក និងជនជាតិអាមេរិក។ សូមឯកឧត្តម និងមិត្តទទួលយកនូវការរាប់អាននិងសេចក្តីស្មោះត្រង់ពីខ្ញុំ។**

**ហត្ថលេខា,**
**សិរិមតៈ**

មួយសប្តាហ៍ក្រោយមកព្រះអង្គម្ចាស់ សិរិមតៈ ត្រូវបានខ្មែរក្រហមសម្លាប់។ ដូចជាព្រះអង្គម្ចាស់ សិរិមតៈដែរ ប្រជាជនកម្ពុជាជាច្រើនត្រូវបានសហរដ្ឋអាមេរិកបោះបង់ចោលនៅពេលដែលខ្លួនចាកចេញទៅ និងទុកឲ្យប្រទេសកម្ពុជាធ្លាក់ក្នុងរបបខ្មែរក្រហមដែលជាចលនាកុម្មុយនីស្ត និងបានសម្លាប់ប្រជាជនកម្ពុជាជាង២លាននាក់។ អារម្មណ៍ដែលត្រូវបានបោះបង់ចោល ភាពអសន្តិសុខ និងភេរវកម្មដ៏ឃោរឃៅដែលបានកើតឡើងទៅលើប្រជាជនកម្ពុជានៅឆ្នាំ១៩៧៥ គឺពិតជាដូចគ្នាទៅនឹងអ្វីដែលជនជាតិអាហ្វហ្គានីស្ថានជាច្រើនជួបប្រទះនៅពេលបច្ចុប្បន្ន ជាពិសេសអ្នកដែលបានលះបង់ជីវិតរបស់ខ្លួនដើម្បីស្វែងរកសេរីភាពឲ្យប្រទេសអាហ្វហ្គានីស្ថាន។

ទោះបីជាយ៉ាងណាក៏ដោយ អារម្មណ៍នៃការបោះបង់ចោលនេះ មិនសំដៅចំពោះតែសហរដ្ឋអាមេរិកនោះទេ។ សហរដ្ឋអាមេរិកបានដឹកនាំយុទ្ធនាការដែលបានផ្តួលរំលំរបបតាលីបង់ និងប៉ុនប៉ងកសាងឡើងវិញនូវរបបសាធារណរដ្ឋអាហ្វហ្គានីស្ថាន ប៉ុន្តែប្រទេសអាហ្វហ្គានីស្ថានមិនត្រូវបានបោះបង់ចោលដោយសហរដ្ឋអាមេរិកតែមួយនោះទេ។អង្គការសហប្រជា

ជាតិ និងសហគមន៍អន្តរជាតិ គឺមានចំណែកទទួលខុសត្រូវស្មើគ្នាចំពោះស្ថានការណ៍នៅប្រទេសអាហ្វហ្កានីស្ថាន ដូចដែលពួកគេមានទំនួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា នាចុងសតវត្សរ៍ទី២០។ ការយល់ដឹងមួយចេញពីការប្រៀបធៀបរវាងស្ថានភាពប្រទេសកម្ពុជា និងអាហ្វហ្កានីស្ថាន គឺគ្មានអ្វីដែលអាចជំនួសការដឹកនាំរបស់សហរដ្ឋអាមេរិកបានឡើយ។ ភាពជាអ្នកដឹកនាំរបស់សហរដ្ឋអាមេរិក គឺនៅតែជាកត្តាដ៏សំខាន់ហើយអាចនិយាយបានថា ជាធាតុផ្សំដ៏សំខាន់ក្នុងការការពារ ក៏ដូចជាការដោះស្រាយបញ្ហាសន្តិសុខអន្តរជាតិ។

ការយល់ដឹងមួយទៀតដែលទទួលបានពីការប្រៀបធៀបរវាងប្រទេសអាហ្វហ្កានីស្ថាន និងកម្ពុជា គឺអំពីការបើកបង្ហាញ ឬការបញ្ជាក់ឲ្យឃើញថា ការស្វែងរកគោលដៅអភិវឌ្ឍន៍មនុស្ស ដូចជា ការការពារសិទ្ធិមនុស្ស ការប្តេជ្ញាចិត្តចំពោះប្រជាជនងាយរងគ្រោះ និងការគាំទ្រដល់សង្គមស៊ីវិល គឺត្រូវតែត្រឹមត្រូវមានលក្ខខណ្ឌ និងអន្តរកាល។ អ្នកវិភាគទុទ្ទិដ្ឋិនិយម និងប្រវត្តិវិទូជាច្រើននឹងធ្វើការជជែកវែកញែកថា កាលៈទេសៈនេះគឺមិនមែនជាការបើកបង្ហាញ ប៉ុន្តែយើងជឿជាក់ថា ការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិចំពោះគោលដៅអភិវឌ្ឍន៍មនុស្សគឺបានបាត់បង់ទំនុកចិត្តដែលជាកត្តាដ៏សំខាន់ចំពោះ កិច្ចខិតខំប្រឹងប្រែងនាពេលអនាគត ហើយផលប៉ះពាល់នៃកាលៈទេសៈនេះនឹងបន្តវិវឌ្ឍន៍ទៅមុខ។

ទោះបីជាមានសេចក្តីថ្លែងការណ៍ជាសាធារណៈដោយថ្នាក់ដឹកនាំតាលីបង់ក៏ដោយ ប៉ុន្តែជាក់ស្តែងគឺការស្វែងរកគោលដៅអភិវឌ្ឍន៍មនុស្សនៅប្រទេសអាហ្វហ្កានីស្ថាន ត្រូវបានប្រគល់ទៅឲ្យអង្គការភេរវកម្មបាត់ទៅហើយ។ របបនេះបានបង្ហាញពីទំនោររួចទៅហើយចំពោះអំពើឃោរឃៅ និងអរិភាពចំពោះសង្គមស៊ីវិល ហើយគណៈរដ្ឋមន្ត្រីដែលទើបបង្កើតថ្មីរបស់តាលីបង់មិនមានលក្ខណៈរាប់បញ្ចូល ឬមិនតំណាងឲ្យការសន្យានៃការកែទម្រង់របស់ខ្លួនឡើយ។ ការលើកឡើងថ្មីៗថាតាលីបង់បច្ចុប្បន្នអាចមានភាពខុសប្លែកពីតាលីបង់ពីអតីតកាលអាចបញ្ជាក់ថា គឺមិនត្រឹមត្រូវដោយមូលហេតុរៀបរាប់ខាងលើ។ ការវាយដំជាសាធារណៈទៅលើជនស៊ីវិល ស្ទួតត្រង់ការវាយប្រហារសងសឹកអតីតអ្នកគាំទ្រសាធារណរដ្ឋអាហ្វហ្កានីស្ថាននិងការផ្លាស់ប្តូរសមត្ថភាពស្ត្រីក្នុងការរស់នៅ និងធ្វើការដោយគ្មានការគាបសង្កត់ទាំងនេះ គឺបង្ហាញថាហេតុការណ៍ដែលអាក្រក់បំផុតគឺនឹងនៅមានបន្តទៀត។

ការពិចារណារបស់សហគមន៍អន្តរជាតិក្នុងការសហការជាមួយតាលីបង់ ធ្វើឲ្យខ្ញុំនឹកឃើញអំពីស្ថានភាពស្រដៀងគ្នាទៅនឹងប្រទេសកម្ពុជា នៅពេលដែលសហគមន៍អន្តរជាតិបានអនុញ្ញាតឲ្យខ្មែរក្រហមធ្វើជាតំណាងប្រជាជនកម្ពុជាបណ្តោះអាសន្ននៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ។ សេចក្តីព្យាយាមក្នុងការបកស្រាយពីភាពចាំបាច់ក្នុងការសហការជាមួយរបបភេរវកម្មដើម្បីគោលបំណងឈានទៅមុខគួរតែត្រូវបានវាយតម្លៃដោយប្រិតប្រៀងថា តើគោលដៅអភិវឌ្ឍន៍មនុស្សនឹងត្រូវលះបង់ក្នុងកម្រិតណាខ្លះសម្រាប់បំពេញតម្រូវការនយោបាយឬសន្តិសុខ? តើយើងអាចទទួលយកភាពសាហាវឃោរឃៅប៉ុន្មានដងទៀតដើម្បីភាពចាំបាច់នៃស្ថានភាពនយោបាយ? ហើយថាតើការទទួលស្គាល់នៃរបបភេរវកម្ម ឬរបបដែលបង្កើតឡើងដោយភេរវកម្មអាចកាត់បន្ថយភាពជឿជាក់ និងសុចរិតភាពរបស់សហគមន៍ពិភពលោកដែលផ្តល់សារសំខាន់ដល់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យយ៉ាងដូចម្តេចខ្លះ?

ប៉ុន្តែនៅមានក្តីសង្ឃឹមមួយបានកើតឡើងបន្ទាប់ពីគ្រោះមហន្តរាយដែលគ្របដណ្តប់លើប្រទេសកម្ពុជានៅក្រោមរបបខ្មែរក្រហម គឺជាក្តីសង្ឃឹមនេះហើយដែលកើតឡើងនៅក្នុងប្រទេសអាហ្វហ្កានីស្ថាន។ នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ខ្មែរក្រហមបានប្រព្រឹត្តអំពើសាហាវឃោរឃៅដែលមិនអាចបរិយាយបាន។ មេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តរបបភេរវកម្មដែលជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមហេតុផលដើម្បីពង្រឹងមនោគមវិជ្ជាកុម្មុយនីស្តទទេមួយ ដែលត្រូវបានបង្កើតឡើងនៅលើទស្សនៈខុស

ឆ្គងនៃសង្គមនិយមមហាលោតផ្លោះ មហាអស្ចារ្យ។ ថ្វីត្បិតតែខ្ញុំបានឃើញភាពភ័យរន្ធត់ដោយផ្ទាល់ និងជួបប្រទះការបាត់បង់យ៉ាងណាក្តី ក៏ខ្ញុំមិនមានការអាក់អន់ស្រពោនចិត្ត ឬមានអារម្មណ៍ថា ត្រូវបានបោះបង់ចោលដែរ។ ត្រឹមតែជាក្មេងវ័យជំទង់មួយរូប ខ្ញុំគ្រាន់តែយល់ថា សហរដ្ឋអាមេរិកគឺជាទឹកដីដែលបំណងប្រាថ្នាអាចកើតឡើង ហើយក្តីសង្ឃឹមនេះហើយដែលជួយខ្ញុំ និងអ្នករស់រានមានជីវិតជាច្រើននាក់ទៀតមានជីវិតបន្តរស់នៅ។

ការក្រោកឈរឡើងវិញរបស់តាលីបង់ និងការដួលរលំនៃរដ្ឋអាហ្វហ្គានីស្ថានចាំបាច់បង្ខំឲ្យមានការសិក្សាឡើងវិញទៅលើគោលនយោបាយការបរទេសសហរដ្ឋអាមេរិក និងការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិចំពោះគោលដៅអភិវឌ្ឍន៍មនុស្ស ប៉ុន្តែគឺជារឿងខុសឆ្គងក្នុងការមើលកាលៈទេសៈទាំងនេះថាជាការរាំងស្ទះដល់ឱកាសរបស់សហរដ្ឋអាមេរិក និងសហគមន៍អន្តរជាតិដើម្បីជះឥទ្ធិពលទៅលើប្រទេសអាហ្វហ្គានីស្ថានដែលគ្រប់គ្រងដោយតាលីបង់។ ស្របគ្នាជាមួយនឹងរូបភាពឧទ្ធម្ភាគចក្រនៅលើដំបូលអគារ ភាពវឹកវរនៅតាមដងផ្លូវ និងការបំផ្ទុះគ្រាប់បែកអត្តឃាតដែលសម្លាប់ជនជាតិអាហ្វហ្គានីស្ថានស្លូតត្រង់ និងទាហានអាមេរិកក៏មានរូបភាពវិជ្ជមានជាច្រើននៃវីរភាព ការតស៊ូ និងក្តីសង្ឃឹម។

អនាគតរបស់ប្រទេសអាហ្វហ្គានីស្ថាននឹងមិនត្រូវបានកំណត់ដោយការបោះបង់ចោល និងការអាក់អន់ស្រពោនចិត្តនោះទេ ប៉ុន្តែគឺវីរភាព ការតស៊ូ និងក្តីសង្ឃឹម។ ដូចជាប្រទេសកម្ពុជាដែរ អនាគតរបស់ប្រទេសអាហ្វហ្គានីស្ថានគឺស្ថិតនៅក្នុងក្តីសង្ឃឹម និងក្តីសុបិន្តបំណងប្រាថ្នារបស់យុវជន ហើយគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក និងយុទ្ធសាស្ត្ររបស់សហគមន៍អន្តរជាតិក្នុងការដោះស្រាយជាមួយប្រទេសអាហ្វហ្គានីស្ថានគួរតែរួមបញ្ចូលយុវជនអាហ្វហ្គានីស្ថាននៅក្នុងផែនការរយៈពេលវែងរបស់ខ្លួន។

គួរកត់សម្គាល់ថា សំឡេងយុវជនអាហ្វហ្គានីស្ថានមិនមានភាពលេចធ្លោនៅក្នុងការផ្សព្វផ្សាយព័ត៌មានថ្មីៗនេះទេ ប្រសិនបើប្រៀបធៀបទៅនឹងចំនួនសមាមាត្ររបស់យុវជននៅក្នុងប្រទេសនេះ។ សំឡេងរបស់យុវជនអាហ្វហ្គានីស្ថានត្រូវបានគេកត់សម្គាល់ថា មិនមានច្រើននៅក្នុងការវិភាគស្តីពីអាហ្វហ្គានីស្ថានដែលផ្ទុយពីភាគរយដ៏លើសលប់របស់យុវជននៃចំនួនប្រជាជនសរុប។ ស្ទើរតែ ៧០ ភាគរយនៃជនជាតិអាហ្វហ្គានីស្ថានមានអាយុក្រោម២៥ឆ្នាំ ប៉ុន្តែសំឡេងភាគច្រើនដែលពុះចេញពីអាហ្វហ្គានីស្ថានគឺមកពីអតីតមន្ត្រីរដ្ឋាភិបាល និងជនភៀសខ្លួនមានវ័យចំណាស់។ ជាការពិតណាស់ជនជាតិអាហ្វហ្គានីស្ថានដែលមានវ័យចំណាស់ គឺចាំបាច់ជាប្រជាជនដែលមានសារសំខាន់ក្នុងការសិក្សាអំពីអ្វីដែលបានកើតឡើង និងភាពខុសឆ្គងនៃការចាកចេញរបស់សហរដ្ឋអាមេរិក និងសហគមន៍អន្តរជាតិពីប្រទេសអាហ្វហ្គានីស្ថាន ក៏ប៉ុន្តែគឺជាយុវជនអាហ្វហ្គានីស្ថាននោះទេដែលមានសារសំខាន់បំផុតចំពោះចម្លើយ នាពេលអនាគតលើសំណួរថា តើនឹងមានអ្វីកើតឡើងបន្ទាប់ពីនេះ។ ប្រហែលជាគ្មានក្រុមប្រជាជនណាដែលសំខាន់ចំពោះអនាគតរបស់ប្រទេសអាហ្វហ្គានីស្ថានជាងក្រុមយុវជននោះទេ ហើយគ្មានពេលណាដែលប្រសើរជាងនៅពេលនេះដើម្បីចាប់ផ្តើមគិតអំពីវិធីធ្វើយ៉ាងណាដើម្បីរាប់បញ្ចូលក្រុមយុវជននោះឡើយ។

ប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក និងសហគមន៍អន្តរជាតិនៅប្រទេសកម្ពុជាមិនមែនជាផែនទីបង្ហាញផ្លូវ ឬមគ្គុទេសក៍ណែនាំសម្រាប់ប្រទេសអាហ្វហ្គានីស្ថាននោះទេ ប៉ុន្តែគឺជាចំណុចយោងមួយដែលផ្តល់នូវការយល់ដឹង និងការរំឭកសំខាន់ៗដែលអាចបង្ហាញអំពីវិធីសាស្ត្រ និងគោលនយោបាយនាពេលអនាគត។ ថ្វីត្បិតតែមានសោកនាដកម្មកើតឡើងនៅប្រទេសអាហ្វហ្គានីស្ថាន ក៏ប៉ុន្តែនៅតែមានក្តីសង្ឃឹម ហើយយើងត្រូវចាប់ផ្តើមគិតអំពីវិធីសាស្ត្រដើម្បីបង្កើនក្តីសង្ឃឹមនេះ និងកសាងអនាគតប្រទេសអាហ្វហ្គានីស្ថានមិនត្រឹមតែសម្រាប់ប្រជាជនអាហ្វហ្គានីស្ថានប៉ុណ្ណោះទេ ប៉ុន្តែគឺការប្តេជ្ញាចិត្តរបស់យើងចំពោះមនុស្សជាតិ និងសន្តិសុខពិភពលោកនាពេលអនាគត។

អត្ថបទនេះចុះផ្សាយជាភាសាអង់គ្លេសនៅទស្សនាវដ្តីការទូត (The Diplomat) និងបកប្រែមកជាភាសាខ្មែរដោយ សូវិចិត្រ មេត្តា ដែលជានិស្សិតអនុបណ្ឌិតផ្នែករដ្ឋបាលសង្គមស៊ីវិល នៅប្រទេសកូរ៉េខាងត្បូង។

# កងទ័ពវៀតណាម ប៊ួយ ហុងវ៉េ ៖ ពលបាលផ្កាយបីកងរថក្រោះ វរសេនាធំលេខ២៦

***ដារ៉ារដ្ឋ មេត្តា***



*រថក្រោះ និងយោធាខ្មែរក្រហមនៅលើ សមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ប៊ួយ ហុងវ៉េ អាយុ២៧ឆ្នាំ នៅក្នុងឆ្នាំ១៩៧៨។ ខ្ញុំមាននាទីជាពលបាលផ្កាយបី អនុប្រធាន អនុសេនាតូចលេខ២ អនុសេនាធំលេខ៣ វរសេនាតូចលេខ២១ វរសេនាធំលេខ២៦។ ខ្ញុំមានស្រុកកំណើតនៅដុងបុង ឃុំហាទៀន ស្រុកហាត្រុង ខេត្តថាញ់វ៉ា ភាគខាងជើងនៃប្រទេសវៀតណាម។ នៅឆ្នាំ១៩៧២ បក្សកុម្មុយនីស្តវៀតណាម ចាប់បង្ខំខ្ញុំឲ្យធ្វើជាទាហាន។ ខ្ញុំមិនចង់ធ្វើទាហានទេ ខ្ញុំចង់នៅជួយការងារឪពុកម្តាយដែលកំពុងមានជីវភាពលំបាក។ បក្សកុម្មុយនីស្តវៀតណាមចាប់ខ្ញុំរួចបញ្ជូនខ្ញុំទៅនៅកងរថក្រោះ។ ក្រោយមកបក្សកុម្មុយនីស្តវៀតណាមបញ្ជូនខ្ញុំឲ្យទៅរៀននៅសាលារថក្រោះវិញភូ គឺជាសាលារថក្រោះមួយដែលល្បីល្បាញជាងគេនៅក្នុងប្រទេសវៀតណាម។ ខ្ញុំចាំទ្រឹស្តីនៅសាលារថក្រោះនិយាយថា រថក្រោះ គឺជាអាវុធវាយលុកមួយបែបដែលមានប្រសិទ្ធភាពបំផុត។ បក្សកុម្មុយនីស្តវៀតណាមតែងតែអួតសរសើរអំពីរថក្រោះធុនតេ៥៤ របស់ប្រទេសសូវៀត។ បក្សកុម្មុយនីស្តវៀតណាម ហាមមិនឲ្យបង្រៀនយុទ្ធជនអំពីចំណុចខ្សោយរបស់រថក្រោះតេ៥៤ទេ ប៉ុន្តែគ្រូខ្ញុំម្នាក់លួចប្រាប់ខ្ញុំអំពីរថក្រោះតេ៥៤

មានចំណុចខ្សោយជាច្រើន។ គ្រូរបស់ខ្ញុំប្រាប់ថា ប្រសិនបើខ្មាំងបាញ់គ្រាប់កាំភ្លើងត្រូវចំហៀងផ្នែកខាងស្តាំច្រើនពេក វានឹងធ្វើឲ្យក្តៅធុងសាំងអាចឆេះរថក្រោះ ហើយត្រូវមានស្មារតីប្រុងប្រយ័ត្នសត្រូវផ្តុំបាញ់យើង បាញ់ដាច់ច្រវាក់ និងបរចំមីនដែលកប់ក្នុងដី។ រយៈពេលមួយឆ្នាំចុងក្រោយនេះ មានរថក្រោះតេ៥៤ថ្មីៗ ដែលប្រទេសសូវៀតទើបតែផ្តល់ឲ្យវៀតណាម។ ក្នុងពេលដែលសូវៀតកំពុងតែផ្តល់រថក្រោះមកជាបន្តបន្ទាប់ នាយទាហានជំនិតៗរបស់បក្សកុម្មុនីស្តវៀតណាមនិយាយដដែលថា បើយើងចុះសន្ធិសញ្ញាយោធាជាមួយនឹងសូវៀត សូវៀតនឹងផ្តល់កៅស៊ូគម្របម៉ាស៊ីន និងពោងមុជទឹកមក ទើបរថក្រោះតេ៥៤ មានគ្រឿងបន្ទាស់គ្រប់ ដែលអាចមុជទឹកជម្រៅបានពីរ ទៅបីម៉ែត្រ។ សូវៀតអាចនឹងជួយផ្តល់រថក្រោះធុនតេ៧៦ មកទៀត រថក្រោះនេះមានអនុភាពកាន់តែខ្លាំងក្លា។

សភាពការណ៍នយោបាយ សតិអារម្មណ៍របស់កងរថក្រោះ មានបែងចេញជា៣ផ្នែកគឺ ទី១) មានគ្នាតិចបំផុតដែលជាផ្នែកដឹតបន្ទំខ្លួន ទី២) កងរថក្រោះគឺមិនពេញចិត្តនឹងរបបរបស់បក្សកុម្មុយនីស្តវៀតណាមជិះជាន់ប្រជាជន និងឪពុកម្តាយយុទ្ធជន។ បក្សកុម្មុយនីស្តវៀតណាម វាយបង្ខំឲ្យយុទ្ធជនមកធ្វើសង្គ្រាមស្លាប់ចោលឆ្អឹងនៅកម្ពុជា។ ទី៣) អ្នកដែលប្រឆាំងជាប់លាប់ជាខ្សែសង្ងាត់ ដោយរថក្រោះឈប់នៅកន្លែងណា តែងត្រូវខ្មាំងលួចបំផ្លាញជាប្រចាំ។

ចំណែកនៅមូលដ្ឋានវិញមានប្រជាជនក្រោកឡើងតស៊ូច្រើនណាស់ មានបាចខិតប័ណ្ណ បាតុកម្មកើតមានឡើងកាន់តែញឹកញាប់។ ប្រជាជនរត់ចូលព្រៃកាន់អាវុធតស៊ូប្រឆាំង កាន់តែច្រើនឡើង។ ចលនាតស៊ូរបស់ប្រជាជនគគ្រឹកគគ្រេង ចាប់តាំងពីខេត្តការវបាក់ ឡាង រហូតដល់ជ្រោយកាម៉ៅ។ ប្រជាជនមានមូលដ្ឋានបង្អែក តំបន់ឈ្លប កងឈ្លបរបស់ប្រជាជនគ្រប់គ្រាន់។ ការបរាជ័យរបស់កងទ័ពវៀតណាមនៅក្នុងប្រទេសកម្ពុជា នៅខែមករា ឆ្នាំ១៩៧៨ ជាកត្តាជំរុញខាងផ្លូវចិត្តមានមហិច្ឆិតាចំពោះការតស៊ូនេះឲ្យរឹតតែខ្លាំងក្លាណាស់ដែរ។



រថក្រោះ និងយោធាខ្មែរក្រហមនៅលើ សមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បក្សកុម្មុយនីស្តវៀតណាម ពឹងផ្អែកទៅលើតែសព្វាវុធទំនើបរបស់សូវៀត។ នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៧៨ វរសេនាធំ ខ្ញុំមានសភាពការណ៍កើតឡើងផ្ទុយស្រឡះ ដោយកម្មាភិបាលជំនិតៗរបស់វៀតណាមគិតតែសប្បាយ។ ទាហានទាំងអស់ព្រួយបារម្ភសោកស្តាយឈឺចាប់ចងកំហឹងជាមួយបក្សកុម្មុយនីស្តវៀតណាម។ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ដៃដើងជំនិតវៀតណាមបាននិយាយថា សភាពការណ៍វៀតណាមល្អប្រសើរណាស់ វៀតណាមប្រមូលផ្តុំកងទ័ពបានជាង១០កងពល នៅតាមបណ្តោយព្រំប្រទល់ប្រទេសកម្ពុជា។ វៀតណាមអាចដោះស្រាយបញ្ហាស្បៀងបានមួយកម្រិត ដោយបក្សសន្សំស្បៀងជំនួយបរទេសចំពោះទឹកជំនន់ ហើយតាមរយៈសន្ធិសញ្ញា សូវៀតនឹងជួយឲ្យមេស្រាមី និងស្រូវសាលីមកទៀត។ ស្រូវសាលី ទោះជាយ៉ាងណាមានរសជាតិឆ្ងាញ់ជាងកន្ទក់ដែរ។ បើយើងខំវាយយកប្រទេសកម្ពុជា គឺយើងយកអង្ករ ជ្រូក មាន់ ទា ត្រីសាច់ បន្លែបង្ការ។ កន្លងមកយើងខ្វះអាវុធទំនើបៗ ឥឡូវនេះសូវៀតនឹងផ្តល់មកច្រើនជាងមុន។ យើងកុំអស់សង្ឃឹម កុំអាលប្រឡំថា កងទ័ពវៀតណាមយើងចាញ់។

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ឈ្មោះ គ្រីន វ៉ាន់យិក វរសេនីយ៍ផ្កាយពីរ ប្រធានវរសេនាធំ កងរថក្រោះលេខ២៦ ចេញបញ្ជាឲ្យខ្ញុំចេញរថក្រោះមួយអនុសេនាធំចូលប្រទេសកម្ពុជា។ រថក្រោះធុនគេ ៥៤ ចំនួន៣គ្រឿងគឺលេខ៧០៥ លេខ៨០៦ និងលេខ ៣៦៥។ ខ្ញុំនៅចាំគ្រូបង្រៀនខ្ញុំឲ្យជៀសវាងចំណុចខ្សោយទាំងប៉ុន្មានដែលខ្ញុំបានរៀនក្រែងលោគង់ជីវិតត្រឡប់មកមាតុប្រទេសវិញ។ ពេលចូលដល់ទឹកដីប្រទេសកម្ពុជាបានមួយស្ទុះ ខ្ញុំឃើញកន្លែងកប់មីន ខ្ញុំបញ្ជាឲ្យបត់រថក្រោះទៅស្តាំគេចចេញពីមីនកប់ក្នុងដីបណ្តាលឲ្យរថក្រោះធ្លាក់រណ្តៅចម្រូង ផ្សៀងកល់មិនអាចបាញ់គ្រាប់បាន។ ខ្ញុំឲ្យសមាជិកក្រុមអើតក្បាលមើលក្តាប់សភាពការណ៍ ស្រាប់តែស្នា ហើយប្រវ៉ាត់មកត្រូវស្លាប់ទាំងពីរនាក់។ ខ្ញុំកាន់តែភ័យ ខ្ញុំទាក់ទងទៅទីបញ្ជាការ។ បញ្ជាការប្រាប់ថា នឹងឲ្យកាំភ្លើងធំមកជួយ។ បក្សកុម្មុយនីស្តឲ្យខ្ញុំប្រាប់ទីតាំងហើយប្រាប់ថា កងថ្មើរជើងជិតមកដល់ដែរ។ ខ្ញុំស្មានតែជិតមកដល់មែន ទើបខ្ញុំរង់ចាំ។ ខ្ញុំចាំបាត់ៗ ខ្ញុំចេះតែសួរទៀត ហើយមេឃកាន់តែងងឹត។ ខ្ញុំសួរម្តងទៀតបក្សប្រាប់ថាឲ្យខ្ញុំខំប្រឹងតាំងស្មារតី កុំភ័យ ប៉ុន្តែខ្ញុំភ័យផង និងខឹងផង។ រថក្រោះរបស់ខ្ញុំពីរទៀតខូច ៧០៥ និង ៣៦៥ សុទ្ធតែជួបគ្រោះអាសន្នដែលមិនបានព្រាងទុកដូចគ្នា។

នៅវេលាម៉ោង៩យប់ មេឃងងឹត ខ្ញុំខំប្រឹងគេចខ្លួន ដោយខ្ញុំភ្លេចទាំងកាំភ្លើងអាការ និងមិនហ៊ានត្រឡប់មកយកទេ។ ខ្ញុំខំប្រឹងលូន ប៉ុន្តែខ្ញុំលូនមិនបានចម្ងាយ១២០ម៉ែត្រពីរថក្រោះផង កងឈ្លបកម្ពុជាឡោមព័ទ្ធចាប់ខ្ញុំ។ ខ្ញុំត្រូវចាប់ខ្លួនបាននៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៨ នៅសមរភូមិស្នួល ខេត្តក្រចេះ។

**កំណត់ចំណាំ ៖ អត្ថបទនេះ ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D07132 ។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ប៊ួយ ហុង វ៉ា ពិតប្ញយ៉ាងណានោះទេ។**



រថក្រោះរបស់ខ្មែរក្រហម។ ខែសីហា ឆ្នាំ១៩៧៨។
(ហ្គុនណា ប៊ីយស្រ្តុម/មជ្ឈមណ្ឌលឯកសារកម្ពុជា

# ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិកប្រកាស
## អំពីហិរញ្ញប្បទានថ្មី ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាព របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*សោម ប៊ុនថន*




ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា W. Patrick Murphy ចូលរួមកម្មវិធីប្រកាសផ្តល់ហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់៥លានដុល្លារសហរដ្ឋអាមេរិក ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការងារលើគម្រោង "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" ដែលត្រូវបានរៀបចំឡើងនៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រកាសអំពីហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់៥លានដុល្លារសហរដ្ឋអាមេរិក ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមរយៈគម្រោងដែលមានឈ្មោះថា "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហិរញ្ញប្បទានបន្ថែមនេះ នឹងធ្វើឲ្យសកម្មភាពប្រតិបត្តិការមានតម្លៃសរុបចំនួន ៦,៥ លានដុល្លារសហរដ្ឋអាមេរិក។

មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងចំណាយប្រាក់ចំនួន ៥ លានដុល្លារសហរដ្ឋអាមេរិក នៃទឹកប្រាក់សរុបចំនួន ៦ លាន៥សែនដុល្លារសហរដ្ឋអាមេរិក ក្នុងជំហានបឋម របស់ខ្លួននៅក្នុងឆ្នាំ២០២១ ដើម្បីលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើង នូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

កម្មវត្ថុនៃការចំណាយនេះ គឺដើម្បីធ្វើឲ្យប្រសើរឡើង នូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ ១) សំដៅទៅដល់ការលើកកម្ពស់ នៃការយល់ដឹងអំពីសុខភាពសាធារណៈ និង ២) ទទួលបានសេវាកម្មសុខភាពសាធារណៈ។ ទន្ទឹមនឹងនេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា សិក្សាស្រាវជ្រាវអំពីស្ថានភាព របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅតាមសហគមន៍ដាច់ស្រយាល សម្រាប់ជាព័ត៌មានមូលដ្ឋាន ក្នុងការរៀបចំជំនួយអភិវឌ្ឍន៍ នាពេលអនាគត ដល់ប្រជាជនក្នុងសហគមន៍ទាំងនេះ។

សកម្មភាពថ្មីនេះ គឺជាកេរដំណែលមួយនៅក្រោយពេលដែលតុលាការបានបញ្ចប់ទៅ ក៏ដូចជា ការចូលរួមដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាដែល ទាក់ទងជាមួយ នឹងសុខភាពសាធារណៈ ហើយនឹងបន្តអនុវត្ត ៣ ការពារ និង ៣ កុំ ដែលជាសេចក្តីណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។

ឯកអគ្គរដ្ឋទូតអាមេរិក W. Patrick Murphy បានថ្លែងថា៖ “យើងមានមោទកភាព ក្នុងការគាំទ្រដល់គម្រោងនេះ។ រដ្ឋាភិបាលសហរដ្ឋអាមេរិក មានសេចក្តីប្តេជ្ញាយូរអង្វែងក្នុងការលើកកម្ពស់សន្តិភាពនិងការផ្សះផ្សាជាតិ តាមរយៈការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម” គម្រោងនេះនឹងផ្តល់ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនូវការប្រើប្រាស់សេវាថែទាំសុខភាពដែលសម្រួលដល់ស្ថានភាពជំងឺទូទៅ ក្តីព្រួយបារម្ភ ស្ថានភាពសង្គមសេដ្ឋកិច្ច និងបទពិសោធន៍ពេលឆ្លងកាត់របបខ្មែរក្រហម។”

ការងារថ្មីមួយនេះ នឹងធ្វើការសិក្សាស្រាវជ្រាវផ្ទាល់ អំពីស្ថានភាពសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបន្ទាប់មក ធ្វើការប្រែក្លាយលទ្ធផលរកឃើញឲ្យទៅជាយុទ្ធនាការបង្កើនការយល់ដឹងរបស់សាធារណជន។ គម្រោងនេះនឹងធ្វើប្រតិបត្តិការនានាដើម្បីធ្វើឲ្យប្រសើរឡើងនូវសុខភាព សុខុមាលភាពនិងភាពសុខស្រួល របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេស។

អ្នកស្រី សូ ហ្វារីណា នាយិការង មជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នកគ្រប់គ្រងគម្រោងនេះ រំពឹងថា៖ ការទទួលបានសេវាកម្មថែទាំសុខភាព និងសង្គមកិច្ចមួយចំនួនសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសក្រុមជនជាតិភាគតិច ដែលរស់នៅតាមតំបន់ដាច់ស្រយាល នាកាលៈទេសៈដ៏លំបាកក្នុងការប្រឆាំងនឹងជំងឺរាតត្បាតកូវីដ ១៩ សព្វថ្ងៃនេះ គឺជាការសំខាន់ខ្លាំងណាស់។

លោក ឆាំង យុ នាយកប្រតិបត្តិមជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកឡើងថា “សោកនាដកម្ម និងភាពអយុត្តិធម៌ ដែលប្រជាជនកម្ពុជាទទួលរងនៅក្នុងរបបខ្មែរក្រហម មានទំហំមហាសាលដែលគ្មានអ្វីអាចជំនួសបាន ឬប៉ះប៉ូវជូនអ្នកទាំងអស់បានទេ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងមួយនេះ គឺជាជំហានឆ្ពោះទៅសម្រេចបានការថែទាំ និងគាំពារដល់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម” ហិរញ្ញប្បទានពិសេស នេះរួមបញ្ចូលនូវអ្នកស្ម័គ្រចិត្តប្រកបដោយភាពមោះមុតចំនួន ៥០០ នាក់ ដែលបំពេញការងារនៅទូទាំងប្រទេស ក្នុងការជួយនាំអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិឋានរបស់ខ្លួនទៅមន្ទីរសុខភាពក្នុងសហគមន៍។ តាមរយៈការងារស្ម័គ្រចិត្តនេះ យុវជន-យុវនារីទទួលបានឱកាសបង្ហាញចេញនូវភាពជាអ្នកដឹកនាំ រួមជាមួយនឹងការបំពេញការងារដោយមិនគិតពីប្រយោជន៍



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (រូបទី១រាប់ពីស្តាំ) ចូលរួមកម្មវិធីទទួលហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់៥លានដុល្លារសហរដ្ឋអាមេរិក ពីទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក ដែលត្រូវបានរៀបចំឡើងនៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្ទាល់ខ្លួន ដើម្បីគាំពារដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាចំពោះប្រជាជាតិកម្ពុជា។ ទន្ទឹមនឹងនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានឱកាសចែករំលែករឿងរ៉ាវឆ្លងកាត់ផ្ទាល់ខ្លួននៅក្នុងអំឡុងរបបខ្មែរក្រហម ទៅកាន់ក្មេងជំនាន់ក្រោយ ដើម្បីធានាថាយើងនៅតែចងចាំ ពេលវេលាដ៏លំបាកយ៉ាងខ្លាំងមួយនោះ។ ជារួម គម្រោងនេះនឹងរំលេចនូវចរិកមនុស្សធម៌របស់យើង និងពង្រឹងបន្ថែមនូវស្មារតីមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជា។”

ឧទាហរណ៍ខ្លះៗនៃផែនការសកម្មភាពថ្មីទាំងនេះ រួមមាន ការបង្កើតជាអាហារូបករណ៍ក្នុងចំនួនកំណត់ សម្រាប់សិស្សសិក្សាផ្នែកវេជ្ជសាស្ត្រ សុខភាពផ្លូវចិត្ត សុខភាពសាធារណៈ និងសុខភាពបឋម។ សកម្មភាពខាងលើថែមទាំងផ្តើមផងដែរនូវសកម្មភាពស្ម័គ្រចិត្តប្រតិបត្តិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលគាំពារដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជារួមមានវេជ្ជបណ្ឌិត ដេមី រេយស៍ និង គីម សុវណ្ណដានី បានចុះសួរសុខទុក្ខតាមមូលដ្ឋាន និងផ្តល់សេវាថែទាំសុខភាពបឋម ជូនដល់អតីតអ្នកដាក់ពាក្យបណ្តឹង ដើមបណ្តឹងរដ្ឋប្បវេណីរបស់សាលាក្តីខ្មែរក្រហម នៅឯវត្តលលកសថ្មី ស្ថិតក្នុងខេត្តពោធិ៍សាត់ និងបណ្តាខេត្តដទៃទៀត ចាប់តាំងពីឆ្នាំ២០១៧ មកម៉្លេះ។ ការចុះសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមមូលដ្ឋាន គឺជាផ្នែកមួយ នៃការផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលឈានទៅដល់ការចំណាយទឹកប្រាក់ ៥ លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០២១ នេះ ដើម្បីសិក្សាអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដោយផ្តោតលើការអប់រំ ពិគ្រោះយោបល់អំពីបញ្ហាសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេស

កម្ពុជា និងតាមរយៈការប្រើប្រាស់វេទិកាសុខភាពចល័តខ្នាតតូច ដែលឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុគ្រោះពន្ធឲ្យនាំចូលវេទិកានេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អាចបន្តចែករំលែកបទពិសោធន៍ជីវិតរបស់ខ្លួនក្នុងរបបខ្មែរក្រហមទៅកាន់មនុស្សជំនាន់ក្រោយរបស់ប្រទេសកម្ពុជា និងនៅលើពិភពលោក។ ការចែករំលែកបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហម គឺជាការគាំទ្រដល់ការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដើម្បីទប់ស្កាត់នូវអំពើឧក្រិដ្ឋកម្មអមនុស្សធម៌នានា មិនឲ្យកើតឡើងជាថ្មីម្តងទៀតនៅក្នុងប្រទេស និងក្នុងតំបន់ផ្សេងទៀតផងដែរ។



អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅខេត្តពោធិ៍សាត់ កំពុងធ្វើការងារលើគម្រោង “ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម” ។ (អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅខេត្តពោធិ៍សាត់)

តាមរយៈការសិក្សាស្រាវជ្រាវជាបឋមបានឃើញថា មួយចំនួននៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងចំណោម២០០០នាក់ តែងពើបប្រទះនូវជំងឺប្រហាក់ប្រហែលគ្នា ចំនួន ៥ប្រភេទរួមមាន៖ ១) ជំងឺលើសឈាម ២) ជំងឺបេះដូង ៣) ជំងឺទឹកនោមផ្អែម ៤) ជំងឺស្ទះផ្លូវដង្ហើមរ៉ាំរ៉ៃ និងជំងឺរបេងសួត និង ៥) ជំងឺមហារីកសុដន។

នៅក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំទៅនៅថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំងអស់បានខិតខំកសាងប្រទេសពីបាតដៃទទេរ ហូតមកដល់សព្វថ្ងៃនេះ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មានប្រសាសន៍បន្ថែមថា៖ «ទំហំនៃការបាត់បង់របស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហមគឺធំធេងណាស់ ដែលគ្មានអ្វីក្នុងលោកនេះ អាចមកជំនួសឬសំណងបានឡើយ។ ការងារខាងលើនេះ គឺជាការខិតខំទៅតាមសមត្ថភាពដែលយើងអាចធ្វើបានដល់អ្នកដែលបានស្លាប់ទៅ និងអ្នកដែលកំពុងរស់នៅក្នុងវ័យជរា ឬពិការ ហើយមានជីវភាពលំបាកឯតំបន់ដាច់ស្រយាលមួយចំនួន»។

មជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមចំណែកលើកិច្ចការនេះដើម្បីធ្វើយ៉ាងណាឲ្យវិស័យសុខភាពសាធារណៈ នៅក្នុងប្រទេសកម្ពុជាមានភាពកាន់តែប្រសើរឡើង និងជាទីទុកចិត្តដល់ប្រជាជនកម្ពុជាគ្រប់ៗរូប។

# កិច្ចសហការរវាងសកលវិទ្យាល័យស្តែនហ្វត និងមជ្ឈមណ្ឌលឯកសារកម្ពុជា លើគម្រោងសុខភាព

**អ៊ុន សុជាទី**




*Daryn Reicherter ថ្លែងទៅកាន់អង្គប្រជុំនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅ ទីក្រុងញូវយ៉ក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

«កម្មវិធីសិទ្ធិមនុស្ស និងសុខភាពផ្លូវចិត្ត របស់សកលវិទ្យាល័យស្តែនហ្វត នៃសហរដ្ឋអាមេរិកមានសេចក្តីសោមនស្សរីករាយក្នុងកិច្ចសហការណ៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងនាមជាអ្នកផ្តល់ប្រឹក្សាក្នុង គម្រោង **ការលើកកម្ពស់សិទ្ធិ និងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម**។ កម្មវិធីសិទ្ធិមនុស្សនិងសុខភាពផ្លូវចិត្តរបស់សកលវិទ្យាល័យស្តែនហ្វតនឹងផ្តល់ការប្រឹក្សាការណែនាំដល់ មជ្ឈមណ្ឌលឯកសារកម្ពុជា លើការបង្កើតវិធីសាស្ត្រដែលមានប្រសិទ្ធភាព សម្រាប់ផ្សព្វផ្សាយព័ត៌មានលើផ្នែកសុខភាពផ្លូវចិត្ត និងការថែទាំសុខភាពទូទៅដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ កម្មវិធីសិទ្ធិមនុស្ស និងសុខភាពរបួសផ្លូវចិត្តនេះនឹងផ្តល់ការណែនាំក្នុងដំណាក់កាលនៃការរៀបចំផែនការ និងធ្វើការឆ្ពោះទៅរកការផ្សព្វផ្សាយព័ត៌មានដែលមានប្រសិទ្ធភាពខ្ពស់។ លើសពីនេះទៅទៀតកម្មវិធីសិទ្ធិមនុស្ស និងសុខភាពផ្លូវចិត្តរបស់សកលវិទ្យាល័យស្តែនហ្វតនឹងផ្តល់ការណែនាំការប្រឹក្សាជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លើការបង្កើត ប្រព័ន្ធផ្សព្វផ្សាយចម្រុះ រួមមាន អត្ថបទកម្មវិធីផ្សព្វផ្សាយសំឡេង វីដេអូអប់រំ និងសម្ភារសម្រាប់ផ្សព្វផ្សាយ ផ្សេងៗទៀតលើប្រធានបទនៃ

បញ្ហាសុខភាពផ្លូវចិត្ត និងសុខភាពទូទៅដែលកើតមានឡើងលើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីផ្សព្វផ្សាយ និងចែកជូនដល់អ្នករស់រានមានជីវិត និងសាធារណជនទូទៅ។ ការសហការរវាង



រូបរាប់ពីស្តាំ៖ Jessie Bruner, Beth van Schaack, DarynReicherter នៅសាកលវិទ្យាល័យកូឡុំប៊ី ទីក្រុងញូវយ៉កៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ការប្រជុំស្តីអំពីកម្មវិធីសុខភាពផ្លូវចិត្តនៅសាកលវិទ្យាល័យស្ទែនហ្វដ រដ្ឋកាលីហ្វញ៉ា (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



Beth van Schaack, Daryn Reicherter នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ទីក្រុងឡាអេ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា និងសាកលវិទ្យាល័យស្ទែនហ្វត គឺប្រើប្រាស់វិធីសាស្ត្រចម្រុះ និងការបង្កើតថ្មី ធ្វើយ៉ាងណាដើម្បីឲ្យធនធានព័ត៌មានសំខាន់ៗបានទៅដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាក្រុមមនុស្សងាយទទួលការរងគ្រោះជាងគេក្នុងប្រទេសកម្ពុជា»។

# ឯកអគ្គរដ្ឋទូតអាមេរិក ផាទ្រិក ម័រហ្វី

## ចូលរួមកម្មវិធីប្រកាសអំពីហិរញ្ញប្បទានថ្មី ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*សោម ប៊ុនថន*




ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា W. Patrick Murphy ចូលរួមកម្មវិធីប្រកាសផ្ដល់ហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់៥លានដុល្លារសហរដ្ឋអាមេរិក ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការងារលើគម្រោង "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" ដែលត្រូវបានរៀបចំឡើងនៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ទីភ្នាក់ងារផ្ដល់ជំនួយសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រកាសអំពីហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់៥លានដុល្លារសហរដ្ឋអាមេរិក ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមរយៈគម្រោងដែលមានឈ្មោះថា "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" ដែលនឹងត្រូវគ្រប់គ្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហិរញ្ញប្បទានបន្ថែមនេះ នឹងធ្វើឲ្យសកម្មភាពប្រតិបត្តិការមានតម្លៃសរុបចំនួន ៦,៥ លានដុល្លារសហរដ្ឋអាមេរិក។

ឯកអគ្គរដ្ឋទូតអាមេរិក W. Patrick Murphy បានថ្លែងថា៖ “យើងមានមោទនភាព ក្នុងការគាំទ្រដល់គម្រោងនេះ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកមានសេចក្តីប្តេជ្ញាយូរអង្វែងក្នុងការលើកកម្ពស់សន្តិភាពនិងការផ្សះផ្សាជាតិ តាមរយៈការចងចាំអំពីប្រវត្តិសាស្រ្តខ្មែរក្រហម” គម្រោងនេះនឹងផ្តល់ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនូវការប្រើប្រាស់សេវាថែទាំសុខភាពដែលសម្រួលដល់ស្ថានភាពជំងឺទូទៅ ក្តីព្រួយបារម្ភ ស្ថានភាពសង្គមសេដ្ឋកិច្ច និងបទពិសោធន៍ពេលឆ្លងកាត់ របបខ្មែរក្រហម។”

ការងារថ្មីមួយនេះនឹងធ្វើការសិក្សាស្រាវជ្រាវផ្ទាល់អំពីស្ថានភាពសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបន្ទាប់មក ធ្វើការប្រែក្លាយលទ្ធផលរកឃើញឲ្យទៅជាយុទ្ធនាការបង្កើនការយល់ដឹងរបស់សាធារណៈ។ គម្រោងនេះនឹងធ្វើប្រតិបត្តិការនានាដើម្បីធ្វើឲ្យប្រសើរឡើងនូវសុខភាពសុខុមាលភាពនិងភាពសុខស្រួល របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេស។

លោក ឆាំង យុ នាយកប្រតិបត្តិមជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកឡើងថា “សោកនាដកម្ម និងភាពអយុត្តិធម៌ ដែលប្រជាជនកម្ពុជាទទួលរងនៅក្នុងរបបខ្មែរក្រហម មានទំហំមហាសាលដែលគ្មានអ្វីអាចជំនួសបុប៉ះប៉ូវជូនអ្នកទាំងអស់បានទេ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងមួយនេះ គឺជាជំហានឆ្ពោះទៅសម្រេចបានការថែទាំ និងគាំពារដល់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម” ហិរញ្ញប្បទានពិសេស នេះ រួមបញ្ចូលនូវអ្នកស្ម័គ្រចិត្តប្រកបដោយភាពមោះមុតចំនួន ៥០០ នាក់ ដែលបំពេញការងារនៅទូទាំងប្រទេស ក្នុងការជួយនាំអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិឋានរបស់ខ្លួនទៅមន្ទីរសុខភាពក្នុងសហគមន៍។ តាមរយៈការងារស្ម័គ្រចិត្តនេះ យុវជន-យុវនារីទទួលបានឱកាសបង្ហាញចេញនូវភាពជាអ្នកដឹកនាំរួមជាមួយនឹងការបំពេញការងារដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីគាំពារដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាចំពោះប្រជាជាតិកម្ពុជា។ ទន្ទឹមនឹងនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានឱកាសចែករំលែករឿងរ៉ាវឆ្លងកាត់ផ្ទាល់ខ្លួននៅក្នុងអំឡុងរបបខ្មែរក្រហមទៅកាន់ក្មេងជំនាន់ក្រោយ ដើម្បីធានាថាយើងនៅតែចងចាំ ពេលវេលាដ៏លំបាកយ៉ាងខ្លាំងមួយនោះ។ ជារួម គម្រោងនេះនឹងរំលេចនូវចរិកមនុស្សធម៌របស់យើង និងពង្រឹងបន្ថែមនូវស្មារតីមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជា។”

ឧទាហរណ៍ខ្លះៗនៃផែនការសកម្មភាពថ្មីទាំងនេះរួមមាន ការបង្កើតជាអាហារូបករណ៍ក្នុងចំនួនកំណត់សម្រាប់សិស្ស សិក្សាផ្នែកវេជ្ជសាស្រ្ត សុខភាពផ្លូវចិត្ត សុខភាពសាធារណៈ និងសុខភាពបឋម។ សកម្មភាពខាងលើថែមទាំងផ្តើមផងដែរនូវសកម្មភាពស្ម័គ្រចិត្តប្រតិបត្តិដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលគាំពារដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។



ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា W. Patrick Murphy ទស្សនកិច្ចនៅបណ្ណាល័យសម្តេចម៉ែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## អំពីទីភ្នាក់ងារផ្តល់ជំនួយ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នៅទូទាំង២៥រាជធានី-ខេត្តក្នុងប្រទេសកម្ពុជា ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិកធ្វើការជាមួយដៃគូកម្ពុជា និងអន្តរជាតិ ដើម្បីអនុវត្តកម្មវិធីនានា ជាប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាទាំងអស់។ ការងាររបស់យើងផ្តោតទៅលើការពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស, ការធ្វើឲ្យប្រសើរឡើងនូវសុខភាពនិងអាហារូបត្ថម្ភ, ការទ្រទ្រង់ដល់ការអប់រំនិងការលូតលាស់របស់កុមារ, ការបង្កើនទិន្នផលកសិកម្ម និងសុវត្ថិភាពចំណីអាហារ, ការអភិរក្សព្រៃឈើនិងតំបន់វងទឹកភ្លៀង រួមជាមួយនឹងការជួយដល់កសិករ និងប្រជាជនក្នុងតំបន់ឲ្យអាចសម្របខ្លួននិងកាត់បន្ថយគ្រោះថ្នាក់ធម្មជាតិ។



ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា W. Patrick Murphy ចូលរួមកម្មវិធីប្រកាសផ្តល់ហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់៥លានដុល្លារសហរដ្ឋអាមេរិក ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការងារលើគម្រោង“ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម” ដែលត្រូវបានរៀបចំឡើងនៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## អំពីមជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតឡើងនៅឆ្នាំ១៩៩៥ បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តឲ្យមានច្បាប់ស្តីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ នៅក្នុងខែមេសា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាចូលជាធរមានដោយប្រធានាធិបតី ឃ្លីនតុន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលការកោតសរសើរនិងមេដាយជាច្រើន សម្រាប់កិច្ចការគាំទ្រឲ្យមានការចងចាំនិងយុត្តិធម៌ សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ក្នុងឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានពានរង្វាន់សិទ្ធិមនុស្ស ជូឌិត លី ស្រ្តូណាច់ ពីមជ្ឈមណ្ឌលយុត្តិធម៌និងការទទួលខុសត្រូវ។ នៅក្នុងឆ្នាំដដែល ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ដល់លោក ឆាំង យុ ជាការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ជាម្ចាស់ពានរង្វាន់រ៉ាម៉ុន ម៉ាកសៃសៃ ដែលត្រូវបានចាត់ទុកថាជាពានរង្វាន់ណូបែលអាស៊ី ក្នុងការថែរក្សាការចងចាំជាប្រវត្តិសាស្ត្រដើម្បីការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌។



ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា W. Patrick Murphy ទស្សនកិច្ចនៅបណ្ណាល័យសម្តេចម៉ែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ**
**នៃប្រទេសកម្ពុជា**

**ជូនលោក**
**ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**
**និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត**
**ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ**

ខ្ញុំសូមសម្តែងនូវអំណរគុណចំពោះលិខិតរបស់លោកចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០២១ ដែលផ្តល់ដំណឹងដល់ខ្ញុំថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលជំនួយ ទឹកប្រាក់សរុបចំនួន ៦លាន៥សែនដុល្លារសហរដ្ឋអាមេរិក ពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីគាំទ្រដល់គម្រោងថែទាំសុខភាព និងសេវាកម្មសង្គម សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានដឹងថាជំនួយនេះ ត្រូវបានបម្រុងទុកសម្រាប់ជួយដល់ប្រជាជនដែលមានវ័យជរា និងជនពិការដែលជាអ្នករស់រានមានជីវិតពីរបបដ៏ជូរចត់នៃប្រវត្តិសាស្ត្រជាតិយើង។

ខ្ញុំសូមសម្តែងនូវការអបអរសាទរចំពោះលោក ឆាំង យុ និងសូមជូនពរឲ្យលោកទទួលបានជោគជ័យពេញលេញក្នុងការអនុវត្តគម្រោងថ្មីនេះ។

សូមលោក ឆាំង យុ ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

Monineath

**នរោត្តម មុនិនាថ សីហនុ**

**ព្រះបរមរាជវាំង,**
**ភ្នំពេញ, ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១**

*ព្រះរាជលិខិតរបស់ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ការលើកកម្ពស់សិទ្ធិ និងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

## សារព័ត៌មានប្រៃសញ្ញ៉ូ ធ្វើបទសម្ភាសន៍ជាមួយលោក ឆាំង យុ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២១

*សោម ប៊ុនថន*

*កាលពីម្សិលមិញ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលហិរញ្ញប្បទានសរុបជាសាច់ប្រាក់ ៦លាន៥សែនដុល្លារសហរដ្ឋអាមេរិក ពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ដែលនឹងផ្តល់ការគាំទ្រដ៏សំខាន់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ គោលបំណងនៃហិរញ្ញប្បទាននេះគឺ (១) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមគោលដៅដែលបានគ្រោងទុក (២) បង្កើនការយល់ដឹងអំពីបញ្ហាសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសាធារណៈដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង (៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសនៅតាមសហគមន៍ដាច់ស្រយាល ដែលនឹងប្រើជាមូលដ្ឋានព័ត៌មានជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់សហគមន៍ និងប្រជាជនកម្ពុជា។*

## សំណួរចម្លើយជាមួយលោក ឆាំង យុ

***ប្រៃសញ្ញ៉ូ ៖ ហេតុអ្វីបានជាហិរញ្ញប្បទាននេះមានសារសំខាន់?***

**លោក ឆាំង យុ ៖** *ហិរញ្ញប្បទាននេះគឺជាជំហានបន្តលើការងារយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបប្រមាណ ៥លាននាក់ ដែលរស់នៅសព្វថ្ងៃនេះ។ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវការទទួលបានការថែទាំសុខភាព ឈានទៅដល់ការធ្វើឲ្យប្រសើរឡើងនូវសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ហិរញ្ញប្បទាននេះរួមបញ្ចូលទាំងសារសំខាន់នៃសមាសភាគស្រាវជ្រាវនិងអប់រំ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការសិក្សាស្រាវជ្រាវដើម្បីបង្កើនការយល់ដឹងសាធារណៈលើការថែទាំអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីជាមូលដ្ឋានព័ត៌មានសម្រាប់ការអភិវឌ្ឍនាពេលអនាគតសម្រាប់សហគមន៍ និងប្រជាជនកម្ពុជា។*

***ប្រៃសញ្ញ៉ូ ៖ តើអ្វីជាទិដ្ឋភាពពិសេសនៃហិរញ្ញប្បទាននេះ?***

**លោក ឆាំង យុ៖** *ហិរញ្ញប្បទាននេះរួមបញ្ចូល សិស្សនិស្សិតដែលជាអ្នកស្ម័គ្រចំនួន៥០០នាក់ ផ្តល់*

សេវាកម្មស្ម័គ្រចិត្តទូទាំងប្រទេស។ គោលបំណងនៃគំនិតផ្តួចផ្តើមនេះគឺ ដើម្បីឲ្យអ្នកស្ម័គ្រចិត្តម្នាក់ៗ សម្របខ្លួន និងធ្វើការជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិដ្ឋាន និងជួយនាំអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅពិនិត្យសុខភាពនៅតាមមន្ទីរសម្រាកព្យាបាលឯកជននៅក្នុងសហគមន៍។ នេះជាកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ សិស្សនិស្សិតដែលជាអ្នកស្ម័គ្រមានឱកាសបង្ហាញអំពីភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រទេសជាតិកម្ពុជា។

**ប្រាសញ៉ូ ៖ តើការថែទាំសុខភាពជាទម្រង់អ្វីដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានទទួលពីហិរញ្ញប្បទាននេះ?**

**លោក ឆាំង យុះ៖** គោលបំណងនៃហិរញ្ញប្បទាននេះគឺគាំទ្រលើការទទួលបានការថែទាំសុខភាព ក៏ដូចជាធ្វើឲ្យប្រសើរឡើងនូវស្ថានភាពខ្លះដែលអាចបង្កគ្រោះថ្នាក់ និងរារាំងអ្នករស់រានមានជីវិតក្នុងការថែទាំសុខភាព។ ផ្តល់ព័ត៌មានដែលអាចជាចំណេះដឹងអំពីការថែទាំសុខភាពខ្លួនឯងផ្ទាល់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការថែទាំដែលទទួលបានពីគ្រួសារ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់ការថែទាំសុខភាពមូលដ្ឋាន ដោយប្រយោលដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនឹងទទួលបាននៅក្នុងការពិនិត្យសុខភាព។ គោលការណ៍ណែនាំមូលដ្ឋានទាំងនេះ អាចចាប់ផ្តើមពីគ្រប់កន្លែង ពីការពិនិត្យ និងផ្តល់ប្រឹក្សាលើការថែទាំបណ្តោះអាសន្នដ៏ល្អមួយ ទៅជាការព្យាបាលរបួស និងស្ថានភាពសុខភាពខ្នាតតូចៗ។

**ប្រាសញ៉ូ៖ តើហិរញ្ញប្បទាននេះកើតចេញពីអ្វី?**

**លោក ឆាំង យុះ៖** ហិរញ្ញប្បទាននេះឆ្លុះបញ្ចាំងពីដំណើរ ១០ឆ្នាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការសិក្សាស្រាវជ្រាវ ចម្រាញ់ រៀបចំសក្ខានុពលសម្រាប់



រូបរាប់ពីឆ្វេង៖ សហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew T. Cayley, នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ និងសហព្រះរាជអាជ្ញាជាតិ លោកជំទាវ ជា លាង ចូលរួមកម្មវិធីសម្ពោធពាក្យស្លោកខ្មែរក្រហម នៅវិទ្យាល័យឥន្ទ្រទេវី នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គម្រោងនេះ។ នៅក្នុងឆ្នាំ២០១៧ ខេមា ហរណ៍ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួម ទាំង វេជ្ជបណ្ឌិត ដេមី រេយស៍ និងលោកស្រី គីម សុវណ្ណ ដានី បានចុះសួរសុខទុក្ខតាមមូលដ្ឋាន និងផ្តល់សេវាថែទាំសុខភាពបឋម ជូនដល់អតីតអ្នកដាក់ពាក្យបណ្តឹង ដើមបណ្តឹងរដ្ឋប្បវេណីរបស់សាលាក្តីខ្មែរក្រហម នៅឯវត្តលលកសថ្មី ស្ថិតក្នុងខេត្តពោធិ៍សាត់ និងបណ្តាខេត្តដទៃទៀត។



អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើការងារលើគម្រោង "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" នៅតាមតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ (អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ប្រ្ញាសញ៉ូ ៖ តើហិរញ្ញប្បទាននេះទាក់ទងនឹងយុត្តិធម៌យ៉ាងដូចម្តេច?

**ឆាំង យុះ** និយមន័យនៃយុត្តិធម៌ គឺមិនមែនមានផ្តោតលើដំណើរការរបស់តុលាការតែម៉្យាងនោះទេ យុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនឹងបន្តតស៊ូរយៈពេលយូរទៅមុខទៀតបន្ទាប់ពីតុលាការខ្មែរក្រហមត្រូវបញ្ចប់។ ហិរញ្ញប្បទាននេះគឺជាការខិតខំប្រឹងប្រែងថ្មីមួយដើម្បីធ្វើឲ្យសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រសើរឡើង ដែលជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។



## ប្រ្ញាសញ៉ូ ៖ តើមជ្ឈមណ្ឌលឯកសារកម្ពុជាកំណត់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដោយវិធីណា?

**លោក ឆាំង យុ** ៖ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំបានបំផ្លាញភាពជាមនុស្សរបស់ប្រជាជន។ មជ្ឈមណ្ឌលឯកសារកម្ពុកមានគោលដៅស្តារឡើងវិញនូវអំពើមនុស្សធម៌នៃប្រជាជនទាំងអស់ មិនមែនត្រឹមតែជនរងគ្រោះតែប៉ុណ្ណោះទេ ប៉ុន្តែគឺរួមបញ្ចូល ទាំងជនដែលបានប្រព្រឹត្តអំពើឃោរឃៅ។ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងផ្តល់ការគាំទ្រ និងសេវាកម្មដល់ប្រជាជនកម្ពុជាឲ្យច្រើនតាមអ្វីដែលអាចធ្វើបាន ដោយផ្អែកលើការជឿជាក់ថា ប្រជាជន



*កម្ពុជា ទាំងអស់ដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហម ទទួលការរងទុក្ខវេទនា។*

**ប្រូសញ៉ូ៖ តើជនដែលនឹងទទួលបានការគាំទ្រ និងសេវាកម្មដូចជនរងគ្រោះដែរឬទេ?**

**ឆាំង យុ**៖ *សំណួរនេះធ្វើឲ្យខ្ញុំនឹកឃើញដល់ការសន្ទនារបស់ខ្ញុំជាមួយជនរងគ្រោះម្នាក់ ដែលចង្អុលបង្ហាញមកខ្ញុំអំពី ការផ្តល់ការថែទាំសុខភាព និងសេវាកម្មដ៏អស្ចារ្យនេះដល់ជនជាប់ចោទពីបទឧក្រិដ្ឋខណៈដែលប្រជាជនកម្ពុជាជាច្រើនដែលធ្លាប់បានរស់នៅក្រោមរបបខ្មែរក្រហមនៅតែបន្តរងទុក្ខពីរបួស និងស្ថានភាពសុខភាព ទាំងផ្លូវកាយ និងផ្លូវចិត្ត។ កិច្ចខិតខំប្រឹងប្រែងនេះគឺ ជាសកម្មភាពសំខាន់ប្តេជ្ញាក្នុងការផ្តល់ការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនដែលមិនអាចទទួលបានការថែទាំសុខភាព និង អ្នកដែលកំពុងរងទុក្ខដែលគ្មានអ្នកណាម្នាក់ដឹងឮ។*

**ប្រូសញ៉ូ៖ តើប្រភេទជំងឺ ឬស្ថានភាពសុខភាពណាខ្លះដែលមជ្ឈមណ្ឌលឯកសារកម្ពុជារំពឹងថានឹងរកឃើញលើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម?**

**លោក ឆាំង យុ**៖ *មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាង ២០០០ នាក់ចាប់តាំងពីឆ្នាំ២០១៧។ ការងាររបស់យើងបានប្រទះឃើញជំងឺប្រហាក់ប្រហែលគ្នាក្នុងចំណោមអ្នកទាំងនោះគឺចំនួន ៥ ប្រភេទរួមមាន៖ ១)ជំងឺលើសឈាម ២)ជំងឺបេះដូង ៣)ជំងឺទឹកនោមផ្អែម ៤)ជំងឺស្ទះផ្លូវដង្ហើមរ៉ាំរ៉ៃ និងជំងឺរបេងសួត និង ៥)ជំងឺមហារីកសុដន។*

**ប្រូសញ៉ូ៖ តើអ្វីអាចគ្រប់គ្រាន់ក្នុងការតបស្នងដល់ប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម?**

**លោក ឆាំង យុ**៖ *សោកនាដកម្ម និងអំពើអយុត្តិធម៌ដែលប្រជាជនកម្ពុជាបានជួបប្រទះក្រោមរបបខ្មែរក្រហមគឺ ធំធេងគ្មានអ្វីដែលអាចតបស្នងបាននោះទេ យ៉ាងណាមិញ កិច្ចខិតខំប្រឹងប្រែងនេះគឺជាជំហានដ៏ចាំបាច់មួយឆ្ពោះទៅរកការគាំទ្រ និងការជួយជ្រោមជ្រែងពិតប្រាកដមួយដល់អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍។ ការងារនេះនឹងកំណត់គោលដៅមិនត្រឹមតែចំពោះមនុស្សចាស់ និងជនពិការដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ គឺរួមបញ្ចូល ទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមសហគមន៍ដាច់ស្រយាល និងនៅឆ្ងាយពីមន្ទីរសម្រាប់ព្យាបាលឯកជន។ នេះគឺជាយុត្តិធម៌ «ការគិតឡើងវិញ»... វាគឺជា «យុត្តិធម៌ផ្សះផ្សា» សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។*

*យុត្តិធម៌អន្តរកាលត្រូវតែរួមបញ្ចូលលើសពីសំណងជានិមិត្តរូប វាត្រូវតែរួមបញ្ចូល ទាំងសកម្មភាពយ៉ាងយោចណាស់ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ប្រទេសកម្ពុជាអាចជាប្រទេសទី១ ចាប់តាំងពីអំពើឧក្រិដ្ឋកម្មសម្លាប់រង្គាលលើជនជាតិជ្វីហ្វនៅអឺរ៉ុប ក្នុងន័យដែលអ្នករស់រានមានជីវិតពីអំពើឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ទទួលបានសំណងទាក់ទងនឹងការស្តារឡើងវិញនូវសេវាកម្ម ការគាំទ្រ និងការថែទាំសុខភាពពីសហគមន៍អន្តរជាតិ។ យើងទាំងអស់គ្នាគួរតែទទួលស្គាល់ថាកិច្ចខិតខំប្រឹងប្រែងក្នុងការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគឺជា ជំហានទៅមុខមួយដែលគួរឲ្យកោតសរសើរក៏ដូចជាការចាប់ផ្តើមនៃការសន្ទនាថ្មីលើនិយមន័យយុត្តិធម៌ក្រោយជម្លោះ។*

# កិច្ចសម្ភាសន៍រវាងសារព័ត៌មានស្វែងរកការពិតជាមួយ លោក ឆាំង យុ

## លើកិច្ចខិតខំប្រឹងប្រែងថ្មីដើម្បីផ្សះផ្សាការឈឺចាប់នៃអំពើប្រល័យពូជសាសន៍តាមរយៈការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

សោម ប៊ុនថន

*ថ្មីៗនេះ លោក ឆាំង យុ បានទទួលហិរញ្ញប្បទានសរុបជាសាច់ប្រាក់ ៦លាន៥សែន ដុល្លារសហរដ្ឋអាមេរិក ពីរដ្ឋាភិបាលសហរដ្ឋអាមេរិកតាមរយៈ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ប្រចាំនៅរាជធានីភ្នំពេញសម្រាប់អនុវត្តគម្រោងរបស់លោក មានឈ្មោះថា ការលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។*

### សំណួរចម្លើយជាមួយលោក ឆាំង យុ

***សារព័ត៌មានស្វែងរកការពិត ៖ តើហេតុអ្វីបានជាហិរញ្ញប្បទាននេះពិសេសសម្រាប់លោក?***

***លោក ឆាំង យុ ៖*** *ជាដំបូង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះពររបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ លើកិច្ចខិតខំប្រឹងប្រែងនេះ។*

*ខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសគឺ ក្រសួងមហាផ្ទៃ ដែលតែងតែជួយគាំទ្រដល់ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៥។*

*មជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល កម្ពុជា ក្នុងការដោះស្រាយបញ្ហាដែលទាក់ទងជាមួយនឹងសុខភាពសាធារណៈ និង បន្តអនុវត្ត ៣ ការពារ និង ៣ កុំ ដែលជាសេចក្តីណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។*

*ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តម អគ្គ បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានអនុគ្រោះពន្ធឲ្យនាំចូលរថយន្តសុខភាពចល័តខ្នាតតូចដើម្បីគាំទ្រសកម្មភាពខ្លះនៃគម្រោងនេះ។*

*ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលទទួលបានហិរញ្ញប្បទានពីរដ្ឋាភិបាលសហរដ្ឋអាមេរិក តាមរយៈ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ប្រចាំនៅរាជធានីភ្នំពេញដែលនឹងផ្តល់ការគាំទ្រដ៏សំខាន់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។*



ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា W. Patrick Murphy (រូបទី៨រាប់ពីស្តាំ) និងនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ (រូបទី៦រាប់ពីឆ្វេង) នៅក្នុងកម្មវិធីប្រកាសផ្តល់ហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់៥លានដុល្លារសហរដ្ឋអាមេរិក ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលត្រូវបានរៀបចំឡើងនៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ហេតុអ្វីបានជាហិរញ្ញប្បទាននេះពិសេសសម្រាប់រូបខ្ញុំ?

ហិរញ្ញប្បទាននេះរួមបញ្ចូល សិស្សនិស្សិតដែលជាអ្នកស្ម័គ្រចំនួន៥០០នាក់ ផ្តល់សេវាកម្មស្ម័គ្រចិត្តទូទាំងប្រទេសសម្រាប់ជួយគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមភូមិដ្ឋាន និងជួយនាំអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅពិនិត្យសុខភាពនៅតាមមន្ទីរសម្រាកព្យាបាលឯកជននៅក្នុងសហគមន៍។ កិច្ចខិតខំប្រឹងប្រែងដ៏សំខាន់នេះនឹងផ្តល់ឱកាសដល់យុវវ័យដើម្បីបង្ហាញអំពីភាពជាអ្នកដឹកនាំ និងស្វែងរកការពិតដោយខ្លួនឯងផ្ទាល់ និងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រទេសជាតិកម្ពុជា។ ទន្ទឹមនឹងនេះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានឱកាសចែករំលែករឿងរ៉ាវដែលធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ទៅយុវវ័យជំនាន់ក្រោយដើម្បីធ្វើឲ្យប្រាកដថា យើងទាំងអស់គ្នាចងចាំរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ ជារួម គម្រោងនេះនឹងរំលេចនូវចរិតមនុស្សធម៌របស់យើង និងពង្រឹងបន្ថែមនូវស្មារតីមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជា។

## សារព័ត៌មានរស្មីកម្ពុជា៖ តើលោកអាចកំណត់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដោយវិធីណា?

**លោក ឆាំង យុ៖** អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំបានបំផ្លាញមនុស្សធម៌របស់ប្រជាជន។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅស្តារឡើងវិញនូវអំពើមនុស្សធម៌នៃប្រជាជនទាំងអស់ មិនមែនត្រឹមតែជនរងគ្រោះតែប៉ុណ្ណោះទេ ប៉ុន្តែ គឺរួមបញ្ចូលទាំងជនដែលបានប្រព្រឹត្តអំពើឃោរឃៅ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់ការគាំទ្រ និងសេវាកម្មដល់ប្រជាជនកម្ពុជាឲ្យច្រើនតាមអ្វីដែលអាចធ្វើបាន ដោយផ្អែកលើការជឿជាក់ថាប្រជាជនកម្ពុជាទាំងអស់ដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហមទទួលការរងទុក្ខវេទនា។ បើនិយាយអំពីតួលេខ

គឺមានអ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ចំនួន ៥,១៤៣,៣៨៦ នាក់ (អាយុ៥០ឆ្នាំ និងលើសពី៥០ឆ្នាំ) ស្មើនឹង ៣៣.១៦ ភាគរយនៃប្រជាជនសរុប ក្នុង១៩៦ស្រុក ក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៧។ មូលហេតុគឺ បច្ចុប្បន្ននេះ ប្រជាជនដែលមានអាយុចាប់ពី ៥០ឆ្នាំ ឬច្រើនជាង៥០ឆ្នាំ យ៉ាងហោចណាស់ជាក្មេងដែលមានអាយុ ៨ ទៅ១០ឆ្នាំនៅពេលដែលខ្មែរក្រហមដួលរលំក្នុង១៩៧៩។ គាត់គឺជាក្រុមមនុស្សដែលនៅចងចាំរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម និងជាក្រុមមនុស្សដែលមានរឿងរ៉ាវសម្រាប់ចែករំលែកជាមួយយុវវ័យបច្ចុប្បន្ននេះ។

### សារព័ត៌មានរស្មីកម្ពុជា ៖ តើអ្វីអាចគ្រប់គ្រាន់ក្នុងការតបស្នងដល់ប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម?

**លោក ឆាំង យុ ៖** សោកនាកម្ម និងអំពើអយុត្តិធម៌ដែលប្រជាជនកម្ពុជាបានជួបប្រទះក្រោមរបបខ្មែរក្រហមគឺ ធំធេងគ្មានអ្វីដែលអាចតបស្នងបាននោះទេ យ៉ាងណាមិញ កិច្ចខិតខំប្រឹងប្រែងនេះគឺជាជំហានដ៏ចាំបាច់មួយឆ្ពោះទៅរកការគាំទ្រ និងការជួយជ្រោមជ្រែងពិតប្រាកដមួយដល់អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍។ ការងារនេះនឹងកំណត់គោលដៅមិនត្រឹមតែចំពោះមនុស្សចាស់ និងជនពិការដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ គឺរួមបញ្ចូលទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមសហគមន៍ដាច់ស្រយាល និងនៅឆ្ងាយពីមន្ទីរសម្រាកព្យាបាលឯកជន។ នេះគឺជាយុត្តិធម៌ «ការគិតឡើងវិញ»... វាគឺជា «យុត្តិធម៌ផ្សះផ្សា» សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

### សារព័ត៌មានរស្មីកម្ពុជា ៖ តើហិរញ្ញប្បទាននេះមានអត្ថន័យយ៉ាងដូចម្តេចចំពោះប្រទេសកម្ពុជា?

**លោក ឆាំង យុ៖** យុត្តិធម៌អន្តរកាលត្រូវតែរួមបញ្ចូលលើសពីសំណងជានិមិត្តរូប វាត្រូវតែរួមបញ្ចូលទាំងសកម្មភាពយ៉ាងយោចណាស់ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ប្រទេសកម្ពុជាអាចជាប្រទេសទី១ ចាប់តាំងពីអំពើឧក្រិដ្ឋកម្មសម្លាប់រង្គាលលើជនជាតិជ្វីហ្វនៅអឺរ៉ុប ក្នុងន័យដែលអ្នករស់រានមានជីវិតពីអំពើឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ទទួលបានសំណងទាក់ទងនឹងការស្តារឡើងវិញនូវសេវាកម្ម ការគាំទ្រ និងការថែទាំសុខភាពពីសហគមន៍អន្តរជាតិ។ យើងទាំងអស់គ្នាគួរតែទទួលស្គាល់ថាកិច្ចខិតខំប្រឹងប្រែងក្នុងការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគឺជា ជំហានទៅមុខមួយដែលគួរឲ្យកោតសរសើរ ក៏ដូចជាការចាប់ផ្តើមនៃការសន្ទនាថ្មីលើនិយមន័យយុត្តិធម៌ក្រោយជម្លោះ។



រូបខាងស្តាំ៖ គឹម សុវណ្ណដានី អ្នកសម្របសម្រួលគម្រោង "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" ជួបជាមួយគ្រូពេទ្យធ្វើការនៅគ្លីនិកឯកជន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា W. Patrick Murphy ជូនកញ្ចប់អនុស្សាវរីយ៍ដល់អ្នករស់រានមានជីវិតនៅក្នុងរបបខ្មែរក្រហម នៅក្នុងកម្មវិធីប្រកាសផ្ដល់ហិរញ្ញប្បទានបន្ថែមក្នុងទំហំទឹកប្រាក់ ៥ លានដុល្លារសហរដ្ឋអាមេរិក ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើការងារលើគម្រោង "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" ដែលត្រូវបានរៀបចំឡើងនៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)
















អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើការងារលើគម្រោង "ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" នៅតាមតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ (អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅ ខេត្តត្បូងឃ្មុំទទួលកញ្ចប់អនុស្សាវរីយ៍

ឡុង ដានី







អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តត្បូងឃ្មុំ ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ ។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តត្បូងឃ្មុំ)

កាលពីរសៀលថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ ក្រុមការងារមជ្ឈមណ្ឌលឯកសារ កោះថ្ម ខេត្តត្បូងឃ្មុំ រួមមាន៖ ឡុង ដានី និង សុខ វណ្ណៈ បានដឹកកញ្ចប់អនុស្សាវរីយ៍ចំនួន១០០កញ្ចប់ចេញពីទីក្រុងភ្នំពេញ ឆ្ពោះទៅកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ នៅម៉ោង៦៖៣០នាទីល្ងាចថ្ងៃដដែល ក្រុមការងារបានមកដល់ទីរួមស្រុកមេមត់ និងបានស្នាក់នៅទីនោះមួយយប់។ នៅវេលាម៉ោង៧៖៣០ព្រឹក ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១ លោក ឡុង ដានី និង សុខ វណ្ណៈ បានធ្វើដំណើរទៅកាន់មជ្ឈមណ្ឌលឯកសារកោះថ្មបន្តទៀត។ នៅទីនោះ លោក ឡុង ដានី និង សុខ វណ្ណៈ បានផ្តល់កញ្ចប់អនុស្សាវរីយ៍ចំនួន១០០កញ្ចប់ដល់អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តត្បូងឃ្មុំ ដើម្បីរៀបចំនិងចែកជូនបន្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលអ្នកស្ម័គ្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្ភាសន៍ និងបំពេញតារាងស្ទាបស្ទង់មតិលើគម្រោងសុខភាពកាលពីខែសីហា ឆ្នាំ២០២១ កន្លងមក។



























អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តត្បូងឃ្មុំ ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ ។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តត្បូងឃ្មុំ)

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅ
## ខេត្តកំពង់ស្ពឺ ទទួលកញ្ចប់អនុស្សាវរីយ៍

*មីន សាណាស់*



អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ស្ពឺ ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ ។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ស្ពឺ)









នៅវេលាម៉ោង៧:៣០នាទីព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១ ក្រុមការងារមជ្ឈមណ្ឌលឯកសាកម្ពុជា រួមមាន៖ ឡុង អូន និង មីន សាណាស់ បានដឹកកញ្ចប់អនុស្សាវរីយ៍ចំនួន៥០កញ្ចប់នៃគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចេញពីការិយាល័យនៅទីក្រុងភ្នំពេញឆ្ពោះទៅកាន់ ខេត្តកំពង់ស្ពឺ ដើម្បីចែកជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងស្រុកភ្នំស្រួច ស្រុកថ្ពង និងស្រុកឧដុង្គ។ នៅម៉ោង១១: ០០នាទីព្រឹកថ្ងៃដដែល ក្រុមការងារបានមកដល់ ក្រុងច្បារមន ដើម្បីជួបជុំអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្ត

កំពង់ស្ពឺ។ នៅអំឡុងពេលនោះយើងពិភាក្សាពីបញ្ហាប្រឈម និងដំណោះស្រាយចំពោះការចុះធ្វើការកន្លងមក ព្រមទាំងប្រគល់ជូននូវអាវ និងថង់យាមដល់អ្នកស្ម័គ្រចិត្ត និងបរិភោគអាហារថ្ងៃត្រង់ជុំគ្នា។ បន្ទាប់ពីហូបបាយថ្ងៃត្រង់រួច អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ស្ពឺ រៀបចំសម្ភារ និងកញ្ចប់អនុស្សាវរីយ៍យកទៅចែកជូនដល់អ្នករស់រានមានជីវិតពីរបបក្រហម ដែលខ្លួនបានសម្ភាសន៍ និងបំពេញតារាងស្ទាបស្ទង់មតិលើគម្រោងសុខភាពនៅក្នុងខែសីហា និង ខែកញ្ញា ឆ្នាំ២០២១ កន្លងមក។











អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ស្ពឺ ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ ។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ស្ពឺ)





# សហគមន៍ជនជាតិភាគតិចចាម នៅក្នុងស្រុកក្រូចឆ្មារ ទទួលបានកញ្ចប់អនុស្សាវរីយ៍

***មីន សាណាស់***





ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម រួមមាន ឡុង ដានី និង មីន សាណាស់ បានដឹកកញ្ចប់អនុស្សាវរីយ៍ចំនួន១០០កញ្ចប់ ចេញពីការិយាល័យនៅទីក្រុងភ្នំពេញឆ្ពោះទៅកាន់ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដើម្បីចែកជូនដល់សហគមន៍ជនជាតិចាម ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងស្រុកក្រូចឆ្មារ។ នៅម៉ោង១១÷៤៥នាទីព្រឹកថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០២១ ក្រុមការងារបានមកដល់ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ បន្ទាប់ពីហូបបាយថ្ងៃត្រង់រួចក្រុមការងារ និងអ្នកស្ម័គ្រចិត្តកម្ពុជា នៃមជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំស្រុកក្រូចឆ្មារបានជញ្ជូនសម្ភារ និងកញ្ចប់អនុស្សាវរីយ៍ចេញពីក្នុងរថយន្ត ដើម្បីវេចខ្ចប់។ នៅម៉ោងប្រមាណ១÷៤០នាទីរសៀល ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម និងអ្នកស្ម័គ្រចិត្តកម្ពុជារៀបចំវេចខ្ចប់ប្រអប់អនុស្សាវរីយ៍ចំនួន១០០កញ្ចប់ ដើម្បីយកទៅចែកជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងសហគមន៍



អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តត្បូងឃ្មុំ ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ចាម)

ជនជាតិភាគតិចចាម នៅក្នុងស្រុកក្រូចឆ្មារ ដែលក្រុមអ្នកស្ម័គ្រកម្ពុជាបានសម្ភាសន៍ និងបំពេញតារាងស្ទាបស្ទង់មតិលើគម្រោងសុខភាពកាលពីខែសីហា ឆ្នាំ២០២១ កន្លងមក។












# អនុព័ន្ធយោធាសហរដ្ឋអាមេរិកទស្សនកិច្ច មជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ

ឡុង ដានី








មន្ត្រីអនុព័ន្ធយោធាសហរដ្ឋអាមេរិក Eric T Phillips ទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តត្បូងឃ្មុំ

នៅវេលាម៉ោង១១៖៣០នាទីព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១ លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារ កោះថ្ម ខេត្តត្បូងឃ្មុំ បានទទួលស្វាគមន៍លោក Eric T Phillips មន្ត្រីអនុព័ន្ធយោធាសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា និងសហការីដែលបានមកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងពិភាក្សាអំពីការងារស្រាវជ្រាវនៅអតីតតំបន់សមរភូមិ រវាងទាហានសហរដ្ឋអាមេរិក និងកងទ័ពវៀតកុង នៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៧០។





# មជ្ឈមណ្ឌលឯកសារកម្ពុជា
## ផ្តល់ម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគ និងទឹកថ្នាំសម្លាប់មេរោគជូន រដ្ឋបាលស្រុកអន្លង់វែង

ធ្យុង អូន











នៅព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ រដ្ឋបាលស្រុកអន្លង់វែង ទទួលម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគចំនួន៤គ្រឿង និងទឹកថ្នាំសម្លាប់មេរោគចំនួន៥០លីត្រ ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងខណៈដែលការរីករាលដាលជំងឺកូវីដ១៩ និងមេរោគបំប្លែងថ្មីប្រភេទដែលតានៅក្នុងប្រទេសបានឈានដល់កម្រិតមួយដ៏គួរបារម្ភ។ លោក ហោ ជិនវិរយុទ្ធ អភិបាល នៃគណៈអភិបាលស្រុកអន្លង់វែង បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់សម្ភារទាំងអស់នេះ ដើម្បីរួមចំណែកទប់ស្កាត់ការរីករាលដាលនៃមេរោគនេះ។

ថ្មីៗនេះ មានការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ចូលទៅក្នុងសហគមន៍ ក្នុងស្រុកអន្លង់វែង។

មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគ និងអាល់កុលជូនរដ្ឋបាលស្រុកអន្លង់វែង គឺជាការរួមចំណែកក្នុងការទប់ស្កាត់ការរីករាលជំងឺកូវីដ-១៩ ជាពិសេសគឺជំងឺកូវីដ-១៩ បំប្លែងថ្មីប្រភេទដែលតា។

# ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី យាងទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ»

សុភ័ក្ត្រ ភាណា





ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី ព្រះប្រធានមូលនិធិស្ត្រី សម្តេចរស្មីសោភ័ណ ទ្រង់ដឹកនាំប្រតិភូកិត្តិយស រួមមាន ព្រះអង្គម្ចាស់ក្សត្រី នរោត្តម រតនាទេវី, ព្រះអង្គម្ចាស់ នរោត្តម សីហបុទ្ធិ, ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ តេសូ និងលោកជំទាវ ប៉ុក បុប្ផា យាងទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា នាព្រឹកថ្ងៃអង្គារ ទី១៨ ខែកញ្ញា ឆ្នាំ២០២១។
( សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី ព្រះប្រធានមូលនិធិស្ត្រី សម្តេចរស្មីសោភ័ណ ទ្រង់ដឹកនាំប្រតិភូកិត្តិយស រួមមាន ព្រះអង្គម្ចាស់ក្សត្រី នរោត្តម រតនាទេវី, ព្រះអង្គម្ចាស់ នរោត្តម សីហបុទ្ធិ, ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ តេសូ និងលោកជំទាវ ប៉ុក បុប្ផា យាងទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា នាព្រឹកថ្ងៃអង្គារ ទី១៨ ខែកញ្ញា ឆ្នាំ២០២១។

ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី ព្រះប្រធានមូលនិធិស្ត្រី សម្តេចរស្មីសោភ័ណ ទ្រង់ប្រសូតនៅទីក្រុងភ្នំពេញ នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៨ និង

ទទួលការសិក្សានៅក្នុងប្រទេសកម្ពុជា និងប្រទេសបារាំង។ ក្នុងឆ្នាំ១៩៨៥ ព្រះអង្គម្ចាស់ក្សត្រី ព្រះរាជបង្កើតសមាគមស្ត្រីកម្ពុជា ដែលមានទីតាំងដំបូងនៅឯជំរំជនភៀសខ្លួនតាមបណ្តោយព្រំដែនកម្ពុជាថៃ ដែលធ្វើប្រតិបត្តិការដោយគណបក្សហ៊្វុនស៊ិនប៉ិច។

បន្ទាប់ពីសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស សមាគមស្ត្រីកម្ពុជា បានប្តូរឈ្មោះទៅជាមូលនិធិស្ត្រី សម្តេចរស្មីសោភ័ណ ដែលជាព្រះនាមរបស់ព្រះអង្គម្ចាស់ក្សត្រី នរោត្តម រស្មី សោភ័ណ ព្រះអនុជរបស់ព្រះបាទសម្តេចនរោត្តម សុរាម្រិត។ មូលនិធិនេះមានទីស្នាក់ការនៅក្នុងទីក្រុងភ្នំពេញ ដោយត្រូវបានទទួលស្គាល់ជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលជួយដល់ស្ត្រីកម្ពុជាលើវិស័យអប់រំ សុខាភិបាល និងការបណ្តុះបណ្តាល។

មូលនិធិស្ត្រី សម្តេចរស្មីសោភ័ណបានបង្កើតឡើង និងគឺជាអង្គការឈានមុខក្នុងការលើកកម្ពស់ការកកើតឡើងវិញនៃសូត្រខ្មែរ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើររស់រានផ្នែកសិល្បៈ ការស្តារមុខមាត់ និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

នៅក្នុងដំណើរទស្សនកិច្ចនេះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, លោកឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ អេ. ហែលក្រេស អតីតលេខាព្រះបរមរតនកោដ្ឋ និងលោកស្រី សូ ហ្វារីណា នាយិការងមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលស្វាគមន៍ព្រះប្រតិភូកិត្តិយសយ៉ាងកក់ក្តៅ។ លោក ឆាំង យុ បានបង្ហាញភ្ញៀវកិត្តិយស នូវពិព័រណ៍នៃប្លង់រចនាវិទ្យាស្ថានស្លឹករឹត ដែលជាស្នាដៃរបស់លោកស្រី ហ្សាហា ហាឌីដ ស្ថាបត្យករស្ត្រីដ៏ល្បីល្បាញកម្រិតពិភពលោក។ ទន្ទឹមនឹងនេះ លោកឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ អេ. ហែលក្រេស បានណែនាំអំពីបន្ទប់បណ្ណាល័យនៃ «បណ្ណាល័យសម្តេចម៉ែ» ដែលមានរក្សាទុកឯកសារកម្រនានា ស្តីពីព្រះរាជកិច្ចនិងព្រះរាជដំណើរជីវិតរបស់ព្រះបរមរតនកោដ្ឋ។

ព្រះប្រតិភូកិត្តិយស បានយាងទតបរិក្ខាររក្សាទុកឯកសារខ្មែរក្រហមបែបឌីជីថល។ ព្រះប្រតិភូកិត្តិយសក៏បានយាងទស្សនាបរិក្ខាររក្សាទុកឯកសារជាសំឡេងដែលជាសមិទ្ធផលនៃគម្រោងប្រវត្តិសាស្ត្រនិយាយដោយផ្ទាល់មាត់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ គម្រោងនេះបានប្រមែប្រមូលសាច់រឿងប្រមាណជាង១លាន ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ គួរបញ្ជាក់ថា ប្រជាជនកម្ពុជាប្រមាណជាង៥លាន







នាក់បានបន្តរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជា បាននិងកំពុងស្វះស្វែងចងក្រងបទពិសោធន៍ និងលើកស្ទួយសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំងនោះតាមរយៈគម្រោងលើកកម្ពស់សិទ្ធិនិងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

បន្ទាប់មក ព្រះប្រតិភូកិត្តិយស និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ពិភាក្សាជុំវិញការងារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្តអនុវត្ត និងការចូលរួមចំណែករបស់ស្ត្រីនៅក្នុងការងារសង្គមឈានទៅសម្រេចបានការអភិវឌ្ឍ។ កិច្ចពិភាក្សាបានផ្តោតជាពិសេសលើ គម្រោងសូត្រចាមរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា ដែលបច្ចុប្បន្ន ស្ថិតនៅក្នុងដំណាក់កាលស្រាវជ្រាវលម្អិតស្តីពីទម្រង់ ពណ៌ ការរចនា និងការប្រើប្រាស់ជាដើម។ ការសិក្សាស្រាវជ្រាវនេះក្រោយនឹងត្រូវបោះពុម្ពជាសៀវភៅ និងធ្វើប្រតិបត្តិជាក់ស្តែង តាមរយៈ ការធ្វើពិសោធន៍បែបវិទ្យាសាស្ត្រ ដើម្បីបង្កើតជាផលិតផលសម្រេច។

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា គម្រោងនេះនឹងអាចស្តារឡើងវិញនូវកេរដំណែលវប្បធម៌នៃសហគមន៍ជនជាតិចាមដែលស្ទើរតែនឹងបាត់បង់ តាមរយៈការផ្តល់ឱកាសដល់អ្នកត្បាញនៃសហគមន៍នេះឲ្យវិលត្រឡប់មកប្រកបមុខរបរត្បាញ និងអាចបង្កើនប្រាក់ចំណូលគ្រួសាររបស់ខ្លួន។ គម្រោងនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំដល់ក្មេងជំនាន់ក្រោយអំពីសម្បត្តិវប្បធម៌ដ៏កម្រ ព្រមទាំងចូលរួមថែរក្សាកេរដំណែលនេះឲ្យប្រកបដោយចីរភាព។ គម្រោងសូត្រចាមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងប្រើប្រាស់ធនធានដែលបង្កើតបានពីការលក់ផលិតផលសម្រេច ដើម្បីបន្តនិរន្តរភាពរបស់ខ្លួន ក៏ដូចជាលើកស្ទួយសេដ្ឋកិច្ចរបស់អ្នកតម្បាញដទៃទៀត។

នៅមុនពេលបញ្ចប់ព្រះរាជទស្សនកិច្ច ព្រះប្រតិភូកិត្តិយសបានសម្តែងនូវអំណរគុណ ចំពោះគារវកិច្ចស្វាគមន៍ដ៏សោមនស្សរបស់ថ្នាក់ដឹកនាំមជ្ឈមណ្ឌលឯកសារកម្ពុជា។ ព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី ទ្រង់សព្វព្រះហឫទ័យរាជទានបណ្តុំឯកសារដែលមានតម្លៃជាប្រវត្តិសាស្ត្រ ដើម្បីដាក់តម្កល់នៅ «បណ្ណាល័យសម្តេចម៉ែ» សម្រាប់បម្រើដល់កិច្ចការស្រាវជ្រាវ និងអប់រំដល់មនុស្សជំនាន់ក្រោយរបស់កម្ពុជា។



# យូ ព្រឿង ៖ អតីតពេទ្យផ្នែកផលិតអំពូលកែវដាក់ថ្នាំក្នុងរបបខ្មែរក្រហម

**ដារ៉ារដ្ឋ មេត្តា**

«នៅពេលទឹកជន់ បំរដូវស្រូវទុំ កងរបស់ខ្ញុំប្រូតស្រូវមិនទាន់ធ្វើឲ្យទឹកលិចស្រូវខូចអស់ ពេលនោះអង្គការចោទថាកងរបស់ខ្ញុំបំផ្លាញបដិវត្តន៍ ហើយបញ្ជូនខ្ញុំនិងសមាជិកផ្សេងទៀតទៅលត់ដំខ្លួននៅមន្ទីរព-២ ដែលមានទីតាំងក្បែរផ្ទះ១០០ខ្នង»។

ខ្ញុំឈ្មោះដើម ទឹម ព្រឿង ។ នៅពេលខ្ញុំចូលបដិវត្តន៍ ខ្ញុំដូរត្រកូលដោយយកឈ្មោះជីតា ដាក់គឺ តាយូ ទើបខ្ញុំជាប់ឈ្មោះ យូ ព្រឿង រហូតមក។ ពេលខ្ញុំចេញទៅធ្វើការងាររឆ្ងាយៗ ខ្ញុំដាក់ឈ្មោះថ្មីទៀតគឺ សំអួន។ ខ្ញុំមានប្រពន្ធឈ្មោះ ឡុង យ៉េន។ យើងរៀបការនៅក្នុងឆ្នាំ១៩៦៨។ ខ្ញុំមានកូនចំនួន៨នាក់គឺស្រី៦នាក់ និងប្រុសចំនួន២នាក់។ កូនប្រុសរបស់ខ្ញុំពីរនាក់ គឺ ឈ្មោះ យៀត ស្លាប់ដោយសារជំងឺកញ្ជ្រិល និង ឈ្មោះ វឿន ស្លាប់ដោយសារកើតពិសកុកនៅក្នុងរបបខ្មែរក្រហម។



យូ ព្រឿង រស់នៅឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំចូលបដិវត្តន៍នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៧៤ នៅក្នុងឃុំត្នោតតាមរយៈប្រធានភូមិឈ្មោះ ទិត ណោ។ ខ្ញុំស្ម័គ្រចិត្តចូលបដិវត្តន៍ ព្រោះឃើញមានការជិះជាន់ទៅលើប្រជាជន, កម្មករ, កសិករ ទើបធ្វើឲ្យខ្ញុំមានកំហឹងជាមួយរបប លន់ នល់។ មិនយូរប៉ុន្មាន អង្គការជ្រើសរើសខ្ញុំ និងចាត់តាំងខ្ញុំឲ្យធ្វើជាយោធាស្រុករយៈពេល៣ខែ។ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅ ស-២០០ ដែលមានផ្ទៃដីទំហំប្រហែលជា១០០ម៉ែត្រការ៉េ គឺជាសាលាហ្វឹកហ្វឺនផ្នែកយោធារបស់តំបន់២០ ភូមិភាគបូព៌ា។ ពេលនោះខ្ញុំហ្វឹកហាត់នៅក្នុងវត្តចាស់ដែលស្ថិតនៅលើដីទួល ក្បែរភូមិស្វាយ ទាប ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។ ខ្មែរក្រហមរៀបចំធ្វើជាបន្ទាយហ្វឹកហាត់យុទ្ធជនរត់ ពួន លូន ក្រាប បាញ់ ជាដើម។ ក្រោយមកអង្គការបានផ្លាស់ទីតាំងពីឃុំអំពិលក្រៅ ទៅភូមិស្វាយរមៀត ឃុំក្ដឿងរាយ ស្រុកកញ្ជ្រៀច ក្នុងខេត្តព្រៃវែងដដែល។ ខ្ញុំហាត់រៀនរយៈពេល២ខែ ពីរបៀបបាញ់ ក្រាប ដើរ លូន និងវាយឆ្មក់។ ប្រធានខនៅស្រុកកញ្ជ្រៀចឈ្មោះ ខេន និង ប្រធានគរបស់ខ្ញុំឈ្មោះសី ។ ពេល បងសី និយាយជាមួយខ្ញុំគាត់តែងតែលើកពាក្យ «អង្គការ» ប្រាប់ខ្ញុំឲ្យធ្វើអ្វីមួយ ប៉ុន្តែខ្ញុំមិនដឹងអង្គការគឺជានរណាទេ ហើយខ្ញុំគ្រាន់តែហៅតាម

គាត់តែប៉ុណ្ណោះ។ កងខ្ញុំនៅលេខ៤គ គឺជាកងចំណុះមិនទាន់មានការបែងចែកជាកងពលនៅឡើយ។ បន្ទាប់ពីចប់វគ្គហ្វឹកហ្វឺន អង្គការបានបែងចែកកម្លាំងតាមក្រសួងនានាដែលត្រូវការ ហើយអង្គការគឺជាអ្នកសម្រេចចិត្តថាអ្នកត្រូវចាត់តាំងទៅខាងទ័ព អ្នកណាត្រូវទៅខាងក្រសួងសង្គមកិច្ច ឬទៅខាងភ័ស្តុភារ។ នៅក្នុងសាលាស-២០០ មានបែងចែកផ្នែកផ្សេងៗជាច្រើន។ បើទោះបីជាខ្ញុំរៀនខាងយោធា ប៉ុន្តែអង្គការបានបែងចែកខ្ញុំទៅខាងសង្គមកិច្ច។

នៅឆ្នាំ១៩៧៦ ខ្ញុំមកនៅផ្នែកសង្គមកិច្ចមន្ទីរ ព-២ ដែលមានទីតាំងនៅជ្រោយចង្វារ ទីក្រុងភ្នំពេញ។ នៅទីនោះខ្ញុំមាននាទីគឺជាប្រធានក្រុម។ ខ្ញុំចូលរៀនវគ្គបណ្តុះបណ្តាលនយោបាយនៅសាលាវិជ្ជាជាន់ខ្ពស់ មានទីតាំងនៅខាងលិចផ្លូវពោធិ៍ចិនតុង។ នៅក្នុងវគ្គបណ្តុះបណ្តាល សមាជិកមន្ទីររបស់ខ្ញុំចូលរួមចំនួន១០នាក់ ហើយមានកម្មាភិបាលប្រមាណជា ១០០ទៅ២០០នាក់ មកពីច្រើនភូមិភាគផ្សេងគ្នា រួមមានភូមិភាគបស្ចិម ភូមិភាគនិរតី ភូមិភាគពាយ័ព្យ ភូមិភាគឧត្តរ ភូមិភាគឦសាន និងភូមិភាគបូព៌ា។ នួន ជា និង អៀង ធីរិទ្ធិ គឺជាអ្នកបង្រៀនវគ្គនយោបាយនេះ។ អៀង ធីរិទ្ធិបង្រៀនជារៀងរាល់ឆមាស និងត្រីមាស។ ទីតាំងខ្ញុំធ្លាប់ចូលរៀនវគ្គបណ្តុះបណ្តាលនយោបាយមាននៅមន្ទីរពេទ្យកាល់ម៉ែត្រ និងស្ថានីយ៍រថភ្លើង។ ខ្ញុំធ្លាប់រៀនវគ្គនយោបាយ ៤ទៅ៥ដង។ នៅពេលព្រឹកយើងរៀនរយៈពេល២ទៅ៣ម៉ោង ដោយបំពាក់បំប៉ននយោបាយទ្រឹស្តី។ នៅក្នុងមួយថ្ងៃកម្មាភិបាលទាំងអស់ចូលរៀនពីរវេន គឺពេលព្រឹកចាប់ផ្តើមម៉ោង៧ ដល់ម៉ោង១១ និងពេលរសៀលដល់ម៉ោង៤កន្លះទើបសម្រាក។ ជួនកាលនៅថ្ងៃបិទវគ្គ អង្គការសម្តែងសិល្បៈឲ្យសិក្ខាកាមមើល រួចត្រឡប់មកធ្វើការរៀងខ្លួន។ នៅក្នុងមន្ទីរព-២ ខ្ញុំកាន់ខាងធ្វើអំពូលសម្រាប់ដាក់ថ្នាំពេទ្យ។ ការងារធ្វើអំពូលនេះពិបាកត្រង់ថា នៅពេលដែលយើងរៀបឡ គឺចាំបាច់រកឥដ្ឋដែលធន់នឹងកម្តៅខ្លាំងទើបអាចទប់ការប្រេះបែក ហើយយើងដុតកម្តៅនៅសីតុណ្ហភាពខ្ពស់បំផុត។ ក្រុមខ្ញុំខាងរៀបឡ មានសមាជិក១០នាក់ គឺស្រី៥នាក់ និងប្រុស៥នាក់។ របៀបនៃការធ្វើអំពូលកែវដំបូងត្រូវយកអំបែងដបឈប់ប្រើដែលយើងប្រមូលបាន ហើយយកទៅដាក់ក្នុងឡធំមួយ។ យើងយកប្រេងចំណុះចំនួន២០០ ទៅ ៣០០លីត្រចាក់ចូលក្បាលបូមមានរន្ធប៉ុនមេដៃ ហើយបាញ់បញ្ចូលទៅក្នុងឡរយៈពេល១ម៉ោងទៅ២ម៉ោង អំបែងដបនៅពេលក្តៅដល់សីតុណ្ហភាពរលាយ ហូរដូចទឹកទើបអាចប្រើបាន។ យើងមានបំពង់ដែកមួយប៉ុនមេដៃប្រវែងមួយម៉ែត្រ ជាងរួចយកមកផ្លុំដោយមានរបៀបនៃការផ្លុំ បើអ្នកមិនចេះផ្លុំ ផ្លុំមិនចេញជារូបរាងដបកែវទេ។ ពេលផ្លុំកែវហើយ យើងយកកែវមកកាត់តាមប្រវែងកំណត់ រួចគវ៉ាទុកម្តុំៗ។ ដបថ្នាំដែលយើងផលិតបានសម្រាប់ប្រើតែនៅក្នុងមន្ទីរពេទ្យព-២ និងទុកដាក់ថ្នាំអាសន្នរោគ គោក្របី តែប៉ុណ្ណោះ ចំណែកថ្នាំប្រើលើមនុស្ស គឺមានដបដែលស្មើពីខាងក្រសួង។ ពេលខ្លះអង្គការហៅសមាជិកក្រុមរបស់ខ្ញុំគ្នា៤ទៅ៥នាក់ ទៅធ្វើថ្នាំ។ យើងចូលធ្វើថ្នាំមួយលើកៗមានរយៈពេល២ទៅ៣ម៉ោង ទើបចេញមកវិញ។ ការងារធ្វើថ្នាំមិនទៀងទាត់ទេ ជួនកាល១អាទិត្យ ឬជួនត្រឹមតែ៣ថ្ងៃប៉ុណ្ណោះ។ ថ្នាំដែលមន្ទីរព-២ធ្វើគឺថ្នាំមេរោគអុត គោ-ក្របី។ ថ្នាំទាំងនោះបានមកពីការធ្វើពិសោធន៍លើ គោ ក្របី និង មនុស្ស។ ថ្នាំប៉ុវ៉ាក់សាំងដែលអង្គភាពខ្ញុំបណ្តុះបានយកមកព្យាបាលអ្នកជំងឺនិងមានប្រសិទ្ធភាពយ៉ាងខ្លាំង។ នៅពេលមានអ្នកជំងឺកើតអាសន្នរោគ ហើយអង្គការហៅប្រជាជនទៅចាក់ដើម្បីទប់ស្កាត់កុំឲ្យរីករាលដាលខ្លាំងឡើង។ តាវ៉ែន គឺជាអ្នកក្តាប់ខាងមន្ទីរពិសោធន៍ និងមានគណៈមន្ទីរឈ្មោះ សុវណ្ណ។ តាវ៉ែន មិនបានរៀនសូត្រខ្ពស់ទេ ប៉ុន្តែគាត់ធ្លាប់ដើរបកប្រែភាសាឲ្យបារាំង ហើយបារាំងឲ្យគាត់ដើរមើលការស្រាវជ្រាវនៅកន្លែងពិសោធន៍មន្ទីរពេទ្យប៉ាស្ទ័រ ដូចជាការធ្វើថ្នាំ។ តាវ៉ែន ពូកែចំណាំប្រភេទថ្នាំ និងរបៀបពិសោធន៍។ ខ្ញុំធ្លាប់រៀនសូត្រពីតា តាវ៉ែន

បានតិចតួច ហើយខ្ញុំចេះភាសាបារាំងបានតិចៗប៉ុណ្ណោះ។ ពេលរៀនម្តងៗ អង្គការសរសេរអក្សរចំណាំជាភាសាបារាំងលើថ្នាំឲ្យយើងមើល។ នៅពេល តាវិន ពិសោធន៍ថ្នាំប៉ូវ៉ាក់សាំងម្តងៗ ខ្ញុំបានឃើញបរទេសដូចជា កូរ៉េ ចុះមកមើលមួយខែម្តង។

នៅក្នុងឆ្នាំ១៩៧៧ ក្រុមរបស់ខ្ញុំបានផ្លាស់មកមន្ទីរ ព-៣ ដើម្បីលត់លំ បន្ទាប់ពីគណៈមន្ទីរ សុវណ្ណ ត្រូវបានចាប់ខ្លួនដោយអង្គការចោទថាក្បត់។ ខ្ញុំបានដឹងដំណឹងពីការចាប់ខ្លួន សុវណ្ណ តាមរយៈអ្នកធ្វើការនៅក្នុងមន្ទីរជាមួយគ្នា។ សុវណ្ណ គឺជាអ្នកស្រុកកោះសូទិន។ ប្រហែលជានៅពេលរសៀល ខែមិថុនា ឬខែកក្កដា អង្គការបានហៅគាត់ និងគ្រួសារទាំងអស់។ នៅពេលនោះ អង្គការបានហៅគ្រប់មន្ទីរទៅប្រជុំដែរ។ អៀង ធីរិទ្ធ និយាយថា «សុវណ្ណ ក្បត់នឹងអង្គការ រួមជាមួយធុច ក៏ក្បត់ដែរ។ អង្គការឲ្យគាត់រៀនសូត្រ និងឲ្យគាត់កែប្រែខ្លួន»។ នៅមន្ទីរព-៣ យើងត្រូវលត់ដំដោយលើកដីទប់ភ្លឺស្រែប្រាំង។ អ្នកដែលផ្លាស់ទៅមន្ទីរព-៣ ជាមួយខ្ញុំប្រហែលជា២០នាក់។ អង្គភាពខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើស្រែ៤ទៅ៥ហិកតា។ នៅទីនោះមានត្រពាំងមួយធំ ហើយអង្គការប្រាប់ថាស្រូវធ្វើទុកចិញ្ចឹមសត្វ។ ខ្ញុំនៅចាំកាលនោះខ្ញុំលើកភ្លឺអែបៗផ្ទះ ១០០ខ្នង ហើយមានផ្លូវរទេះភ្លើងនៅជិតនោះ។ ខ្ញុំចាំមិនភ្លេច «ពេលមួយនៅពេលដល់ខែទឹកជន់ ចំពេលស្រូវទុំ ក្រុមរបស់ខ្ញុំប្រូតស្រូវមិនទាន់ក៏លិចស្រូវអស់។ អង្គការចោទថា ក្រុមខ្ញុំបំផ្លាញបដិវត្តន៍ តាមពិតខ្ញុំខំប្រឹងធ្វើការហត់នឿយស្ទើរស្លាប់។ យើងយកម៉ាស៊ីនមកបូមទឹកចេញ ប៉ុន្តែនៅតែបូមមិនទាន់»។ ទោះអង្គការមិនបានយកខ្ញុំទៅរៀនសូត្រ ប៉ុន្តែខ្ញុំបានក្លាយជាមុខសញ្ញារបស់អង្គការ។ នៅមន្ទីរព-៣ គឺជាអង្គភាពព្យាបាលជំងឺទូទៅ។ ខ្ញុំឃើញអង្គភាពនោះផលិតថ្នាំសុលកូនក្មេង និងថ្នាំជាច្រើនប្រភេទ ព្រមទាំងមានឃ្លាំងសម្រាប់ទុកថ្នាំ។ ខ្ញុំចូលរៀនវគ្គនយោបាយនៅបុរីកីឡាបានប្រហែលជា២ទៅ៣ដងជាមួយ នួន ជា។ នួន ជា និយាយអំពីការកសាងប្រទេស និងការពារប្រទេសឲ្យបានជឿនលឿនមហាលោតផ្លោះមហាអស្ចារ្យ។ អង្គការមានឡានមកដឹកខ្ញុំពីមន្ទីរ និងជូនទៅមកដោយមានរៀបចំបាយ ទឹកឲ្យហូប។ ថ្ងៃខ្លះបន្ទាប់ពីរៀននយោបាយជាមួយ នួន ជា ហើយ គាត់ប្រាប់ថា «មិត្តអើយ នាំគ្នាជិះរថភ្លើងមួយស្របក់ទៅ» យើងនាំគ្នាឡើងជិះរ៉ារថភ្លើងប្រហែលជាកន្លះម៉ោង ទើបត្រឡប់មកវិញ។

នៅក្នុងឆ្នាំ១៩៧៨ ខ្ញុំផ្លាស់មកមន្ទីរព-១ ពេទ្យកាល់ម៉ែត្រវិញ។ មុនដំបូងអង្គការប្រាប់ថាឲ្យមកជួសជុលមន្ទីរពេទ្យ ដោយក្រុមប្រុសៗមកមុន។ អង្គការប្រាប់ថាឲ្យមកតែមួយថ្ងៃប៉ុណ្ណោះ។ ប៉ុន្តែគណៈមន្ទីរឲ្យនៅមន្ទីរព-១ តែម្តងដោយសារខ្ញុំចេះខាងសំណង់។ គណៈមន្ទីរថាបើខ្ញុំទៅវិញមិនមានអ្នកណាជួសជុលអគារចាស់ៗទេ។



រោងចក្រផលិតដប នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ កម្មករកំពុងផ្លុំដប ខែសីហា ឆ្នាំ១៩៧៨។
( ហ្គុនណា បឺយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា )

យើងជួសជុលផ្ទះ មន្ទីរពេទ្យ និង ពិនិត្យមើលអ្នកធ្វើការនៅក្នុងមន្ទីរ អ្នកណាដើរចេញអ្នកណាដើរចូលចំនួនប៉ុន្មាននាក់ ដើម្បីឲ្យដឹងចំនួនៗ ខ្ញុំមានគ្នា១០នាក់ត្រួតពិនិត្យលើការងារនេះ។ ពេលព្រលឹមខ្ញុំជិះកង់ទៅឈរមើលពីចម្ងាយនៅចំណតរទេះភ្លើង ឃើញមានអ្នកជម្លៀសភាគច្រើនមកពីស្រុកប្រសូត្រ និងស្រុកចន្ទ្រា ស្វាយរៀង។ ខ្ញុំបានដើរទៅសួរប្រជាជនដែលអង្គការបញ្ជូនមកនៅជុំវិញផ្សារថ្មីមានទាំងចាស់ និងក្មេងៗ។ ព្រលឹមឡើងអង្គការបញ្ជូនអ្នកទាំងនោះតាមរថភ្លើងទៅនៅដីខ្លាញ់។ ក្មេងស្រីម្នាក់ស្គាល់ខ្ញុំនៅកន្លែងមន្ទីរសង្គមកិច្ចយំពេលឃើញខ្ញុំ។ ក្មេងស្រីនោះផ្តាំខ្ញុំឲ្យប្រាប់ម៉ែឪគាត់ផង ព្រោះគាត់ចេញទៅដីខ្លាញ់មិនដឹងស្លាប់ឬរស់ទេ។ ខ្ញុំមិនដឹងជួយក្មេងនោះយ៉ាងណាទេ ខ្ញុំតបថាចាំអ៊ំជួយប្រាប់។ ការជម្លៀសប្រជាជនតាមរថភ្លើងក្នុងមួយថ្ងៃ៥០០នាក់។ នៅមន្ទីរព-១ ពេទ្យចំនួន១៥០នាក់ និងមានអ្នកជំងឺប្រមាណជា ៣០០នាក់ រួមមានកុមារ និងស្ត្រីសម្រាលកូនៗ មន្ទីព-១ឬហៅថា «ពេទ្យកុមារ» មានអ្នកជំងឺមកពីខេត្តមណ្ឌលគិរីដែរ។ ថ្ងៃមួយ ខ្ញុំបានដឹងដំណឹងតាមអ្នកបើកបររថយន្តអំពីការបោសសម្អាតនៅភូមិភាគបូព៌ា។ អ្នកបើករថយន្តនិយាយប្រាប់ខ្ញុំថា «នៅ ខាងភូមិភាគបូព៌ា ឥឡូវអង្គការសម្លាប់អស់ច្រើនណាស់ ឲ្យតែអ្នកតំបន់ ២០ សម្លាប់អស់»។ ពេលខ្ញុំឮដំណឹងនេះ ខ្ញុំជឿខ្លះមិនជឿខ្លះ។ ខ្ញុំចង់ទៅលេងផ្ទះ ទោះបីជាអង្គការសម្លាប់ក៏ដោយ គឺខ្ញុំសុំទៅលេងផ្ទះឲ្យទាល់តែបាន។ ពេលមួយ ខ្ញុំអង្គុយរៀននៅបន្ទប់ផ្ទាល់ដីនៅមន្ទីរពេទ្យកាល់ម៉ែត្រ ខ្ញុំសម្រេចចិត្តសុំបងៗ គណៈសាលាដោយប្រាប់ថា «ខ្ញុំសុំទៅលេងផ្ទះ២ទៅ៣ថ្ងៃ»។ ប៉ុន្តែគណៈសាលាមិនបានឆ្លើយតបជាមួយខ្ញុំទេ។ ខ្ញុំមកកន្លែងស្នាក់នៅវិញ។ ថ្ងៃមួយពេលខ្ញុំក្រោកពីដេកមិនទាន់លុបលាងមុខផង មានទូរស័ព្ទពីកន្លែងធ្វើការខ្ញុំប្រាប់ខ្ញុំថាឲ្យខ្ញុំទៅជួបមួយភ្លែត។ ពេលនោះខ្ញុំភ័យបុកពោះ ព្រោះគិតថាខ្ញុំបានធ្វើអ្វីខុសហើយ តាមពិតបងៗអនុញ្ញាតច្បាប់ឲ្យខ្ញុំទៅលេងផ្ទះ។ លិខិតធ្វើដំណើរទៅលេងស្រុក សរសេរថ្ងៃផុតកំណត់ធ្វើដំណើរ មានឈ្មោះខ្ញុំ និងត្រកូលរបស់ខ្ញុំ។ នៅក្នុងសំបុត្រមានចុះហត្ថលេខារបស់ នួនជា និង ប៉ោះ ត្រាជាសេនាធិការក្រុងភ្នំពេញ។ ខ្ញុំសុំអនុញ្ញាតច្បាប់រយៈពេល១៥ថ្ងៃ ប៉ុន្តែក្នុងសំបុត្រសរសេរថាផុតកំណត់ក្នុងរយៈពេល ១០ថ្ងៃទៅវិញ ដោយសំបុត្រសរសេរខុស។ នៅតាមផ្លូវយោធាសុំមើលសំបុត្រ ហើយប្រាប់ខ្ញុំថា សំបុត្រនេះហួសកំណត់ រួចបានចាប់ខ្ញុំឃុំខ្លួនមួយយប់។ ខ្ញុំបានតវ៉ាអំពីសំបុត្រនេះទើបអ្នកត្រួតពិនិត្យដោះលែងខ្ញុំ។ ខ្ញុំជិះកង់មកតាមផ្លូវដល់ផ្សារអូររាំងឪ ឃើញយោធាខ្មែរក្រហមដាក់រាំងផ្លូវមិនឲ្យចូល។ ខ្ញុំជិះវៀងទៅតាមផ្លូវមួយផ្សេងទៀត អ្នកភូមិប្រាប់ថាយោធាវាយមនុស្សម្នាក់ចូលទៅក្នុងអណ្តូងជាច្រើន។ ខ្ញុំឃើញយោធាឈរត្រៀបតាមផ្លូវដោយដៃកាន់កាំភ្លើងជាប់រហូត។ ខ្ញុំសុំយោធាជិះកាត់ដោយខ្ញុំប្រាប់ថា «ខ្ញុំសុំទៅផង» ទើបយោធាឲ្យខ្ញុំធ្វើដំណើរបន្តទៅមុខ។ ខ្ញុំមកដល់ផ្ទះនៅវេលាម៉ោង ៦ ល្ងាច។ នៅស្រុកកញ្ជៀចប្រធានសហករណ៍មានឈ្មោះ ណោ , ឈិត និង គ្រេន។ បងគ្រេនបានចាត់តាំងខ្ញុំឲ្យធ្វើខាងនេសាទ និងមិនឲ្យខ្ញុំត្រឡប់មកអង្គភាពវិញទេ ព្រោះខ្លាចយួនសម្លាប់។ ខ្ញុំនៅរកត្រីបានរយៈពេលប្រហែលជាកន្លះខែ អង្គការជម្លៀសអ្នកភូមិទៅដីខ្លាញ់។ ខ្ញុំឃើញយោធាស្រុកមកពីខេត្តកណ្តាល និងកំពង់ចាម ក្នុងគោលបំណងកៀរយើងទៅ ខាងកំពង់ចាមវិញ។ មុនជម្លៀសចេញទៅ បងប្អូនខ្ញុំកាប់ផ្លែដូងដាក់ប៉ោតទុកដឹក។ បងគ្រេន ប្រធានសហករណ៍និយាយថា «បើងាប់ គឺងាប់ទាំងអស់គ្នា កុំរត់ចោលគ្នា។ ខ្ញុំបាននិយាយថា «បងឯងមិនរត់ ខ្ញុំក៏មិនរត់ដែរ»។ នៅពេលព្រឹកឡើងស្រាប់តែមានការផ្ទុះអាវុធគឺកងទ័ពវៀតណាមចូលមកដល់ស្រុកកំចាយមារ ដូច្នេះយើងចំនួន៥គ្រួសារមិនបានជម្លៀសទៅដីខ្លាញ់ទេ។ ខ្ញុំបន្តរស់នៅស្រុកកំណើត បន្ទាប់ពីរបបខ្មែរក្រហមដួលរលំដោយប្រកបមុខរបរធ្វើស្រែបន្តិចបន្តួច។

# ង៉ា យ៉ែម ៖ ខ្មែរក្រហមបង្ខំឱ្យខ្ញុំសឹក ដើម្បីចូលធ្វើយោធា

*ភា រស្មី*



*ង៉ា យ៉ែម រស់នៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

យ៉ែម មានស្រុកកំណើតនៅក្នុងភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ សព្វថ្ងៃ យ៉ែម រស់នៅជាមួយប្រពន្ធបងថ្លៃ ក្មួយ និងចៅពីរនាក់។ គ្រួសាររបស់ យ៉ែម ធ្វើស្រែចម្ការ ដាំដំណាំបន្តិចបន្តួចនៅជុំវិញផ្ទះ សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ក្រៅពីប្រកបរបរធ្វើស្រែចម្ការ យ៉ែម គឺជាអាចារ្យរៀបចំរៀលាការ និងអាពាហ៍ពិពាហ៍របស់ប្រជាជននៅក្នុងភូមិ។ ពេលបច្ចុប្បន្ននេះ ដោយសារតែមានការរីករាលដាលនៃជំងឺកូវីដ-១៩ ទើបធ្វើឲ្យការងារជាអាចារ្យរៀបចំរៀលាការ និងអាពាហ៍ពិពាហ៍មិនសូវមានញឹក។

នៅក្រោមផ្ទះដែលមានគ្រាប់ពូជស្រូវជាច្រើនបាវ និងមានរុក្ខជាតិលម្អនៅជុំវិញផ្ទះ យ៉ែម រៀបរាប់ថា ពេលខ្ញុំអាយុ៨ឆ្នាំ នៅឆ្នាំ១៩៦២ ខ្ញុំចូលរៀននៅវត្តសិរីឧត្តមរយៈពេលមួយឆ្នាំ។ ខ្ញុំរៀនដល់ថ្នាក់ទី ៨ ក៏កើតមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ចេញពីតំណែងប្រមុខរដ្ឋ ដូច្នេះ សិស្សានុសិស្សនៅក្នុងភូមិ រួមទាំងរូបខ្ញុំបានឈប់រៀន ដោយសារប្រទេសជាតិចាប់ផ្ដើមកើតមានសង្គ្រាម។

បន្ទាប់ពីថ្ងៃ១៨ មីនា ឆ្នាំ១៩៧0 សម្ដេចព្រះ នរោត្តម សីហនុ ប្រកាសតាមវិទ្យុពីក្រៅប្រទេសឲ្យកូនចៅទាំងអស់ចូលព្រៃម៉ាគី ដណ្ដើមអំណាចឲ្យព្រះអង្គ ហើយព្រះអង្គនឹងយាងត្រឡប់ចូលប្រទេសវិញ។ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំមួយចំនួនរត់ចូលព្រៃធ្វើបដិវត្តន៍ និងមួយចំនួនទៀតរត់ចូលទៅតំបន់ដែលគ្រប់គ្រងដោយ

លន់ នល់ ហើយអ្នកនៅសេសសល់បន្តរស់នៅក្នុងភូមិដដែល។ នៅក្នុងភូមិរបស់ខ្ញុំចាប់ផ្តើមមានការប្រយុទ្ធគ្នាជាបន្តបន្ទាប់រវាងកងទ័ពបដិវត្តន៍ខ្មែរក្រហមជាមួយទាហាន លន់ នល់។ កងទ័ពបដិវត្តន៍ខ្មែរក្រហមសហការជាមួយវៀតណាមខាងជើង (ត្រូវបានស្គាល់ថា វៀតកុង) ហើយកងទ័ព លន់ នល់ រួមដៃជាមួយវៀតណាមខាងត្បូង (ត្រូវបានស្គាល់ថា ធីវគី)។ នៅពេលនោះ ប្រជាជនដែលរស់នៅក្នុងភូមិរោង ឃុំចាម ទាំងអស់មានការលំបាកយ៉ាងខ្លាំង ដោយសារភូមិរោងប្រែទៅជាសមរភូមិប្រយុទ្ធ ហើយប្រជាជនក្នុងភូមិមួយចំនួនទទួលរងការធ្វើបាបពីសំណាក់កងទ័ពវៀតណាមខាងត្បូង ពេលចូលមកក្នុងភូមិម្តងៗ។

នៅឆ្នាំ១៩៧១ ដោយសារតែមានការប្រយុទ្ធគ្នាកាន់តែខ្លាំង ប្រជាជនទាំងអស់ភៀសខ្លួនចេញពីភូមិរោង។ អ្នកភូមិ រួមទាំងគ្រួសាររបស់ខ្ញុំរត់ចូលទៅតំបន់ លន់ នល់ គ្រប់គ្រង និងមួយចំនួនទៀតរត់ចូលទៅតំបន់រំដោះរបស់ខ្មែរក្រហម។ ខ្ញុំបានបួសជាព្រះសង្ឃនៅក្នុងវត្តព្រៃពោន ទើបខ្ញុំអាចបន្តការរៀនសូត្រតទៅទៀត។ ខ្ញុំរៀនរយៈពេលត្រឹមតែ៣ខែ កងទ័ពបដិវត្តន៍ខ្មែរក្រហមវាយចូលមកទៀត។ រហូតដល់ឆ្នាំ១៩៧២ កងទ័ពបដិវត្តន៍ខ្មែរក្រហមទទួលជ័យជម្នះទៅលើទាហាន លន់ នល់ និងចូលគ្រប់គ្រងនៅក្នុងឃុំព្រៃពោន។ នៅឆ្នាំ១៩៧៤ ដោយសារមានការបង្ខិតបង្ខំកងទ័ពបដិវត្តន៍ខ្មែរក្រហម ខ្ញុំរួមជាមួយព្រះសង្ឃក្មេងៗជាច្រើនអង្គទៀតនៅក្នុងវត្ត សម្រេចចិត្តលាចាកសិក្ខាបទ លើកលែងតែព្រះសង្ឃដែលមានអាយុច្រើនប៉ុណ្ណោះ ដែលអាចនៅតស៊ូបួសបន្តទៀត។ បន្ទាប់ពីសឹករួច កងទ័ពបដិវត្តន៍ខ្មែរក្រហម បង្ខំឲ្យខ្ញុំចូលបម្រើជាយោធា និងបានបញ្ជូនខ្ញុំឲ្យទៅរៀនក្បួនយុទ្ធសាស្ត្រទ័ពនៅស្រុកព្រះស្តេច។ ចំណែកប្អូនរបស់ខ្ញុំម្នាក់ឈ្មោះ វ៉ា យ៉ន នៅធ្វើជាយោធាក្នុងស្រុកកំពង់ត្របែក។ ក្រោយពីរៀនក្បួនយុទ្ធសាស្ត្រទ័ពរយៈពេល៣ខែ កងទ័ពបដិវត្តន៍ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យចូលធ្វើជាយោធាតំបន់២៤។ យោធាតំបន់២៤ ឈរជើងនៅក្នុងស្រុកព្រះស្តេច ហើយខ្ញុំឡើងវាយប្រយុទ្ធជាមួយទាហាន លន់ នល់ ជាច្រើនលើក។

នៅដើមឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍ខ្មែរក្រហមវាយឈ្នះ ទាហាន លន់ នល់ ជាបន្តបន្ទាប់ ចំណែកអង្គភាពរបស់ខ្ញុំវាយយកតំបន់អ្នកលឿង។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍ខ្មែរក្រហមយកជ័យជម្នះលើតំបន់គ្រប់គ្រងរបស់របប លន់ នល់ នៅតាមបណ្តាស្រុក និងដណ្តើមយកក្រុងភ្នំពេញទាំងស្រុង។ ខ្មែរក្រហមបញ្ជូនក្រុមរបស់ខ្ញុំឲ្យមកឈរជើងនៅស្រុកព្រះស្តេច ក្នុងគោលបំណងការពារតាមបណ្តោយព្រំដែនកុំឲ្យវៀតណាមចូលឈ្លានពាន។ នៅខណៈនោះ ប្រជាជនជាច្រើននាក់ត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ ហើយប្រជាជនជម្លៀសជាច្រើនគ្រួសារបានមករស់នៅជាមួយប្រជាជនមូលដ្ឋាននៅក្នុងភូមិ និងជិតអង្គភាពរបស់ខ្ញុំឈរជើង។ ខ្ញុំឃើញយោធាខ្មែរក្រហមចាប់ទាហាន លន់ នល់ ជាច្រើននាក់ដែលជាឈ្លើយសឹក ហើយប្រើឲ្យធ្វើការងារធ្ងន់ធ្ងរដូចជា ជីកប្រឡាយ លើកទំនប់ និងការងារធ្វើការងារផ្សេងទៀតដូចជាសត្វធាតុ។ ខ្មែរក្រហមមិនបាញ់សម្លាប់ឈ្លើយសឹកទាំងអស់នោះទេ គឺអ្នកទាំងនោះឲ្យស្លាប់ដោយជំងឺ ការអត់អាហារ និងការធ្វើការងារហួសកម្លាំង។

នៅទីនោះខ្មែរក្រហមចាត់ក្រុមរបស់ខ្ញុំឲ្យធ្វើការងារលើកទំនប់ ជីកប្រឡាយនៅរដូវប្រាំង ហើយនៅរដូវវស្សា ធ្វើស្រែ និងភ្ជួររាស់ ស្ថិតនៅក្បែរព្រំដែន។ ខ្មែរក្រហមផ្តល់អាហារមួយចានក្នុងមួយពេល។ ខ្ញុំហូបមិនឆ្អែតទេ ហើយត្រូវធ្វើការងារធ្ងន់ៗ ជារៀងរាល់ថ្ងៃ។ នៅចុងឆ្នាំ១៩៧៦ ខ្ញុំឮដំណឹងថាកងទ័ពវៀតណាមវាយចូលក្នុងស្រុកកំពង់ត្របែក បណ្តាលឲ្យយោធាខ្មែរក្រហមជាច្រើននាក់រងរបួស និងស្លាប់។

នៅឆ្នាំ១៩៧៧ អង្គការដាក់គោលនយោបាយថ្មីគឺវាយចូលប្រទេសវៀតណាមតាមព្រំដែន នៅក្នុងតំបន់២៤ ប៉ុន្តែមិនទទួលបានជោគជ័យឡើយ។ អំឡុងពេលនោះ ខ្ញុំឮដំណឹងថា សោ ភឹម ក្បត់អង្គការ ហើយអង្គការកំពុងតាមចាប់ខ្លួន។ ក្រោយមកក៏បានឮដំណឹង សោ ភឹម ធ្វើអត្តឃាត។ បន្ទាប់ពីហេតុការណ៍នោះ យោធាខ្មែរក្រហមមកពីខាងភូមិភាគនិរតីដឹកនាំដោយ តាម៉ុក ចូលមកគ្រប់គ្រងនៅភូមិភាគបូព៌ា ហើយប្រធានវរសេនាតូចធំនៅខាងភូមិភាគបូព៌ាជាច្រើននាក់ត្រូវចាប់យកទៅសម្លាប់ ជាពិសេសអ្នកដែលធ្លាប់ទៅរៀនសូត្រនៅ

ប្រទេសវៀតណាម។ នៅអំឡុងខែឧសភា និងមិថុនា ឆ្នាំ១៩៧៨ កងទ័ពវៀតណាមវាយចូលមកទឹកដីកម្ពុជាម្តងទៀត និងសម្លាប់យោធាខ្មែរក្រហមជាច្រើននាក់។ ប៉ុន្តែក្រោយមកក៏ដកថយទៅវិញ។ នៅពេលកងទ័ពវៀតណាមវាយចូលមកម្តងទៀត ខ្ញុំឃើញមានការចែកចាយខិត្តប័ណ្ណជាច្រើនសន្ធឹកមានរូប ប៉ុល ពត និងមានសរសេរអក្សរដែលមានអត្ថន័យថា ប៉ុល ពត គឺជាបិសាច។ នៅពេលនោះ ខ្ញុំមិនហ៊ាននិយាយទាក់ទងនឹងរូប ប៉ុល ពត នៅក្នុងខិតប័ណ្ណទេ ព្រោះខ្លាចខ្មែរក្រហម។

នៅដើមខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលយ៉ាងម្តងទៀត បណ្តាលឲ្យខ្ញុំ និងយោធាខ្មែរក្រហមផ្សេងទៀតបាក់ទ័ព និងរត់ទៅកាន់ខេត្តភាគខាងលិច។ នៅពេលរត់ទៅដល់ភ្នំស្រង់ ក្នុងខេត្តកំពង់ស្ពឺ ខ្ញុំ និងសមាជិកនៅក្នុងអង្គភាពចំនួន១២នាក់ សម្រេចចិត្តចុះចូលជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលគាំដោយវៀតណាម ព្រោះយើងគិតថានឹងស្លាប់ ប្រសិនបើយើងរត់ចូលព្រៃបន្តទៀត។ បន្ទាប់ពីចុះចូលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបញ្ជូនយើងឲ្យមករៀនសូត្របីថ្ងៃ នៅចាក់អង្រែ ក្នុងទីក្រុងភ្នំពេញ។ តាមពិត យើងមិនបានរៀនសូត្រអ្វីទេ គឺយើងនៅសម្រាកឲ្យគ្រប់ចំនួនថ្ងៃដែលកំណត់។ នៅថ្ងៃចុងក្រោយ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាមកសាកសួរអំពីចំណាប់អារម្មណ៍របស់យើងថា ចង់ចូលធ្វើជាកងទ័ពវិញ ឬក៏ត្រឡប់ទៅផ្ទះ? ខ្ញុំនិងសមាជិកនៅក្នុងក្រុមសម្រេចចិត្តត្រឡប់ទៅផ្ទះវិញ។ ខ្ញុំនិងសមាជិកនៅក្នុងក្រុមបានទទួលស្បៀងអាហារសម្រាប់ការធ្វើដំណើរ និងចែកផ្លូវគ្នាដើម្បីទៅរស់នៅស្រុកកំណើតរៀងៗខ្លួន។ នៅតាមផ្លូវខ្ញុំបានយកអង្ករដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចែកឲ្យ ទៅដូរជាមួយនំ និងផ្លែឈើតាមផ្លូវហូបរហូតដល់ផ្ទះ។ ខ្ញុំចំណាយពេលចំនួន២ថ្ងៃ ដើម្បីដើរពីភ្នំពេញទៅស្រុកកំពង់ត្របែក ដោយរួមដំណើរជាមួយប្រជាជនដែលដើរត្រឡប់ទៅស្រុកកំណើតនៅស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង។ ប្រជាជននៅខេត្តស្វាយរៀងភាគច្រើនអង្គការជម្លៀសទៅខេត្តពោធិ៍សាត់ និងបាត់ដំបង។ ពេលខ្ញុំធ្វើដំណើរមកដល់ផ្ទះ ខ្ញុំបានជួបជាមួយឪពុកម្តាយបងប្អូនរបស់ខ្ញុំទាំងអស់នៅក្នុងភូមិ លើកលែងតែប្អូនប្រុសរបស់ខ្ញុំម្នាក់ដែលចូលធ្វើជាយោធាខ្មែរក្រហមបាត់ដំណឹងរហូតមកដល់បច្ចុប្បន្ន។ ខ្ញុំឃើញប្រជាជននៅក្នុងភូមិរោងនាំគ្នាទៅសែងផ្ទះរបស់ខ្លួននៅភូមិផ្សេងៗត្រឡប់មកវិញ ព្រោះក្នុងសម័យខ្មែរក្រហមក្នុងភូមិរោងជាសមរភូមិប្រយុទ្ធ ដូច្នេះប្រជាជនមិនអាចរស់នៅបានទេ។ ក្រោយមកប្រជាជននៅក្នុងភូមិចាប់ផ្តើមសាងសង់វត្តអារាម សាលារៀន មន្ទីរពេទ្យ និងផ្សារលក់ដូរ។ រហូតមកដល់ឆ្នាំ១៩៨២ ខ្ញុំបានរៀបការជាមួយប្រពន្ធរបស់ខ្ញុំ និងបានរួមរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃ។



ស្ត្រី ជិះកង់នៅលើ ភ្លឺ ប្រឡាយ ស្ថិតនៅក្នុងឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី / មជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!















# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ារដ្ឋ មេត្តា

(តពីលេខមុន)

៦១៥. *នៅក្នុងដំណើរការនៃការស្រាវជ្រាវប្រវត្តិសាស្ត្ររបស់ខ្លួន អ្នកជំនាញលោក* Philip SHORT *និងលោក* David CHANDLER *ពុំបានរកឃើញឯកសារណាមួយដែលបញ្ជាក់ថា ខៀវ សំផន ជំនួសតំណែងរបស់ឌឿនជាប្រធានមន្ទីរ៨៧០ ឡើយ។ ក៏ប៉ុន្តែលោក* Philip SHORT *បានថ្លែងប្រាប់អង្គជំនុំជម្រះថា ផ្អែកលើឯកសារនានាដែលលោកបានអាន លោក «មានហេតុផលដែលនាំឲ្យសន្និដ្ឋាន» បានថា ខៀវ សំផន «មានតួនាទីសំខាន់» នៅក្នុងមន្ទីរនោះក្រោយពី ឌឿន ត្រូវបានចាប់ខ្លួន។ លោក* David CHANDLER *ក៏បានសន្និដ្ឋានថា ខៀវ សំផន ជំនួសតំណែង ឌឿន។ ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់មូលដ្ឋានរបស់អ្នកជំនាញក្នុងការទាញសន្និដ្ឋានទាំងនេះ ដែលជាការសិក្សាស្រាវជ្រាវយ៉ាងលម្អិតរបស់អ្នកស្រាវជ្រាវ និងចំណេះដឹងពីកម្ពុជាប្រជាធិបតេយ្យក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះមិនអាចផ្តល់ទម្ងន់សំខាន់ទៅលើ ការស្មានបែបនេះឡើយ នៅពេលពិចារណាទៅលើភស្តុតាងផ្សេងៗទៀតដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹងមុខងារជាក់លាក់របស់ ខៀវ សំផន នៅក្នុងមន្ទីរ៨៧០។*

៦១៦. *ការទទួលខុសត្រូវជាក់លាក់របស់ ខៀវ សំផន នៅក្នុងមន្ទីរ៨៧០ ដែលខុសប្លែកពី ការទទួលខុសត្រូវរបស់អ្នកដែលគ្រប់គ្រងមន្ទីរ៨៧០ ពីមុនឬអ្នកដែលទទួលការតែងតាំងដទៃទៀតនៅតែមានភាពមិនច្បាស់លាស់។ អង្គជំនុំជម្រះបានស្តាប់ភស្តុតាងមួយចំនួនទៀតថា ខៀវ សំផន ចេញលិខិតអនុញ្ញាតធ្វើដំណើរ (លិខិតដើរផ្លូវ) ទៅឲ្យកម្មាភិបាលភូមិភាគដែលគ្រប់គ្រងលើប្រតិភូមកធ្វើទស្សនកិច្ចនិងជាទូទៅ គឺចុះហត្ថលេខាផងដែរ លើលិខិតអនុញ្ញាតឲ្យធ្វើដំណើរទាំងនេះ។ ភស្តុតាងបង្ហាញថា ខៀវ សំផន បំពេញមុខងារជាក់លាក់នៅក្នុងមន្ទីរ៨៧០ ក្រោយពេលដែលប៉ង់ ត្រូវបានចាប់ខ្លួននៅដើមឆ្នាំ១៩៧៧ អាចដោយសារតែទីតាំងគាត់ទៅកាន់មន្ទីរនោះ ឬជាផ្នែកមួយនៃការទទួលខុសត្រូវផ្សេងទៀតក្នុងនាមជាសមាជិកបក្សជាន់ខ្ពស់។ ដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់ទាក់ទងនឹងតួនាទីរបស់ខៀវ សំផន នៅក្នុងមន្ទីរ៨៧០ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានទេថា គាត់បានបំពេញតួនាទីជាប្រធានមន្ទីរ៨៧០ ឬគាត់គ្រាន់តែជា «កម្មាភិបាលដឹកនាំ» នៅក្នុងមន្ទីរនេះ ដូចដីកាដំណោះស្រាយបានចោទប្រកាន់ដែរឬយ៉ាងណានោះ។*

### ៨.៣.៤.២. ការគ្រប់គ្រងពាណិជ្ជកម្ម

៦១៧. *នៅខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍នៃ ប.ក.ក. បានតែងតាំង ខៀវ សំផន ឲ្យទទួលខុសត្រូវផ្នែក «ពាណិជ្ជកម្មខាងបញ្ជីនិងតម្លៃ» បន្ថែមពីនេះលើមុខងារដែលមានស្រាប់របស់គាត់ជាឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិនោះ។ នៅខែមីនា ឆ្នាំ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានតែងតាំង ខៀវ សំផន ទៅក្នុងគណៈកម្មាធិការទទួលបន្ទុក«ពិនិត្យរៀបចំបញ្ជីទំនិញដែលត្រូវទិញ» មកពីប្រទេសចិនរួមជាមួយសមាជិកផ្សេងទៀតដែលមាន អៀង សារី, វន វ៉េត និង ឌឿនក្រោមការ*

ដឹកនាំរបស់ កុយ ធួនៗ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដដែលនោះ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការមួយបន្ថែមទៀតដែលបង្កើតឡើងដើម្បីពិនិត្យ «បញ្ហូធនាគារ» រួមជាមួយ នឹង កុយ ធួន, អៀង សារី និង ឌឿនៗ

**៦១៨**. នៅពេលបើកសម័យប្រជុំសភាតំណាងប្រជាជន នៅថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ «គណៈកម្មាធិការពាណិជ្ជកម្ម» ថ្មីមួយត្រូវបានបង្កើតឡើងដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី វ៉ន វ៉េត ទទួលបន្ទុកខាងសេដ្ឋកិច្ចរួមជាមួយគណៈកម្មាធិការចំនួនប្រាំផ្សេងទៀតៗ គណៈកម្មាធិការនេះត្រូវបានបរិយាយនៅក្នុងកំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថាជាគណៈកម្មាធិការ «នៅជុំវិញមន្ទីរ៨៧០» ដែលធ្វើឡើងនៅមួយសប្តាហ៍បន្ទាប់ពី វ៉ាន់រិត, ព្រុំ ញ៉ែម និង «ឈឿន» ត្រូវបានតែងតាំងជាសមាជិកៗ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ នង សួនហោ ជ័យ ត្រូវបានផ្លាស់ពីគណៈកម្មាធិការកសិកម្មមក «កាន់កាប់ពាណិជ្ជកម្ម» ជាមួយ ឌឿន ដែលត្រូវតែងតាំងជាបណ្តោះអាសន្នឲ្យមកជួយគណៈកម្មាធិការនេះរយៈពេលបីខែបន្ថែមលើភារកិច្ចរបស់គាត់នៅមន្ទីរ៨៧០ៗ របាយការណ៍ដែលមាននៅចំពោះមុខអង្គជំនុំជម្រះបញ្ជាក់ថា ត្រឹមចុងខែតុលា ឆ្នាំ១៩៧៦ ខ្សែបណ្តាញរាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្មបានផ្លាស់ប្តូរពី ឌឿន ទៅ ខៀវ សំផនវិញៗ

**៦១៩**. ខៀវ សំផន ទទួលស្គាល់ថាជាផ្នែកមួយនៃការទទួលខុសត្រូវរបស់គាត់នៅក្នុងមន្ទីរ៨៧០ គាត់ធ្វើទំនាក់ទំនងជាមួយក្រសួងនានានៃកម្ពុជាប្រជាធិបតេយ្យ និងក្រសួងរបស់ប្រទេសដទៃទៀតជាច្រើន ដើម្បីនាំចូលទំនិញដែលគណៈកម្មាធិការអចិន្ត្រៃយ៍បានអនុម័ត និងសម្រួលដល់ការបែងចែកសម្ភារនិងផលិតផលទៅតាមកបណ្តាភូមិភាគៗ ការជាន់ភារកិច្ចគ្នាយ៉ាងច្បាស់បែបនេះជាមួយ និងការទទួលខុសត្រូវលើមុខងារដទៃទៀតបន្ថែមពីលើភាពមិនច្បាស់លាស់នៃរដ្ឋបាលផ្នែកកិច្ចការនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ធ្វើឲ្យអង្គជំនុំជម្រះមិនអាចបង្ហាញឲ្យបានជាក់លាក់អំពីមុខតំណែងទាំងអស់ដែល ខៀវ សំផន ត្រូវទទួលខុសត្រូវនោះទេៗ ទោះជាយ៉ាងនេះក្តីភស្តុតាងជាឯកសារនាសម័យកាលនោះ បានបង្ហាញថា ខៀវ សំផន មាននួនាទីយ៉ាងសំខាន់នៅក្នុងការត្រួតពិនិត្យលើកិច្ចការពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យៗ ឧទាហរណ៍ គណៈកម្មាធិការពាណិជ្ជកម្ម ជាញឹកញាប់បានស្នើសុំសេចក្តីណែនាំពី ខៀវ សំផន លើបញ្ហាពាណិជ្ជកម្មហើយរបាយការណ៍គណៈកម្មាធិការនេះនិងឯកសារពាក់ព័ន្ធនឹងពាណិជ្ជកម្មផ្សេងទៀតត្រូវបានផ្ញើជូន ចម្លងជូនឬ ត្រូវបានអះអាងថាប្រគល់ជូន ខៀវ សំផន នៅចន្លោះពីខែតុលា ឆ្នាំ១៩៧៦ ដល់ខែធ្នូ ឆ្នាំ១៩៧៨ ដែលរួមមានរបាយការណ៍នៃការពិភាក្សាជាមួយគណៈប្រតិភូពាណិជ្ជកម្មបរទេស និងទំនាក់ទំនងផ្សេងទៀតទាក់ទិនពាណិជ្ជកម្មអន្តរជាតិ របាយការណ៍ស្តីពីបរិមាណស្រូវអង្ករដែលបញ្ជូនទៅឃ្លាំងរដ្ឋពីបណ្តាភូមិភាគនានា និងរបាយការណ៍ស្តីពីការនាំចេញស្រូវអង្ករ និងទំនិញផ្សេងៗទៀត សំណើរសុំទិញទំនិញនិងសម្ភារពីក្រសួងនានា និងបញ្ជីសម្ភារនាំចូលពីប្រទេសចិន របាយការណ៍ស្តីពីការប្រើប្រាស់ឥណទានរបស់ចិនពីសំណាក់កម្ពុជាប្រជាធិបតេយ្យនិងសារផ្ញើទៅមករវាងក្រុមហ៊ុន-FORTRA និង ក្រុមហ៊ុន Ren Fungៗ

**៦២០**. ទោះបីជាមានភាពច្បាស់លាស់ថា ខៀវ សំផន មិនមាននួនាទីណាមួយនៅក្នុងគណៈរដ្ឋមន្ត្រីពាក់ព័ន្ធនឹងពាណិជ្ជកម្មឬ ពាណិជ្ជកម្មអន្តរជាតិ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយរដ្ឋមន្ត្រីពាក់ព័ន្ធនិងវិស័យនេះត្រូវបានផ្ញើជូនជាសំខាន់ទៅ ខៀវ សំផន ហើយឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច គឺ វ៉ន វ៉េត ជាញឹកញាប់ត្រូវបានចម្លងជូននៅក្នុងរបាយការណ៍ក្នុងនាមជាអ្នកទទួលទីពីរបន្ទាប់ពី ខៀវ សំផនៗ នៅក្នុងឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទិនបញ្ហាពាណិជ្ជកម្ម មានឯកសារតិចតួចប៉ុណ្ណោះដែលបញ្ជាក់ថា វ៉ន វ៉េត គឺជាអ្នកទទួលឯកសារតែម្នាក់ឯង ដូចជាករណីថាមិនមាន

ផ្ញើជូន ខៀវ សំផន ជាដើមនោះ។ បន្ទាប់ពី វ៉ន វ៉េត ត្រូវបានចាប់ខ្លួននៅចុងឆ្នាំ១៩៧៨ ខៀវ សំផន នៅបន្តទទួលលិខិតនិងរបាយការណ៍ស្តីពីបញ្ហាពាណិជ្ជកម្ម។ លើសពីនេះទៀត ខៀវ សំផន ក៏បានទៅមើលឃ្លាំងរដ្ឋជាមួយ វ៉ាន់ រិត ដែលនៅទីនោះ ខៀវ សំផន បានពិនិត្យផលិតផលដែលត្រូវបាននាំចេញ និងប្រជុំជាមួយកម្មករ និងកម្មាភិបាលពាណិជ្ជកម្ម ដោយបង្រៀនពួកគេអំពីភាពជាអ្នកដឹកនាំគោលការណ៍ និងសីលធម៌ និងការថ្កោលទោស «ពួកដែលខ្ជិលធ្វើការ» ថាជាខ្មាំងរបស់បក្ស។

**៦២១.** អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានអនុវត្តន៍កិច្ចការពិនិត្យដ៏សំខាន់ដូច្នេះហើយគាត់បានទទួលព័ត៌មានពេញលេញ អំពីបញ្ហាពាណិជ្ជកម្ម និងការនាំចេញនាំចូលរបស់ប្រទេសកម្ពុជាប្រជាធិបតេយ្យ ទាំងក្នុងស្រុកនិងអន្តរជាតិ នៅចន្លោះពីខែតុលា ឆ្នាំ១៩៧៦ ដល់ដើមឆ្នាំ១៩៧៩។

## ៨.៣.៤.៣. ការទទួលខុសត្រូវនៅក្នុងក្រសួងការបរទេស

**៦២២.** ដីកាដំណោះស្រាយបានបង្ហាញអំពីកំណត់ហេតុស្តាប់ចម្លើយ ឡុង នរិន្ទ ដែលបញ្ជាក់ថាមាន«ភស្តុតាងថា នៅពេល អៀង សារី នៅក្រៅប្រទេស ខៀវ សំផន ទទួលខុសត្រូវលើក្រសួងការបរទេស»។ សាក្សីបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស. ថា«ពេលដែល អៀង សារី មិននៅ ខៀវ សំផន គាត់មកទទួលខុសត្រូវ មកទទួលពីរដង តាមខ្ញុំចាំប្រហែលជា វ៉ន វ៉េត មកពីរដងដែរ អត់មានថ្នាក់ដឹកនាំណាមួយដទៃទៀតទេ ក្រៅពី ខៀវ សំផន និង វ៉ន វ៉េត។




កម្មករនៅកំពង់ផែព្រះសីហនុ កំពុងផ្ទេរធុងប្រេងចេញពីកប៉ាល់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ថតនៅខែសីហា ឆ្នាំ១៩៧៨។ (ហ៊ុនណា បឹយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**៦២៣.** សាក្សីបានអះអាងម្តងហើយម្តងទៀតនៅក្នុងសវនាការថា «ពេលខ្លះ ខៀវ សំផន មក» ក្រសួងការបរទេសក្នុងនាមជា «ប្រធានស្តីទី» ជាអ្នកជំនួស អៀង សារី ប៉ុន្តែមិនបានផ្តល់ព័ត៌មានអ្វីបន្ថែមទៀតឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា ទោះបីជាអង្គជំនុំជម្រះយល់ឃើញថា ឡុង នរិន្ទ ជាសាក្សីដែលអាចជឿជាក់បានជាទូទៅក្តី ក្រៅពីចំណុចដែលថា ខៀវ សំផន ទៅក្រសួងការបរទេសនៅពេលអវត្តមាន អៀង សារី ប៉ុន្តែអង្គជំនុំជម្រះមិនមានភស្តុតាងនៅចំពោះមុខបន្ថែមទៀតដែលគាំទ្រដល់អំណះអំណាងរបស់សាក្សីនេះឡើយ។ សាក្សី សា ឡុត បានក៏បានឃើញ ខៀវ សំផន នៅក្រសួងការបរទេសដែរ នៅពេលដែល អៀង សារី អវត្តមាន ដោយ ខៀវ សំផន បានពិភាក្សាអំពីសំបុត្រយន្តហោះ និងបានដឹកនាំការប្រជុំអំពីជនបរទេស។ អង្គជំនុំជម្រះមិនច្បាស់ថា តើការប្រជុំបែបនេះធ្វើឡើងទៅតាមមុខងាររដ្ឋការ ឬក្រៅរដ្ឋការនៅក្នុងក្រសួងនោះទេ។ សាក្សី សួង ស៊ីគឿន ក៏បានជួប ខៀវ សំផន ពីរដងដែរនៅក្រសួងការបរទេស ដោយពួកគាត់ទាំងពីរនាក់បានពិភាក្សាអំពីរបៀបរៀបចំសេចក្តីព្រាងអត្ថបទសារព័ត៌មានមួយ។ អង្គជំនុំជម្រះសូមរម្លឹកអំពីការរក្សាការសម្ងាត់ទូទៅនៃការគ្រប់គ្រងនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ និងអង្គជំនុំជម្រះទទួលស្គាល់ពីលទ្ធភាពដែលថា តាមពិត ខៀវ សំផន អាចជួយដល់ផ្នែកផ្សេងៗនៃការគ្រប់គ្រងរដ្ឋាភិបាលទៅតាមពេលវេលាជាក់ស្តែង ដែលជាផ្នែកមួយនៃមុខងារបន្ទាប់បន្សំរបស់គាត់។ ត្រង់ចំណុចនេះអង្គជំនុំជម្រះបានរកឃើញរួចហើយថា គាត់បានបំពេញមុខងារបន្ទាប់បន្សំមួយចំនួនក្រៅពីតំណែងរដ្ឋការរបស់គាត់។ ប៉ុន្តែភស្តុតាងមានភាពមិនច្បាស់លាស់ទាក់ទងនិងការចោទប្រកាន់ពីការទទួលខុសត្រូវរបស់ ខៀវ សំផន ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេស ដែលមិនអាចឲ្យអង្គជំនុំជម្រះសម្រេចថា នៅពេលអវត្តមាន អៀង សារី និងក្រៅពីការជួយបណ្តោះអាសន្នបន្តិចបន្តួចនិងម្តងម្កាលនោះ ខៀវ សំផន ត្រូវទទួលខុសត្រូវលើក្រសួងការបរទេសនោះបានទេ។

## ៨.៤ សេចក្តីសង្ខេបពីសំអាងហេតុ

**៦២៤.** អង្គជំនុំជម្រះរកឃើញថា វត្តមានដ៏យូររបស់ ខៀវ សំផន នៅក្នុងមជ្ឈដ្ឋាននយោបាយរបស់កម្ពុជា បានធ្វើឲ្យចលនាគស៊ីនេះមានភាពស្របច្បាប់ ដែលក្រោយមកត្រូវបានបង្ហាញខ្លួនថាជា ប.ក.ក.។ បន្ទាប់ពីជ័យជម្នះរបស់កងទ័ពរំដោះប្រជាជនកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន បានបន្តដើរតួនាទីជាមុខមាត់សាធារណៈរបស់កម្ពុជាប្រជាធិបតេយ្យ ដែលដំបូងឡើយ គឺជាឧបនាយករដ្ឋមន្ត្រីរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ហើយចាប់តាំងពីដើមឆ្នាំ១៩៧៦ គាត់បានក្លាយជាប្រធានគណៈប្រធានរដ្ឋ។ នៅពេលនោះ ការទទួលខុសត្រូវរបស់ ខៀវ សំផន គឺមានត្រឹមតែទំនាក់ទំនងការទូត ការចេញសេចក្តីថ្លែងការណ៍ក្នុងនាមកម្ពុជាប្រជាធិបតេយ្យ និងការគាំទ្រដល់មាគ៌ា ប.ក.ក.។ ទោះជាយ៉ាងនេះក្តី ក្រៅពីតួនាទីជាប្រមុខរដ្ឋដែលមានត្រឹមតែឈ្មោះនោះ មានភស្តុតាងបង្ហាញថា ការទទួលខុសត្រូវក្នុងមុខងាររបស់ ខៀវ សំផន បានពង្រីកហួតដល់ប្រតិបត្តិការសំខាន់ៗរបស់បក្ស និងរដ្ឋ រួមទាំង ការត្រួតពិនិត្យមើលទៅលើការងារពាណិជ្ជកម្ម និងការនាំចេញនាំចូលរបស់ប្រទេសចិន និងការដឹកនាំវគ្គរៀនសូត្រនិងអប់រំនយោបាយ។ លើសពីនេះដោយមិនគិតពីអំណះអំណាងរបស់គាត់ដែលថាគាត់មិនបានប្រើប្រាស់តួនាទីណាមួយនៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សប៉ុណ្ណោះទេ ប៉ុន្តែ ខៀវ សំផន ថែមទាំងស្ថិតនៅក្នុងតួនាទីមួយដែលមានភាពលេចធ្លោខ្លាំងនៅក្នុងបក្ស ដោយសារតែវត្តមានរបស់គាត់នៅឯកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលពិភាក្សាពីបញ្ហាសំខាន់ៗ ហើយសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើងក្នុងកិច្ចប្រជុំនោះ។

## ៩ ច្បាប់ជាធរមាន ៖ ឧក្រិដ្ឋកម្ម

### ៩.១. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

### ៩.១.១. ការធ្វើមនុស្សឃាត

**៦២៥.** ទាក់ទិនសំណុំរឿង ០០២/០២ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាតនៅក្នុងការដ្ឋានការងារសាងសង់ទំនប់ត្រពាំងថ្ម ការដ្ឋានការងារទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល និងនៅក្នុងក្រខណ្ឌនៃការប្រព្រឹត្តចំពោះពុទ្ធសាសនិក ជនជាតិចាម និងជនជាតិវៀតណាម។

**៦២៦.** អង្គជំនុំជម្រះបានសម្រេចពីមុនរួចមកហើយថា ការធ្វើមនុស្សឃាតត្រូវបានទទួលស្គាល់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥។ ភាគីនានានៃសំណុំរឿងនេះ មិនបានជំទាស់អំពីអត្ថិភាពនៃការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គិតត្រឹមឆ្នាំ១៩៧៦នោះទេ។

**៦២៧.** ធាតុផ្សំសត្យានុម័តនៃការធ្វើមនុស្សឃាតរួមមានអំពើសកម្មឬអសកម្ម របស់ជនជាប់ចោទឬរបស់ជនណាម្នាក់ឬច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើសកម្មឬអសកម្មដែលបណ្តាលឲ្យជនរងគ្រោះស្លាប់។ អំពើសកម្ម ឬ អសកម្មត្រូវតែបានរួមចំណែកយ៉ាងពិតប្រាកដក្នុងការធ្វើឲ្យបាត់បង់ជីវិតជនរងគ្រោះ។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា មិនមានភាគីណាមួយជំទាស់ទៅនឹងចំណុចដែលថាការប្រព្រឹត្តការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈអំពើអកម្ម ដែលបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិគិតត្រឹម ១៩៧៥ នោះឡើយ។ អង្គជំនុំជម្រះនេះធ្លាប់បានយកគោលការណ៍ទូទៅដែលតុលាការមិនអចិន្ត្រៃយ៍នានាយកទៅអនុវត្តយ៉ាងស៊ីសង្វាក់គ្នា ដែលថា «បទឧក្រិដ្ឋមួយអាចប្រព្រឹត្តឡើយដោយអំពើអកម្ម ដែលនាំឲ្យមានពិរុទ្ធ ក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការ»។ ទោះបីជា សេចក្តីសង្កេតនេះធ្វើឡើងនៅក្នុងបរិបទនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះយល់ឃើញថា គោលការណ៍ទូទៅ ដែលចាំបាច់ត្រូវបានកាតព្វកិច្ចក្នុងការចាត់វិធានការ អនុវត្តបានចំពោះអំពើអសកម្មទាំងអស់ ដែលនាំឲ្យមានពិរុទ្ធ។ ហេតុដូច្នេះអំពើអកម្មនឹងមានពិរុទ្ធតែក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការតែប៉ុណ្ណោះ។

**៦២៨.** ធាតុផ្សំនៃការធ្វើមនុស្សឃាតអាចត្រូវបានបំពេញ ទោះបីជាសាកសពរបស់ជនរងគ្រោះត្រូវបានរកឃើញឬ មិនត្រូវបានរកឃើញ។ អង្គហេតុនៃការបាត់បង់ជីវិតរបស់ជនរងគ្រោះអាចត្រូវបានសន្និដ្ឋានតាមរយៈភស្តុតាងដែលបានបង្ហាញទាំងអស់។ អ្វីដែលតម្រូវឲ្យធ្វើការសន្និដ្ឋានពីភស្តុតាងនោះគឺការទាក់ទាញសេចក្តីសន្និដ្ឋានដ៏សមហេតុផលតែមួយគត់ដែលថា ជនរងគ្រោះស្លាប់ដោយសារអំពើសកម្ម ឬអសកម្មរបស់ជនជាប់ចោទ ឬរបស់ជនណាម្នាក់ឬច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើនោះ។ ពិរុទ្ធភាពពីការធ្វើមនុស្សឃាតពុំត្រូវបានដកចេញដោយសារតែពុំអាចកំណត់ចំនួនមនុស្សស្លាប់សរុប ឬពុំអាចកំណត់អត្តសញ្ញាណរបស់ចារីផ្ទាល់ និងជនរងគ្រោះទៅតាមករណីមួយៗបានឡើយ។ ដើម្បីមានការសន្និដ្ឋានរួមដែលថាការសម្លាប់បានកើតឡើងឲ្យហួសពីវិមតិសង្ស័យនោះ ហេតុការណ៍ជាក់លាក់នៃការសម្លាប់មនុស្សត្រូវតែបង្ហាញឲ្យហួសពីវិមតិសង្ស័យ។

**៦២៩.** សហព្រះរាជអាជ្ញាលើកឡើងថា ការធ្វើអត្តឃាតរបស់បុគ្គលម្នាក់អាចត្រូវបានចាត់ទុកថាជាការធ្វើមនុស្សឃាត នៅពេលដែលអំពើសកម្ម ឬ

អសកម្មរបស់ចារី «បាននាំឲ្យជនរងគ្រោះធ្វើសកម្មភាព» ដែលបានបណ្ដាលឲ្យជនរងគ្រោះស្លាប់»។ អង្គជំនុំជម្រះនឹងបញ្ជាក់ថា តើការធ្វើអត្តឃាតរបស់បុគ្គលម្នាក់អាចជាការធ្វើមនុស្សឃាតបានដែរឬទេ ដោយសារតែបញ្ហានេះកើតឡើងដោយផ្អែកលើអង្គហេតុនានានៃរឿងក្ដី និងចំពោះករណីថា ហេតុការណ៍នានានៃការធ្វើអត្តឃាតត្រូវបានអះអាងថា ជាការធ្វើមនុស្សឃាតនៅក្នុងដីកាដំណោះស្រាយ។

**៦៣០.** អង្គជំនុំជម្រះធ្លាប់បានសម្រេចថា ធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាត តម្រូវឲ្យមានការបង្ហាញភ័ស្ដុតាងអំពីចេតនាដាច់ខាតរបស់ជនណាម្នាក់ឬច្រើននាក់ ដែលជនដាច់ខាតជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់ ឬការបង្កឲ្យមានព្យសនកម្មលើរូបកាយធ្ងន់ធ្ងរ ដោយមានហេតុផលសមស្របដែលនាំឲ្យដឹងថា អំពើសកម្មឬអសកម្មនោះអាចធ្វើឲ្យមានការបាត់បង់ជីវិតមនុស្ស។ យុត្តិសាស្ត្របានបញ្ជាក់ច្បាស់ថា ការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវឲ្យមានការគិតទុកជាមុននោះឡើយ។

**៦៣១.** នៅក្នុងការបដិសេធការជំទាស់ ទៅនឹងការកំណត់និយមន័យនៃការធ្វើមនុស្សឃាតរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលអត្ថិភាពក្នុងឆ្នាំ១៩៧៥ «ត្រូវតែកំណត់និយមន័យឲ្យមានលក្ខណៈទូលាយ

កម្មករនៅរោងចក្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កៀបសម្លីគដើម្បីនាំចេញទៅបរទេសថតនៅខែសីហា ឆ្នាំ១៩៧៨។ (ហ្គុនណា បឺយស្ត្រម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



(Largo sensu) ដើម្បីរួមបញ្ចូលនូវចេតនាដោយប្រយោល (dolus eventualis) ផងដែរ» និងបានទទួលយកនិយមន័យដូចខាងក្រោមនេះ៖

ការកំណត់និយមន័យ ដែលជាលក្ខណៈបច្ចេក-ទេសលើចេតនាដោយប្រយោល (dolus eventualis) មានដូចតទៅ៖ ប្រសិនបើចារីបង្ហាញពីអាកប្បកិរិយាដែលបង្កឲ្យបាត់បង់ជីវិតមនុស្ស ចារីមានចេតនាសម្លាប់ដោយសារតែចារី «សម្រុះសម្រួលខ្លួនទទួលយក» ឬ «ស្រុះស្រួលទទួលយក» បើទោះបីទំនងជានឹងមានការសម្លាប់ក៏ដោយ។ ដូច្នេះប្រសិនបើការសម្លាប់ត្រូវបានប្រព្រឹត្តឡើងដោយ «មិនអើពើអំពីតម្លៃជីវិតរបស់មនុស្ស» បើទោះបីជាអំពើនោះមិនមានហានិភ័យតិចតួចក៏ដោយ ក៏អាចកំណត់បានថា ជាការសម្លាប់មនុស្សដោយចេតនាដែរ។ ការសម្លាប់ក្នុងទ្រង់ទ្រាយធំដែលត្រូវបានចាត់ចំណាត់ថ្នាក់ថាជាការធ្វើមនុស្សឃាតដោយសារការធ្វេសប្រហែសនៅក្នុងសហរដ្ឋអាមេរិក អាចបំពេញតាមលក្ខណៈវិនិច្ឆ័យនៃប្រព័ន្ធច្បាប់ស៊ីវិលស្តីពីចេតនាដោយប្រយោល (dolus eventualis)។ […] គោលគំនិតនៃចេតនាដោយប្រយោល (dolus eventualis) ពុំបានរួមបញ្ចូលនូវបទដ្ឋាននៃការធ្វេសប្រហែសឬធ្វេសប្រហែសទាំងស្រុងនោះឡើយ។

**៦៣២.** មេធាវីការពារក្តី ខៀវ សំផន អះអាងថា ការកំណត់និយមន័យអំពីធាតុផ្សំសំខាន់នៃការធ្វើមនុស្សឃាតដែលបានទទួលយកដោយអង្គជំនុំជម្រះនេះ និងអង្គជំនុំជម្រះតុលាការកំពូល រំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាពដោយហេតុថាវាជាការអនុវត្តបទដ្ឋានធាតុផ្សំអត្តនោម័តិក្នុងកម្រិតទាបជាងចេតនាដោយផ្ទាល់ក្នុងការសម្លាប់ដែលមិនអាចប្រមើលឃើញជាមុន និងមិនអាចដឹងថាមានច្បាប់ចែងនៅក្នុងឆ្នាំ១៩៧៥។ មេធាវីការពារក្តីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើនិយមន័យដែលយកមកពីយុត្តិសាស្ត្រក្រោយៗមកទៀតរបស់តុលាការមិនអចិន្ត្រៃយ៍នានា ដែលសុទ្ធតែមិនត្រូវបានទទួលយកដោយអង្គជំនុំជម្រះទាំងអស់នៅតុលាការទាំងនោះឡើយ។ មេធាវីការពារក្តីអះអាងថា ធាតុផ្សំសំខាន់ៗនៃការធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងឆ្នាំ១៩៧៥ បានកំណត់ត្រឹមតែចេតនាក្នុងការសម្លាប់ប៉ុណ្ណោះ និងមិនបានពង្រាតទៅដល់ចេតនាបង្កឲ្យមានរបួសនកម្មលើរូបកាយដោយដឹងថា អាចនឹងនាំឲ្យមានការបាត់បង់ជីវិតមនុស្សនោះឡើយ។ នៅក្នុងការគាំទ្រសេចក្តីសន្និដ្ឋាននេះ មេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់សាឡើងវិញនូវទឡ្ហីករណ៍នានាដែលបានលើកឡើង និងត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូលនៅដំណាក់កាលបណ្តឹងសាទុក្ខ។ លើសពីនេះទៀតមេធាវីការពារក្តីឆ្លើយតបថា អង្គជំនុំជម្រះតុលាការកំពូលបានរំលោភលើគោលការណ៍នីត្យានុកូលភាព ដោយផ្អែកទៅលើច្បាប់ពីបណ្តាលប្រទេសនានា នៅក្រោយឆ្នាំ១៩៧៥ ដោយមិនត្រឹមត្រូវ និងថាច្បាប់នានាមុនឆ្នាំ១៩៧៥ ដែលអង្គជំនុំជម្រះតុលាការកំពូលបានយកមកធ្វើជាសំអាងនោះ មិនបានបង្ហាញអំពីអត្ថិភាពនៃការអនុវត្តច្បាប់ជាទូទៅ និងស៊ីចង្វាក់គ្នានៅក្នុងចំណោមរដ្ឋទាំងឡាយ ហើយក៏មិនបានបង្ហាញអំពីការបង្ហាញឆន្ទៈទទួលយកជាច្បាប់របស់រដ្ឋ (opinion juris) ដែលបង្កើតបានជាវិធានទំនៀមទម្លាប់ មុនឆ្នាំ១៩៧៥ នោះឡើង។

**៦៣៣.** បន្ទាប់មក មេធាវីការពារក្តី ខៀវ សំផន លើកទឡ្ហីករណ៍ជាច្រើន តាមការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធនិងបញ្ហានេះថា ហេតុអ្វីបានជាអង្គជំនុំជម្រះតុលាការកំពូលមានកំហុសនៅក្នុងការវិភាគទាក់ទងនិងបទដ្ឋានធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការបកស្រាយរបស់អង្គជំនុំជម្រះតុលាការអំពីរឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ (Medical Case) និងការផ្អែករបស់អង្គជំនុំជម្រះទៅលើច្បាប់ជាតិនិងច្បាប់យុត្តិសាស្ត្រ។

**៦៣៤.** អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកថា ដើម្បីអនុលោមតាមគោលការណ៍នីត្យានុកូលភាពនិយមន័យនៃការធ្វើមនុស្សឃាត ដែលអាចអនុវត្តបាននៅក្នុង

រឿងក្តីនេះត្រូវតែឆ្លុះបញ្ចាំងអំពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅត្រឹមឆ្នាំ១៩៧៥។ ផ្ទុយទៅនឹងការសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ប្រការនេះមិនបានរារាំងអង្គជំនុំជម្រះមិនឲ្យយោងទៅសេចក្តីសម្រេចក្រោយៗមកទៀតដែលស្រាយបំភ្លឺ ឬបកស្រាយច្បាប់នោះឡើយ។

**៦៣៥.** នាពេលបច្ចុប្បន្ន យុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍នានាបានទទួលស្គាល់ថា ធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត រួមបញ្ចូលទាំងគោលគំនិតនៃចេតនាដោយប្រយោល (dolus eventualis) ។ ទោះបីជាយ៉ាងណា ទាក់ទិនការប្រើប្រាស់ពាក្យពេចន៍ជាក់លាក់នោះ យុត្តិសាស្ត្រនេះមិនស៊ីចង្វាក់គ្នាទាំងស្រុងនោះទេ ហើយសេចក្តីសម្រេចមួយចំនួនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ICTR) បានលើកឡើងថា ការគិតទុកជាមុន គឺជាតម្រូវការចាំបាច់សម្រាប់គោលបំណងនៃការធ្វើមនុស្សឃាត។ ហេតុដូច្នេះ ទោះបីជាយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ពិតជាបានផ្តល់នូវគោលការណ៍ណែនាំក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃទៅលើស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ១៩៧៥។

**៦៣៦.** អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ និងជាពិសេសរឿងក្តីពាក់ព័ន្ធនិងវេជ្ជសាស្ត្រ (Medicaial case) ដោយរួមបញ្ចូលនូវសញ្ញាណនៃចេតនាដោយប្រយោល (dolus eventualis) នៅក្នុងនិយមន័យនៃការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការវិភាគលើអង្គហេតុនៃរឿងក្តីបង្ហាញថា ទោះបីជាវេជ្ជបណ្ឌិតរបស់ពួកណាហ្ស៊ី មិនបានយកចិត្តទុកដាក់ទាក់តែសោះអំពីអាយុជីវិតរបស់បុគ្គលដែលត្រូវបានគេយកមកពិសោធយ៉ាងឃោរឃៅឬថែម ទាំងគិតថា ការស្លាប់របស់មនុស្សជាច្រើនដែលជាលទ្ធផលនៃការធ្វើដូច្នេះក៏ដោយ ក៏នៅក្នុងករណីមួយចំនួន គោលបំណងរបស់ពួកគេ គឺដើម្បីធ្វើការវាយតម្លៃថា តើបុគ្គលទាំងនោះអាចមានលទ្ធភាពរស់រានមានជីវិតនៅក្នុងស្ថានភាពលំបាកឬជាពិសេស នៅពេលមានជំងឺធ្ងន់ធ្ងរបានដែរឬទេ។ នៅក្នុងស្ថានភាពបែបនេះ ចេតនាបានរួមបញ្ចូលការប្រថុយនឹងគ្រោះថ្នាក់ទៅលើអាយុជីវិតរបស់បុគ្គលទាំងឡាយដែលត្រូវបានគេយកមកពិសោធ ដោយដឹងថាការធ្វើបែបនេះទំនងជានឹងនាំឲ្យមានការបាត់បង់ជីវិត។ ដូច្នេះ ទោះបីជារឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ (Medical Case) មិនបានយោងឲ្យបានច្បាស់ទៅលើការអនុវត្តបទដ្ឋាននៃធាតុផ្សំអត្តនោម័តិ ដែលជាចំណុចដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា រឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ (Medical Case) អាចត្រូវបានចាត់ទុកថា ជាមូលដ្ឋានសំអាងមួយក្នុងចំណោមមូលដ្ឋានសំអាងផ្លូវច្បាប់ជាច្រើន ក្នុងការដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់ដោយចេតនា ទោះបីជាចារីបានប្រព្រឹត្តអំពើដោយចេតនាក្នុងកម្រិតទាបជាងចេតនាដោយចំពោះក៏ដោយ។

**៦៣៧.** អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលមិនផ្អែកតែទៅលើរឿងក្តីពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ (Medical Case) ប៉ុណ្ណោះទេ ប៉ុន្តែក៏បានយល់ឃើញផងដែរថា ទម្លាប់អនុវត្តក្នុងស្រុក « បានបញ្ជាក់បន្ថែមទៀត » ទៅលើសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានរួមបញ្ចូលនូវសញ្ញានៃចេតនាដោយប្រយោល (dolus eventualis) ។

**៦៣៨.** ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់រួចមកហើយ ការពិចារណាទៅលើគោលការណ៍ច្បាប់ទូទៅអាចជាជំនួយចំពោះការកំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងករណីដែលឧក្រិដ្ឋកម្មនោះត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ នៅក្នុងការវាយតម្លៃអំពីអត្ថិភាពនៃគោលការណ៍ច្បាប់ទូទៅ « ការយោងមិនត្រូវសម្អាងទៅលើប្រព័ន្ធច្បាប់ជាតិតែមួយមុខដូចជា ច្បាប់កុំមិនឡូ ច្បាប់ស៊ីវិល «រហូតដល់ទាត់ចោលប្រព័ន្ធច្បាប់ដទៃទៀតនោះទេ» និងតម្រូវឲ្យមានការវាយតម្លៃទៅលើគោល

ការណ៍នានា«ដែលមាននៅក្នុងប្រព័ន្ធគតិយុត្តិសំខាន់ៗនៅលើពិភពលោក» ។ ទោះបីជាខ្លឹមសារនៃគោលការណ៍ទូទៅ «មិនតម្រូវឲ្យមានការអង្កេតឲ្យបានទូលំទូលាយទៅលើប្រព័ន្ធច្បាប់ទាំងអស់នៅលើពិភពលោកក៏ដោយ» ក៏វាមានសារសំខាន់ផងដែរក្នុងការចៀសវាងនូវ «ការយកតាមលំនាំ ឬការផ្ទេរដោយមិនបានពិចារណាពីច្បាប់ជាតិ ទៅដាក់បញ្ចូលក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ»។

**៣៣៩.** អង្គជំនុំជម្រះតុលាការកំពូល បានពិនិត្យទៅលើច្បាប់ដែលយកមកអនុវត្ត នៅក្នុងប្រព័ន្ធច្បាប់កុំមិនឡូ និងច្បាប់ស៊ីវិលមួយចំនួន និងបានសន្និដ្ឋានថា «នៅក្នុងយុត្តិការក្នុងស្រុកទាំងអស់ដែល [...] បានពិនិត្យនោះឃើញថា ធាតុផ្សំអន្តនោម័តនៃអំពើមនុស្សឃាតដោយចេតនា គឺជាលក្ខខណ្ឌតម្រូវ ហើយទោះបីជាចារីបានប្រព្រឹត្តអំពើដោយចេតនាក្នុងកម្រិតទាបជាងចេតនាដោយចំពោះក្នុងការសម្លាប់ក៏ដោយ»។

**៦៤០.** អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវិភាគបន្ថែមទៀត នៅលើប្រព័ន្ធច្បាប់នានាដែលអង្គជំនុំជម្រះតុលាការកំពូលបានយោង៧ ទៅលើច្បាប់យុត្តិសាស្ត្រដែលចុះកាលបរិច្ឆេទក្រោយឆ្នាំ១៩៧៥។

**៦៤១.** ក្រៅពីប្រភពនានាមុនឆ្នាំ១៩៧៥ ដែលជាអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការពិនិត្យនោះ ឧទាហរណ៍ នៅប្រទេសអាល្លឺម៉ង់មានយុត្តិសាស្ត្រច្បាស់លាស់និងស៊ីចង្វាក់គ្នាតាំងពីដើមឆ្នាំ១៩៥៥ ដែលបង្ហាញពីចេតនាដោយប្រយោល (dolus eventualis) ថាមានលក្ខណៈគ្រប់គ្រាន់សម្រាប់គោលបំណងនៃការកំណត់និយមន័យអំពីការធ្វើមនុស្សឃាត។ នៅប្រទេសអូទ្រីស ត្រឹមឆ្នាំ១៩៧៥ ក្រមព្រហ្មទណ្ឌបានកំណត់ឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដោយចេតនាដែលត្រូវបានកំណត់ថា ដោយមានចេតនាដោយប្រយោល (dolus eventualis) បានចាក់ឫសយ៉ាងមាំចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដោយចេតនានៅប្រទេសស្វីស នៅដើមឆ្នាំ១៩៨៣។

**៦៤២.** ចាប់តាំងពីការអនុវត្តម័តិក្រមព្រហ្មទណ្ឌរបស់ខ្លួនក្នុងឆ្នាំ១៨៨១ មកប្រទេសហូឡង់បានបែងចែកដាច់ពីគ្នារវាងមនុស្សឃាតដោយចេតនា («doodslad») និងការធ្វើមនុស្សឃាត («moord») ។ ដើម្បីអាចឲ្យបទល្មើសមួយប្រព្រឹត្តឡើង «ដោយមានចេតនា» («opzettelijk») ច្បាប់ប្រទេសហូឡង់បានទទួលស្គាល់ថាចេតនាក្នុងកម្រិតណាក៏ដោយ រួមទាំងចេតនាដោយប្រយោលផងដែរនោះ(dolus evetualis) («voorwaardelijk opzet») មានភាពគ្រប់គ្រាន់ហើយ។ គោលគំនិតនៃចេតនាប្រយោល (dolus evetualis) ត្រូវបានទទួលយកដោយតុលាការកំពូលប្រទេសហូឡង់ ចាប់តាំងពីឆ្នាំ១៩១១។

**៦៤៣.** នៅប្រទេសអ៊ីតាលី ក្រមព្រហ្មទណ្ឌឆ្នាំ១៩៣១ បានចែងអំពីប្រភេទផ្សេងៗនៃការធ្វើមនុស្សឃាត (omicidio) ដើម្បីកំណត់លក្ខណៈអំពើដែលបង្កឲ្យជនរងគ្រោះស្លាប់ ដោយផ្អែកលើកម្រិតនៃធាតុអត្តនោម័តិៈ «omicidio doloso (បទមនុស្សឃាតដោយចេតនា)» «omicidio perterintenzionale (បទមនុស្សឃាតដែលកើតចេញមកពីអំពីហិង្សាដែលចារីមានចេតនាធ្វើឲ្យជនរងគ្រោះមានរបួសស្នាម ប៉ុន្តែមិនមានចេតនាធ្វើឲ្យជនរងគ្រោះស្លាប់ទេ)» ឬ omicidio colposo (ការធ្វើមនុស្សឃាតដែលកើតចេញមកពីការធ្វេសប្រហែសឬការមិនយកចិត្តទុកដាក់របស់ចារី)»។ យុត្តិសាស្ត្រប្រទេសអ៊ីតាលី បានកំណត់តាំងពីឆ្នាំ១៩៧០ ថាពាក្យចេតនា (dolus) សម្រាប់គោលបំណងនៃការធ្វើមនុស្សឃាតដោយចេតនា (omicidio doloso) រួមបញ្ចូលទាំងចេតនា ដោយប្រយោល dolus eventualis(«dole eventuale») ផងដែរ។

**៦៤៤.** ទោះបីជាក្រមព្រហ្មទណ្ឌប្រទេសប៊ែលហ្ស៊ិប និងប្រទេសបារាំងមានបទប្បញ្ញត្តិស្រដៀងគ្នាយ៉ាងខ្លាំងក៏ដោយ ប៉ុន្តែច្បាប់ប្រទេសប៊ែលហ្ស៊ិកបានទទួលស្គាល់តាំងពីយូរយារណាស់មកហើយ នូវគំនិតនៃចេតនាដោយប្រយោល (dolus evenrualis) ថាជាទម្រង់នៃចេតនាដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញនូវធាតុផ្សំអន្តនោម័តិនៃការធ្វើមនុស្សឃាត។

**៦៤៥.** *ការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើយុត្តិសាស្ត្រ និងច្បាប់មុនឆ្នាំ១៩៧៥ ក៏បានបង្ហាញឲ្យឃើញច្បាស់ផងដែរថា ធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាតនៅក្នុងប្រព័ន្ធច្បាប់កុំមិនឡ* (Common Law) *រួមមាន ប្រទេសអង់គ្លេស ប្រទេសឥណ្ឌា និងប្រទេសអូស្ត្រាលី គឺមានភាពស៊ីចង្វាក់គ្នាជាមួយនឹងសញ្ញានៃចេតនាដោយប្រយោល* (dolus eventualis) ។

**៦៤៦.** *លើសពីនេះទៀត ក្រៅពីប្រព័ន្ធច្បាប់កុំមិនឡ និងប្រព័ន្ធច្បាប់ទ្វីបអឺរ៉ុប ដែលអង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យនោះ អង្គជំនុំជម្រះសាលាដំបូងក៏បានសង្កេតឃើញដែលថា នៅប្រទេសរុស្ស៊ី និង ជប៉ុន គោលគំនិតស្រដៀងគ្នានៃការកំណត់ឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌមានអត្ថិភាពត្រឹមឆ្នាំ១៩៧៥។*

**៦៤៧.** *មាត្រា១០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៦០របស់សាធារណរដ្ឋសង្គមនិយមសហភាពសូវៀត ចែងអំពីឧក្រិដ្ឋកម្មនៃការសម្លាប់ដោយចេតនាដែលកំណត់នូវអំពើដោយចេតនាដែលបណ្ដាលឲ្យបាត់បង់ជីវិតមនុស្ស។ មាត្រា៨ នៃក្រមព្រហ្មទណ្ឌដដែលនេះ បានកំណត់និយមន័យនៃការប្រព្រឹត្តដោយចេតនាដូចតទៅនេះ៖ «បទឧក្រិដ្ឋមួយត្រូវបានទទួលស្គាល់ថាបានប្រព្រឹត្តឡើងដោយចេតនា ប្រសិនបើចារីដឹងអំពីលក្ខណៈនៃសកម្មភាពឬភាពប្រងើយកន្តើយរបស់ខ្លួនដែលមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស ប្រមើលដឹងអំពីផលវិបាកដែលមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស និងមានបំណងចង់កើតមានផលវិបាកនោះឬ មានចេតនាអនុញ្ញាតឲ្យផលវិបាកទាំងនោះកើតមានឡើង»។ នៅប្រទេសជប៉ុននៅដើមឆ្នាំ១៩៤៩ តុលាការកំពូលបានសម្រេចថា ការធ្វើមនុស្សឃាតអាចត្រូវបានបង្កើតឡើង ប្រសិនបើចារីបានដឹងថាការប្រព្រឹត្តរបស់ខ្លួនអាចធ្វើឲ្យមនុស្សស្លាប់ ទោះបីជាយ៉ាងណា ប្រសិនបើចារីបានដឹងថាការប្រព្រឹត្តរបស់ខ្លួនអាចធ្វើឲ្យប្រព័ន្ធច្បាប់ទាំងនេះ ច្បាប់ឬច្បាប់យុត្តិសាស្ត្របានកំណត់យ៉ាងច្បាស់ថា អំពើនោះជាបទល្មើសព្រហ្មទណ្ឌដែលជាការសម្លាប់ចេតនា ប្រសិនបើចារីប្រព្រឹត្តអំពើដោយចេតនាក្នុងកម្រិតទាបជាងចេតនាដោយចំពោះក៏ដោយ។*

**៦៤៨.** *ករណីលើកលែងដែលគួរឲ្យកត់សម្គាល់មួយចំពោះគោលការណ៍នេះ គឺច្បាប់ប្រទេសបារាំងនិងច្បាប់ប្រទេសកម្ពុជាដែលចូលជាធរមាននៅមុនឆ្នាំ១៩៧៥។ ការពិនិត្យមើលទៅលើប្រវត្តិនៃគោលគំនិតនៃការធ្វើមនុស្សឃាតនៅក្នុងច្បាប់ប្រទេសបារាំងបង្ហាញឲ្យឃើញថា ការកំណត់និយមន័យផ្នែកច្បាប់នៃបទល្មើសនេះមានភាពខុសគ្នា។ ក្រមព្រហ្មទណ្ឌដែលបានអនុម័ត នៅក្នុងឆ្នាំ១៨១០ បានកំណត់និយមន័យនៃការធ្វើមនុស្សឃាតត្រឹមតែជាអំពើចេតនាប៉ុណ្ណោះ ហើយច្បាប់មិនបានត្រូវឲ្យមានការបង្ហាញភស្តុតាងអំពីចេតនាជាក់លាក់ក្នុងការសម្លាប់ឡើយ។ វាជាការគ្រប់គ្រាន់ក្នុងការបង្ហាញថា ចារីបានប្រព្រឹត្តហិង្សាដោយចេតនា ហើយអំពើហិង្សានោះបានបណ្ដាលឲ្យជនរងគ្រោះស្លាប់។ នៅក្នុងឆ្នាំ១៨៣២ ក្រុមអ្នកតាក់តែងច្បាប់របស់បារាំងបានកំណត់ភាពខុសគ្នារវាង«ការធ្វើមនុស្សឃាត» និង«អំពើហិង្សាដោយចេតនាដែលបណ្ដាលឲ្យស្លាប់ដោយគ្មានចេតនាសម្លាប់» ។ ជាលទ្ធផលការបង្ហាញភស្តុតាងអំពីចេតនាជាក់លាក់ក្នុងការសម្លាប់ បានក្លាយជាធាតុផ្សំនៃការការធ្វើមនុស្សឃាត ខណៈដែល «អំពើហិង្សាដោយចេតនាដែលបណ្ដាលឲ្យមនុស្សស្លាប់ដែលគ្មានចេតនាសម្លាប់» គ្រាន់តែតម្រូវថា ចារីមានចេតនាប្រព្រឹត្តហិង្សា ហើយថាអំពើហិង្សានេះបានធ្វើឲ្យជនរងគ្រោះស្លាប់។ ធាតុផ្សំនៃចេតនាត្រូវបានពិពណ៌នាថា គ្មានមរណៈចេតនា*(dolus praeter intentionem) *ដោយសារចារីពុំមានចេតនាក្នុងការសម្លាប់ហើយចារីក៏មិនបានទទួលយកហានិភ័យនៃហេតុការណ៍ដែលបណ្ដាលឲ្យស្លាប់នេះដែរ។ ភាពខុសគ្នានេះត្រូវបានយកមកដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជា និងមានអត្ថិភាពតាំងពីដាក់បញ្ចូលនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ត្រង់មាត្រា ៥០៣ មកម្ល៉េះ។*

**៦៤៩.** *ទាំងច្បាប់បារាំង និងច្បាប់កម្ពុជាបានចាត់ទុកថា*

ចេតនាក្នុងការសម្លាប់អាចត្រូវបានសន្និដ្ឋានចេញពីភស្តុតាងប្រយោល ជាពិសេស នៅពេលដែលអំពើនោះបង្ហាញឲ្យឃើញនូវភវនីយភាពកម្រិតខ្ពស់ ដែលវាអាចបណ្ដាលឲ្យជនរងគ្រោះស្លាប់ ដោយគេអាចសន្និដ្ឋានយ៉ាងសមហេតុផលបានថាចារីបានប្រព្រឹត្តដោយមានចេតនាក្នុងការសម្លាប់។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ចែងថា «ចាត់ទុកថាមានចេតនាបាន កាលបើឃើញឃាតករ ប្រហារយ៉ាងពេញទំហឹង កាលបើមានមុខរបួសមុតសាំលើខ្លួនអ្នកស្លាប់ កាលបើឃើញថា ឃាតករបានរើសរកកន្លែងសំណំនៅលើខ្លួនអ្នកស្លាប់ គួរដល់ស្លាប់មែន» ។ ចំណុចនេះអាចត្រូវបានចាត់ទុកថាជា «ចេតនាដោយមិនចំពោះ» នៅក្នុងប្រព័ន្ធច្បាប់ដទៃទៀត ប៉ុន្តែនៅតែតម្រូវឲ្យមានចេតនាក្នុងការសម្លាប់ ដែលមិនមែនដូចគ្នានឹង ចេតនាប្រយោល (dolus eventualis) នោះឡើយ។

**៦៥០.** បន្ទាប់ពីបានពិនិត្យពិច័យទៅលើប្រព័ន្ធច្បាប់ជាតិ បានបញ្ជាក់ខាងលើ ប្រព័ន្ធច្បាប់ជាតំណាងសំខាន់ៗ នៅលើពិភពលោក ការកំណត់និយមន័យអំពីការធ្វើមនុស្សឃាត (ដែលមានន័យថាជាការសម្លាប់មនុស្សដោយខុសច្បាប់និងដោយមានចេតនា) និងការមិនពិចារណាទៅលើច្បាប់និងច្បាប់យុត្តិសាស្ត្រក្រោយឆ្នាំ១៩៧៥ ដែលអង្គជំនុំជម្រះតុលាការកំពូលបានយោងទៅនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទោះបីជាការកំណត់និយមន័យច្បាប់លាស់នៃឧក្រិដ្ឋកម្មនេះអាចមានភាពខុសគ្នា និងទោះបីជាច្បាប់បារាំង និងច្បាប់កម្ពុជា អាចខុសគ្នាពីវិធីសាស្ត្រដទៃទៀតក៏ដោយ ក៏ប្រព័ន្ធច្បាប់ក្នុងស្រុកទាំងនេះ ភាគច្រើនទទួលស្គាល់ថា បទដ្ឋាននៃធាតុផ្សំអត្តនោម័តិ ក្នុងកម្រិតទាបជាងចេតនាដោយចំពោះ អាចយកមកអនុវត្តបាន ទាក់ទិនការធ្វើមនុស្សឃាតដោយចេតនាកម្រិតទាបបំផុត នោះគឺចេតនាដោយប្រយោល (dolus eventualis) ។ ចំណុចនេះរួមទាំងករណីដែលបុគ្គលម្នាក់បានបង្ហាញឆន្ទៈក្នុងការប្រព្រឹត្តដោយដឹងថា អំពើសកម្មឬអសកម្មរបស់ខ្លួនទំនងជាបណ្ដាយឲ្យជនរងគ្រោះម្នាក់ឬច្រើននាក់ស្លាប់ និងយ៉ាងហោចណាស់បុគ្គលនោះទទួលយកឬជ្រើសរើសយកលទ្ធភាពដែលអាចបណ្ដាលឲ្យមានការបាត់បង់ជីវិតនោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ការពិនិត្យពិច័យទៅលើយុត្តិសាស្ត្រជាតិ និងយុត្តិសាស្ត្រអន្តរជាតិមុនឆ្នាំ១៩៧៥ និងច្បាប់ទាំងឡាយដែលចែងពីគោលការណ៍ទូទៅនៃច្បាប់ដែលថា នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តអំពើដោយស្ម័គ្រចិត្ត និងដោយដឹងថាអំពើនោះទំនងជានឹងបណ្ដាយឲ្យមានការបាត់បង់ជីវិតមនុស្ស អំពើនោះគឺជាការធ្វើមនុស្សឃាតឬជាឧក្រិដ្ឋកម្មដែលមានស្ថានទម្ងន់ប្រដៀងគ្នានៅក្នុងប្រព័ន្ធច្បាប់ជាតិនីមួយៗ។ ចំណុចនេះស្របគ្នាជាមួយនឹង សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា «ធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលមានអត្ថិភាពក្នុងឆ្នាំ១៩៧៥ ត្រូវតែកំណត់និយមន័យឲ្យមានលក្ខណៈទូលាយ (Largo sensu) ដើម្បីរួមបញ្ចូលនូវចេតនាដោយប្រយោល (dolus eventualis) ផងដែរ»។ ហេតុដូច្នេះ ការលើកឡើងរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលខុសពីនេះត្រូវបានបដិសេធចោល។

**៦៥១.** ទាក់ទងនឹងភាពអាចប្រមើលឃើញថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងអំពីការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងរឿងក្ដីនេះ អង្គជំនុំជម្រះរម្លឹកថាបញ្ហាសំខាន់ដែលត្រូវពិចារណានោះ គឺគោលបំណងអំពើដែលខ្លួនមិនអាចប្រមើលឃើញជាមុនបានថាជាបទល្មើស នៅពេលខ្លួនប្រព្រឹត្តអំពើនេះនោះទេ។ បន្ទាប់ពីបានពិចារណាទៅលើក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទអាចប្រមើលឃើញនិងដឹងជាទូទៅថា ការធ្វើមនុស្សឃាតត្រូវផ្ដន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនាឆ្នាំ១៩៧៥។

នៅក្នុងបរិបទនេះ អង្គជំនុំជម្រះ សូមរម្លឹកអំពីការយល់ឃើញរបស់ខ្លួនថា ពាក់ព័ន្ធនឹងភាពប្រមើលឃើញថាបទល្មើស និងអាចដឹងថាមានច្បាប់ចែងនោះ អង្គជំនុំជម្រះត្រូវតែពិចារណាលើសពីនិយមន័យបច្ចេកទេសនៃបទល្មើសនេះ ដោយគោរពទៅតាមគោលបំណងនៃគោលការណ៍នីត្យានុកូលភាព។ មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ចាត់ទុក«អំពើដែលប្រព្រឹត្តឡើងដោយមានចេតនាចង់ឲ្យឈឺរូបរាងកាយបុគ្គលណាម្នាក់ ប៉ុន្តែមិនចង់ឲ្យបុគ្គលនោះស្លាប់» ថាជាបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ។ លក្ខខណ្ឌតម្រូវចេតនា (គ្មានមរណៈចេតនា dolus praeter intentionem) គឺបទដ្ឋានដែលមានកម្រិតទាបជាងចេតនាដោយប្រយោល (dolus eventualis)។ ហេតុដូច្នេះហើយ វាមិនមានភាពស្រពេចស្រពិលទេដែលថា នៅក្នុងឆ្នាំ១៩៧៥ គេអាចប្រមើលឃើញថាការសម្លាប់មនុស្សដោយចេតនាដោយប្រយោល (dolus eventualis) គឺជាបទឧក្រិដ្ឋ ហើយធ្វើឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។

**៦៥២.** មេធាវីការពារក្តី នួន ជា អះអាងថា ការសម្លាប់មួយចំនួនក្នុងចំណោមការសម្លាប់ដែលបានចោទប្រកាន់នៅក្នុងរឿងក្តីនេះកើតឡើងដោយសារតែ «ដំណើរការផ្លូវច្បាប់ និងផ្អែកលើមូលដ្ឋានអង្គហេតុ និងអង្គច្បាប់» ទាក់ទិនជាមួយនឹងបុគ្គលនានាដែល «បានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដូចជា អំពើក្បត់ជាតិ អំពើរចារកម្ម ការសហការជាមួយខ្មាំងនៅក្នុងពេលសង្គ្រាម ឬការបំផ្លិចបំផ្លាញជាដើម»។ នៅក្នុងសេចក្តីសន្និដ្ឋានពីមុន មេធាវីការពារក្តី នួន ជា បានស្នើឡើងថា វាអាចថាមិនមានភាពច្បាស់លាស់ថា តើច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ «បានហាមឃាត់ដែរឬទេ ចំពោះការកាត់ទោសប្រហារជីវិត (រួមទាំងការមិនផ្តល់ការធានាពីដំណើរការឆាប់រហ័សពេញលេញ)» ជាពិសេសពាក់ព័ន្ធជាមួយនឹង «បុគ្គលដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការគំរាមកំហែងទៅលើសន្តិសុខរដ្ឋយ៉ាងធ្ងន់ធ្ងរ»។ សហព្រះរាជអាជ្ញាលើកឡើងថា ផ្ទុយពីការអះអាងលើកមុនរបស់មេធាវីការពារក្តី នួន ជា ការសម្លាប់ដោយគ្មានដំណើរការច្បាប់ឬមិនមានការធានាអំពីការត្រឹមត្រូវ គឺជាការធ្វើមនុស្សឃាត វាពុំមែនជាការកាត់ទោសប្រហារជីវិតតាមទំនើងចិត្ត ពុំអាចត្រូវបានធ្វើបដិប្បញ្ញត្តិបានឡើយ ទោះបីក្នុងកាលៈទេសៈណាក៏ដោយ រួមទាំងកាលៈទេសៈដែលប្រទេសមានអាសន្នផងដែរ។ ទឡ្ហីករណ៍ទាំងពីរនេះមានទិដ្ឋភាពអង្គហេតុនិងអង្គច្បាប់ ទាក់ទិនភាពស្របច្បាប់នៃការសម្លាប់មនុស្សជាក់លាក់ៗ អង្គជំនុំជម្រះកត់សម្គាល់ថា ការធ្វើមនុស្សឃាតជាទូទៅ ត្រូវបានយល់ថាជាការសម្លាប់មនុស្សដោយខុសច្បាប់ ហើយថា សិទ្ធិរស់រានមានជីវិតដូចមានចែងនៅក្នុងលិខិតុបករណ៍អន្តរជាតិ រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រារាំងមិនឲ្យមានការសម្លាប់តាមទំនើងចិត្តឡើយ។ ការកាត់ទោសប្រហារជីវិតដែលមានចែងនៅក្នុងច្បាប់ក្នុងស្រុកនោះ អាចធ្វើទៅបានលុះត្រាតែមានដំណើរការតាមផ្លូវតុលាការដែលបានផ្តល់ការធានាដល់ជនជាប់ចោទនូវការជំនុំជម្រះក្តីដោយយុត្តិធម៌ប៉ុណ្ណោះ។ រដ្ឋមិនអាចធ្វើបដិប្បញ្ញត្តិលើសិទ្ធិជាមូលដ្ឋាននេះបានឡើយ។ អង្គជំនុំជម្រះ និងធ្វើការដោះស្រាយទៅលើបញ្ហានៃភាពស្របច្បាប់ជាពិសេស អត្ថិភាពនៃដំណើរតាមផ្លូវតុលាការ មុនការប្រហារជីវិត ដោយផ្អែកលើអង្គហេតុនៃរឿងក្តីនេះ។

### ៩.១.២. ការសម្លាប់រង្គាល

**៦៥៣.** ទាក់ទិនសំណុំរឿង០០២/០២ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការសម្លាប់រង្គាលនៅក្នុងអំឡុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២ (ដែលបានកម្រិតត្រឹមការប្រព្រឹត្តចំពោះជនជាតិចាម) នៅសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានការងារទំនប់ ១មករា និងការដ្ឋានសាង

**តនៅលេខក្រោយ**

# កម្មវិធីផ្សាយសំឡេងតាមស្ថានីយ៍វិទ្យុ អេហ្វអឹមជាតិ ភ្នំក្រាំងដីមាស ខេត្តកំពង់ឆ្នាំង ដើម្បីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ផេង ពង្សរ៉ាស៊ី



ស្ថានីយ៍វិទ្យុអេហ្វអឹមជាតិ ភ្នំក្រាំងដីមាស
មន្ទីរព័ត៌មាន ខេត្តកំពង់ឆ្នាំង។
(សេង លីរតនៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា សហការបង្កើតកម្មវិធីវិទ្យុជាមួយស្ថានីយ៍វិទ្យុអេហ្វអឹមជាតិ ភ្នំក្រាំងដីមាស ខេត្តកំពង់ឆ្នាំង សម្រាប់ផ្សព្វផ្សាយកម្មវិធីអប់រំស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងលើកកម្ពស់សិទ្ធិនិងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលប្រព្រឹត្តទៅជារៀងរាល់ថ្ងៃច័ន្ទដល់សុក្រ ពីម៉ោង១២ថ្ងៃត្រង់ដល់ម៉ោង១រសៀល ហើយចាក់ផ្សាយឡើងវិញនៅរៀងរាល់ថ្ងៃសៅរ៍និងអាទិត្យ ចាប់តាំងពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។ ការផ្សាយនេះ ផ្តោតជាសំខាន់ទៅលើ៖ (១) បទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម និងបង្ហាញពីវិធីសាស្ត្របង្រៀនមេរៀនប្រវត្តិសាស្ត្រប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទៅកាន់អ្នកស្តាប់ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្មេងៗជំនាន់ក្រោយ។ (២) ការលើកកម្ពស់សិទ្ធិនិងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិត

ពីរបបខ្មែរក្រហម និងជនពិការ និង(៣) ការផ្តល់នូវកិច្ចការស្រាវជ្រាវនៅតាមមូលដ្ឋាន ជាពិសេសនៅតាមសហគមន៍ដាច់ស្រយាល ស្តីអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតនិងជនពិការពីរបបខ្មែរក្រហម។

សម្រាប់ការផ្សាយពីនាទីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា និងជាអ្នកដែលធ្លាប់បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅតាមសាលារៀននានាក្នុងទូទាំងប្រទេសកម្ពុជា ចូលរួមជាវាគ្មិនប្រចាំថ្ងៃសម្រាប់ការពិភាក្សាពីមាតិកាប្រវត្តិសាស្ត្រ វិធីសាស្ត្របង្រៀន និងបទពិសោធន៍ផ្ទាល់ខ្លួនឆ្លងកាត់របបខ្មែរក្រហម តាមការរៀបចំរបស់កម្មវិធីវិទ្យុដូចតទៅ៖ (១) អធិប្បាយដោយសង្ខេបពីមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយប្រើប្រាស់ជំពូកនៃមេរៀនទាំងអស់ដែលមាននៅក្នុងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។ (២) ពន្យល់ពីវិធីសាស្ត្របង្រៀននៃមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយប្រើប្រាស់សៀវភៅ «ណែនាំសម្រាប់គ្រូបង្រៀនស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ»។ (៣) វេទិកាពិភាក្សា និងផ្តល់ចម្លើយចំពោះសំណួរដែលមានពីអ្នកស្តាប់។ (៤) និយាយពីបទពិសោធន៍ផ្ទាល់ខ្លួនឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ ដើម្បីជាឧទាហរណ៍បន្ថែមទៅលើមេរៀនប្រវត្តិសាស្ត្រ និង(៥) ពិភាក្សាពីកិច្ចការស្រាវជ្រាវទាក់ទងនឹងប្រធានបទ «ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម» តាមរយៈសំណេរស្រាវជ្រាវ វីដេអូឯកសារ និងការពិភាក្សាផ្ទាល់មាត់។

សម្រាប់កម្មវិធីផ្សាយនាទីស្តីពីការលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម អ្នកសម្របសម្រួលកម្មវិធីវិទ្យុ ដែលទទួលបានការចង្អុលបង្ហាញពីមជ្ឈមណ្ឌលឯកសារកម្ពុជាលើគម្រោង នឹងធ្វើការពន្យល់បកស្រាយច្បាស់លាស់ពី៖ (១) គោលបំណងរបស់គម្រោង។ (២) ផែនការសកម្មភាពការងារដែលគ្របដណ្តប់ក្នុងទូទាំងប្រទេសកម្ពុជា។ (៣) តួនាទីនិងភារកិច្ចរបស់អ្នកស្ម័គ្រចិត្តកម្ពុជា។ (៤) ការពន្យល់ពីការប្រើប្រាស់ទម្រង់សំណួរស្ទាបស្ទង់មតិ។ (៥) អត្ថប្រយោជន៍ដែលអ្នកស្ម័គ្រចិត្តកម្ពុជានឹងទទួលបានពីគម្រោងដូចជា បទពិសោធន៍ការងារទំនាក់ទំនងអន្តរជំនាន់ជាមួយអ្នករស់រានមានជីវិត ការបំពេញបន្ថែមនូវចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍។ (៦) តួនាទីរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហមក្នុងការចូលរួមសហការ និងផ្តល់មេរៀនជីវិតផ្ទាល់ខ្លួនដល់ក្មេងៗជំនាន់ក្រោយ ដើម្បីស្តាប់និងរៀនសូត្រក្នុងន័យចងចាំនិងទប់ស្កាត់អំពើប្រល័យពូជសាសន៍ និង (៧) អត្ថប្រយោជន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ ដែលទទួលបានពីគម្រោងដូចជា ការទទួលបានការពិនិត្យនិងព្យាបាលសុខភាពជាប្រចាំនៅមន្ទីរពហុព្យាបាលឯកជនដែលបានសហការណ៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងការអប់រំពីបញ្ហាសុខភាពពីអ្នកជំនាញនិងវេជ្ជបណ្ឌិតល្បីៗ ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

សូមរំឭកថា មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្លាប់បានរៀបចំកម្មវិធីផ្សាយសំឡេងតាមវិទ្យុដដែលនេះម្តងរួចមកហើយកាលពីឆ្នាំ២០១៧-២០១៨ ស្តីអំពីការរៀននិងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាមួយគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ដែលធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីអំពីវិធីសាស្ត្រនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការពិភាក្សាពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមជាមួយអ្នករស់រានមានជីវិតមកពីស្រុកមួយចំនួនក្នុងខេត្តកំពង់ឆ្នាំង។ នៅឆ្នាំ២០២១នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្ត និងពង្រីកបន្ថែមនូវកម្មវិធីលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម។

ស្របពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបិទបញ្ចប់កិច្ចការរបស់ខ្លួននៅត្រឹមពេលនេះ ស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតទាំងអស់ កាន់តែត្រូវបានលើកកម្ពស់ និងយកចិត្តទុកដាក់ ហើយស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន ក៏កាន់តែជំរុញឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា គិតគូរយ៉ាងយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់។ ការផ្សព្វផ្សាយកម្មវិធីតាមវិទ្យុនាពេលនេះ គឺជាការចាប់ផ្តើមផ្សព្វផ្សាយជាលើកដំបូងនៅក្នុងខេត្តកំពង់ឆ្នាំងសម្រាប់ឆ្នាំ២០២១ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងបន្តធ្វើកិច្ចការដូចគ្នានេះ នៅតាមបណ្តាខេត្តមួយចំនួនទៀតក្នុងទូទាំងប្រទេស។



សេង លីរតនៈ អ្នកសម្របសម្រួលកម្មវិធីវិទ្យុអេហ្វអឹមជាតិ ភ្នំក្រាំងដីមាស ខេត្តកំពង់ឆ្នាំង។
(សេង លីរតនៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)




ឧបករណ៍ផ្សាយសំឡេងរបស់ស្ថានីយ៍វិទ្យុអេហ្វអឹមជាតិ ភ្នំក្រាំងដីមាស ខេត្តកំពង់ឆ្នាំង។
(សេង លីរតនៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ផែះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ជា គីមស្រេង៖ មេផ្ទះ

**រៀបរាប់ប្រាប់ដោយកូនស្រីឈ្មោះ ជា គីមវណ្ណី**

ម្ដាយរបស់ខ្ញុំគឺជាកសិករមកពីទន្លេបិត រីឯឪពុករបស់ខ្ញុំធ្វើជាជាងមាសមកពីខេត្តកំពង់ចាម។ គាត់ជួបគ្នានៅវត្តមួយ។ ឪពុករបស់ខ្ញុំបានសុំម្ដាយខ្ញុំរៀបការជាច្រើនដងមុនពេលដែលម្ដាយរបស់ខ្ញុំយល់ព្រមរៀបការជាមួយគាត់។ បន្ទាប់ពីពួកគាត់រៀបការរួច ឪពុករបស់ខ្ញុំនៅបន្តធ្វើជាជាងមាសទៀត ចំណែកម្ដាយខ្ញុំស្នាក់នៅផ្ទះមើលថែរក្សាកូនចំនួន១២នាក់។ ជារឿយៗ ម្ដាយរបស់ខ្ញុំធ្វើដំណើរទៅសួរសុខទុក្ខប្អូនរបស់គាត់នៅ ទីក្រុងភ្នំពេញ ហើយតែងតែយកខ្ញុំ និងកូនៗ៤ឬ៥នាក់ផ្សេងទៀតទៅជាមួយ។

ឪពុកម្ដាយរបស់ខ្ញុំបានចាប់ផ្ដើមរស់នៅបែកគ្នាក្នុងអំឡុងរបប លន់ នល់។ ឪពុកម្ដាយរបស់ខ្ញុំមិនអាចទំនាក់ទំនងគ្នាបានឡើយ ព្រោះឪពុករបស់ខ្ញុំរស់នៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ស្របពេលដែលម្ដាយរបស់ខ្ញុំរស់នៅក្នុងតំបន់ដែលគ្រប់គ្រងដោយទាហាន លន់ នល់។ នៅពេលនោះ ម្ដាយរបស់ខ្ញុំបានទៅសួរសុខទុក្ខប្អូនរបស់គាត់នៅឯ



ជា គីមស្រេង
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភ្នំពេញ ហើយមិនអាចត្រឡប់មកស្រុកកំណើតវិញ ព្រោះតែមានការប្រយុទ្ធគ្នា។ យើងស្នាក់នៅក្នុងបន្ទប់មួយជាមួយនឹងប្អូនស្រីម្ដាយរបស់ខ្ញុំឈ្មោះ ជា យិចណៃ។ គាត់ពិតជាចិត្តល្អខ្លាំងណាស់ និងយល់ពីស្ថានភាពម្ដាយរបស់ខ្ញុំត្រូវចិញ្ចឹមកូនជាច្រើននាក់។ ដូច្នេះហើយ គាត់ឲ្យយើងរស់នៅជាមួយគាត់។

ជួនពេលខ្លះ យើងស្នាក់នៅជាមួយប្អូនប្រុសរបស់ម្ដាយខ្ញុំឈ្មោះ ប៉េង គា។ គាត់គឺជាអ្នកបើកយន្តហោះ និងជាអនុសេនីយ៍ឯកនៅក្នុងកងទ័ព ដែលជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ គាត់ និងកូនប្រុស២នាក់បានបាត់ខ្លួនក្នុងរបបខ្មែរក្រហម។

នៅក្នុងឆ្នាំ១៩៧៥ ស្ថានការណ៍នៅក្នុងប្រទេសកម្ពុជាកាន់តែយ៉ាប់យ៉ឺនទៅៗ។ យើងរស់នៅក្នុងទីក្រុងភ្នំពេញ ដែលជាកន្លែងមួយដែលសាច់ញាតិម្នាក់របស់ខ្ញុំធ្វើការងារជាអ្នកបកប្រែនៅក្នុងមណ្ឌលកុមារកំព្រា ហើយម្ដាយរបស់ក៏ធ្វើជាអ្នកចម្អិនអាហារនៅ ទីនោះដែរ។ នេះគឺអាចអនុញ្ញាតិឲ្យយើងអាចស្នើសុំទិដ្ឋាការចាកចេញទៅរស់នៅសហរដ្ឋអាមេរិកបាន។ សាច់ញាតិរបស់ខ្ញុំបានចុះឈ្មោះខ្ញុំ និងបងប្អូនរបស់ខ្ញុំនៅមណ្ឌលកុមារកំព្រា ដោយបាននិយាយថាយើងមិនមានឪពុកម្ដាយទេ។ ដោយសារមូលហេតុនេះហើយ ទើបយើងអាចស្នើសុំទិដ្ឋាការដើម្បីទៅរស់នៅអាមេរិកបាន។

នៅថ្ងៃទី១៧ ខែមេសា យើងបានរៀបចំខ្ចប់សម្លៀកបំពាក់មួយចំនួន និងធ្វើដំណើរទៅវត្តភ្នំដើម្បីរង់ចាំយន្តហោះដែលនឹងមកដឹកកុមារកំព្រា

ទៅអាមេរិក។ ក្រុមគ្រួសាររបស់យើងគឺជាអ្នកដែលចាកចេញទៅអាមេរិកចុងក្រោយគេបង្អស់។ យើងឃើញយន្តហោះហោះឆ្វែល ប៉ុន្តែមិនបានចុះចតនោះទេ។ មួយស្របក់ក្រោយមក យោធាដែលស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅកាន់កាំភ្លើង បានមកដល់។ យោធាបានបញ្ជាយើងឲ្យចាកចេញពីទីក្រុងភ្នំពេញទៅតាខ្មៅ។ សមាជិកគ្រួសារ ៧ នាក់ រួមមាន ម្ដាយរបស់ខ្ញុំ កូនស្រីចំនួន៣នាក់ កូនប្រុសម្នាក់ និងបងប្អូនជីដូនមួយចំនួន២នាក់ បានដើរអស់រយៈពេលប្រហែល ១ខែទើបទៅដល់ភូមិព្រែកអំបិល ក្នុងស្រុកកោះធំ។

ម្ដាយរបស់ខ្ញុំ និងខ្ញុំធ្វើការងារស្រែចម្ការ រីឯបងៗរបស់ខ្ញុំលើកទំនប់។ ដំបូង យើងអាចរស់នៅជាមួយគ្នា។ តំបន់នោះមានដាំពោត ហើយយើងអាចស្វែងរកបន្លែបន្ថែមដើម្បីបរិភោគ។ ប៉ុន្តែ ក្រោយមក អង្គការបានបញ្ជូន ១០០គ្រួសារចេញទៅខេត្តបាត់ដំបង។ យើងធ្វើដំណើរទៅទីនោះដោយរថយន្ត ហើយបន្ទាប់មកជិះត្រាក់ទ័រ និងរទេះគោបន្ត។ បន្ទាប់ពីយើងបានទៅដល់ខេត្តបាត់ដំបង យើងរស់នៅក្នុងជំរំមួយដែលស្ថិតនៅក្នុងព្រៃជ្រៅ។ អង្គការបានបញ្ជាឲ្យបុរសទៅលើកទំនប់ និងស្រីៗធ្វើស្រែចម្ការ។ ដំបូង យើងគ្មានអាហារបរិភោគគ្រប់គ្រាន់នោះទេ ប៉ុន្តែក្រោយមកយើងទទួលបានបបរខាប់។

ថ្ងៃមួយ ម្ដាយរបស់ខ្ញុំបានឈ្លោះប្រកែកជាមួយបងរបស់ខ្ញុំ។ បន្ទាប់មកអង្គការបានយកគាត់ទៅរៀនសូត្រដែលជាការព្រមានមិនឲ្យវាយកូនទៀត។

អង្គការបានប្រាប់យើងឲ្យធ្វើការងារបែកគ្នា ដូច្នេះគ្រួសារយើងកម្របានជួបគ្នាណាស់។ ខ្ញុំសែងអាចម៍គោនៅក្នុងកងកុមារ។ បងៗរបស់ខ្ញុំចំនួនពីរនាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម។ បងរបស់ខ្ញុំម្នាក់បានទៅសម្រាកនៅមន្ទីរពេទ្យ ហើយបានស្លាប់ដោយសារអត់ឃ្លាន។ ម្ដាយរបស់ខ្ញុំចង់ទៅមើលថែរក្សាកូនរបស់គាត់ណាស់ ប៉ុន្តែខ្មែរក្រហមមិនបានអនុញ្ញាតឡើយ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យម្ដាយរបស់ខ្ញុំមើលសាកសពបងស្រីរបស់ខ្ញុំជាលើកចុងក្រោយឡើយ ហើយក៏មិនបានប្រាប់យើងថាកន្លែងបញ្ចុះសពបងស្រីខ្ញុំនៅទីណាដែរ។ នៅពេលដែលបងស្រីរបស់ខ្ញុំស្លាប់គ្មាននរណាម្នាក់នៅក្នុងក្រុមគ្រួសារដឹងថាខ្មោចរបស់បងស្រីរបស់ខ្ញុំយកទៅណាឡើយ។ ក្រោយមក បងស្រីរបស់ខ្ញុំម្នាក់ទៀតបានស្លាប់ដោយសារជំងឺគ្រុនពោះនៅពេលដែលគាត់កំពុងតែកាប់ឆ្ការព្រៃ។

**បាង ពិច័ន្ទ និង ទេនី ខកហ្កៀល**



ជា យិចណៃ ត្រូវជាប្អូនស្រី ជា គីមស្រេង (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប៉េង គា ត្រូវជាប្អូនប្រុសរបស់ ជា គីមស្រេង (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

ក្រុមគ្រូពេទ្យពិនិត្យសុខភាពជូនប្រជាជនបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅដើមខែមករា ឆ្នាំ១៩៧៩។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

ជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ វិលត្រឡប់មកស្រុកកំណើត

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅដើមខែមករា ឆ្នាំ១៩៧៩។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)។




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 261, September 2021 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.